# ប្រជាជន

THE PRACHEACHUN MAGAZINE




## អបអរសាទរ ខួបទី ៣៩ នៃ ទិវាជ័យជម្នះ ៧ មករា

ឆ្នាំទី១៧ លេខ ១៩៩ ខែធ្នូ ឆ្នាំ ២០១៧





ផ្លែផ្កានៃដំណើរទស្សនកិច្ចរបស់លោកជំទាវ **សេក្ខ ហាស៊ីណា** នាយករដ្ឋមន្ត្រី បង់ក្លាដេស នៅ......

៦



**សម្តេចតេជោ ហ៊ុន សែន** អញ្ជើញចូលរួមក្នុងកិច្ចប្រជុំជាន់ខ្ពស់នៃបក្សកុម្មុយនីស្តចិន សន្ទនាជាមួយ....

* សម្តេចតេជោ គឺជាមិត្តចាស់ មិត្តពិតប្រាកដ និង.....
* ទោះបស្ចិមប្រទេសចាត់ទុកកម្ពុជាជាអ្វីក៏ដោយ......

៨



ពិធីបួងសួងសុំសេចក្តីសុខចម្រើនដល់ព្រះរាជាណាចក្រកម្ពុជានៅមុខប្រាសាទអង្គរវត្ត

១០



សម្តេចតេជោ ហ៊ុន សែន ៖ ប្រជាធិបតេយ្យដែលគ្មានការគ្រប់គ្រងដោយច្បាប់.....

* មានវត្តមាន ហ៊ុន សែន នៅទីនេះ សូមកុំ........
* ប្រជាធិបតេយ្យ សេរី ពហុបក្ស មិនក្លាយជា.....
* ប្រជាជនកម្ពុជាបានត្រៀមរួចរាល់ហើយ .........

១២



កម្ពុជាប្រារព្ធខួបអនុស្សាវរីយ៍លើកទី៣៩ ថ្ងៃកំណើតរណសិរ្សសាមគ្គីអភិវឌ្ឍន៍............

១៦



**សម្តេចក្រឡាហោម ស ខេង** បញ្ជាឲ្យប៉ូលិសនៅមូលដ្ឋានផ្សព្វផ្សាយពីកំហុសក្បត់ជាតិរបស់អតីត.....

១៧


**និពន្ធនាយក :**

**លោក តាក ស៊ុនអ៊ី**

**គណៈកម្មការនិពន្ធ**

១. លោក ខៀវ ណារី

២. លោក អ៊ឹម សុន្ទរ:

៣. លោក វង្ស សារុំធ

៤. លោក ទាវ សារ:មុនី

៥. លោក សុខ សុធន

**លេខានិពន្ធ**

១. លោក ជុំ សម្បត្តិ

២. លោក ម៉ក់ ឈិន

**អ្នកបកប្រែភាសា**

១. លោកស្រី ម៉ែន នារីសោភ័គ

**អ្នកថតរូប**

១. លោក សុផាត វីរ:មុនី

**វិចិត្រករ**

១. លោក ធា សារុំធ



អាស័យដ្ឋាន :

លេខ ២០៣

មហាវិថី ព្រះនរោត្តម

ភ្នំពេញ-កម្ពុជា

ទូរស័ព្ទលេខ :

០២៣ ២១៩ ០៦៥

**Address :**

**No 203 Preah**

**Norodom Bld.**

**Phnom Penh Cambodia**

**Tel : 023 219 065**


# ប្រជាជន

## ក្រោមការដឹកនាំរបស់គណបក្សប្រជាជនកម្ពុជា ប្រទេសកម្ពុជាមានសុខសន្តិភាព និងការអភិវឌ្ឍ

# មាតិកា Contents


វិចារណកថា : ៧មករា គឺជានិមិត្តរូបនៃសន្តិភាព វិបុលភាពនិងការអភិវឌ្ឍ.................................... ៣

Editorial : 7 January - A Symbol of Peace, Prosperity, and Development..............................

អត្ថបទនយោបាយ : ជីវភាពសង្គមនៅកម្ពុជា ដំណើរការជាប្រក្រតី និងកាន់តែធានា......................... ៥

⇨ សកម្មភាពសមាជិក រដ្ឋសភា ព្រឹទ្ធសភា រាជរដ្ឋាភិបាល និងមន្ត្រីគណបក្ស ................................ ១៨

⇨ សកម្មភាពរបស់ក្រុមការងារយុវជនគណបក្ស ............................................................................ ២១

⇨ សមិទ្ធផលសំខាន់ៗមួយចំនួននៃវិស័យសេដ្ឋកិច្ច............................................................... ២៣

⇨ ថវិកាឆ្នាំ២០១៨ ជាថវិកាយុទ្ធសាស្ត្រនៃការពូនជ្រុំកម្លាំង និងធនធាន.......................................... ២៤

⇨ ចក្ខុវិស័យ និងផែនការការងារវិស័យសាធារណការ និងដឹកជញ្ជូនសម្រាប់.................................... ២៦

⇨ ចំណេះដឹងទូទៅ : អំពីមហាសន្និបាតតំណាងទូទាំងប្រទេសលើកទី១៩ របស់បក្សកុម្មុយនីស្តចិន.... ២៧

⇨ ទឹកដីមាតុភូមិ : ទើបចាប់បដិសន្ធិជាង ៦ ឆ្នាំ ឃុំតេជោអភិវឌ្ឍន៍មានការរីកចម្រើន........................ ២៩

⇨ កំណាព្យ : សំណើច សំណោក សំណាង......................សំណើច................................................. ៣១

# សូមគោរពជូនពរបវរសួស្តីមហាប្រសើរ

## ក្នុងឱកាសដ៏មហានក្ខត្តឫក្សនៃទិវាបុណ្យរំឭកខួប

## អនុស្សាវរីយ៍លើកទី ៣៩ ទិវាជ័យជម្នះ ៧ មករា

( ៧.១.១៩៧៩ ~ ៧.១.២០១៨ )



*សម្តេចអគ្គមហាពញាចក្រី*
**ហេង សំរិន**
ប្រធានរដ្ឋសភា នៃព្រះរាជាណាចក្រកម្ពុជា
**ប្រធានកិត្តិយសគណបក្សប្រជាជនកម្ពុជា**



*សម្តេចអគ្គមហាសេនាបតីតេជោ*
**ហ៊ុន សែន**
នាយករដ្ឋមន្ត្រីនៃព្រះរាជាណាចក្រកម្ពុជា
**ប្រធានគណបក្សប្រជាជនកម្ពុជា**



*សម្តេចក្រឡាហោម*
**ស ខេង**
ឧបនាយករដ្ឋមន្ត្រី និងជារដ្ឋមន្ត្រីក្រសួងមហាផ្ទៃ
**អនុប្រធានគណបក្សប្រជាជនកម្ពុជា**



*សម្តេចវិបុលសេនាភក្តី*
**សាយ ឈុំ**
ប្រធានព្រឹទ្ធសភា នៃព្រះរាជាណាចក្រកម្ពុជា
**អនុប្រធានគណបក្សប្រជាជនកម្ពុជា**

សូម **សម្តេច** បានប្រកបដោយសុខភាពបរិបូរ កាយពលមាំមួន បញ្ញាញាណភ្លឺថ្លា ជន្មាយុយឺនយូរ ដើម្បីបន្តដឹកនាំ មាតុភូមិ និងប្រជាជនកម្ពុជាសម្រេចបានជោគជ័យធំៗថ្មីទៀត ក្នុងបុព្វហេតុ ឯករាជ្យ សន្តិភាព សេរីភាព ប្រជាធិបតេយ្យ និងវឌ្ឍនភាពសង្គម ។

**គោរពជូនដោយក្តីកតញ្ញូតាធម៌ដ៏ជ្រាលជ្រៅបំផុត**

**ទស្សនាវដ្តីប្រជាជន**

# សិរីសួស្តីឆ្នាំថ្មី

## ក្នុងឱកាសចូលឆ្នាំថ្មី ឆ្នាំសកល ២០១៨



យើងខ្ញុំសូមគោរពជូនពរបវរសួស្តី សិរីមង្គល មហាប្រសើរជូនសម្តេច ឯកឧត្តម លោកជំទាវ អ្នកឧកញ៉ា មន្ត្រីរាជការកងយោធពលខេមរភូមិន្ទ កងរាជអាវុធហត្ថ កងនគរបាលជាតិ និងប្រជាជនកម្ពុជានៅគ្រប់ទិសទី ព្រមទាំងអង្គទូត និងអង្គការអន្តរជាតិនានា ដែលកំពុងបំពេញបេសកកម្មដ៏ឧត្តុង្គឧត្តមនៅ ព្រះរាជាណាចក្រកម្ពុជា សូមទទួលបាននូវជោគជ័យថ្មីៗថែមទៀត នៅក្នុងការបំពេញភារកិច្ច និងសូមបានប្រកបតែនឹងពុទ្ធពរទាំងបួនប្រការ គឺ អាយុ វណ្ណៈ សុខៈ ពលៈ កុំបីឃ្លៀងឃ្លាតឡើយ ។

**គោរពជូនពី**

**ទស្សនាវដ្តីប្រជាជន**

# *Happy New Year*

## On the occasion of the Universal New Year 2018

*the Pracheachun Magazine would like to express its sincere best wishes to Samdechs, Your Royal Highnesses, Excellencies, Lok Chumteav, Lok Oknha, Government Officials, Royal Armed Forces, Military Police, National Police, Compatriots, Diplomatic Mission and International Organizations in the Kingdom of Cambodia good health, wealth, happiness, prosperity and every success.*

*from the Pracheachun magazine*

# ៧មករា គឺជានិមិត្តរូបនៃសន្តិភាព វិបុលភាព និងការអភិវឌ្ឍ

## 7 January – A Symbol of Peace, Prosperity, and Development

បច្ចុប្បន្ននេះព្រះរាជាណាចក្រកម្ពុជា ទទួលបាននូវសុខសន្តិភាពយ៉ាងពេញលេញ បរិបូណ៌ ប្រជាជនបានរស់នៅប្រកបដោយភាពសុខដុមរមនា ពង្រឹងបាននូវផ្លូវសាមគ្គីជាតិ ឯកភាពជាតិ ក្នុងក្របខណ្ឌនៃប្រទេសមួយដែលកំពុងការពារបានយ៉ាងរឹងមាំនូវខឿនឯករាជ្យជាតិ និងអធិបតេយ្យជាតិ ។ ប្រទេសកម្ពុជាក៏កំពុងទទួលបាន នូវសមិទ្ធផលជាផ្លែផ្កាជាច្រើនក្នុងការអភិវឌ្ឍន៍សេដ្ឋកិច្ចសង្គម រួមចំណែកដល់ការលើកកម្ពស់ជីវភាពរស់នៅរបស់ប្រជាជនឲ្យមានការរីកចម្រើនប្រសើរឡើងឥតឈប់ឈរ ។ បើយើងងាកបកក្រោយទៅមើលអំពីស្ថានភាពនៃ មាតុភូមិដ៏កំសត់របស់យើង និងជីវិតរស់នៅដ៏ក្រីក្រតោកយ៉ាកហួសនិស្ស័យរបស់ប្រជាជនយើងបន្ទាប់ពីត្រូវបាន សង្គ្រោះចេញពីរបបប្រល័យពូជសាសន៍ នាថ្ងៃទី៧ ខែមករា ឆ្នាំ១៩៧៩ យើងពិតជាមានមោទនភាពខ្លាំងណាស់ចំពោះអ្វីដែលយើងបានទទួលនៅពេលបច្ចុប្បន្ននេះ ។ ៧មករា បានបញ្ចប់សម័យកាលដ៏ខ្មៅងងឹតបំផុត ហើយបានបើកឡើងនូវទំព័រសករាជថ្មី គឺឯករាជ្យ សន្តិភាព សេរីភាព ប្រជាធិបតេយ្យ និងវឌ្ឍនភាពសង្គម ។ ៧មករា គឺជាកម្លាំងរស់ដ៏អស្ចារ្យពោរពេញដោយថាមពលរឹងមាំរបស់ប្រជាជាតិកម្ពុជា ។ ក្រោមការដឹកនាំរបស់គណបក្ស ប្រជាជនកម្ពុជា ប្រជាជនយើងទូទាំងប្រទេសបានខិតខំប្រឹងប្រែង ពុះពារអស់កម្លាំងកាយចិត្តតស៊ូជំនះនូវឧបសគ្គ រាប់ម៉ឺនរាប់សែនជំពូកនាំមកនូវជោគជ័យដ៏ត្រចះត្រចង់ជូនជាតិមាតុភូមិ ។

ប្រជាជនកម្ពុជាទូទាំងប្រទេសបាន និងកំពុងសម្តែងក្តីសប្បាយរីករាយចូលរួមអបអរសាទរប្រារព្ធពិធីខួបអនុស្សាវរីយ៍លើកទី៣៩ នៃទិវាជ័យជម្នះ៧មករា ជាប្រវត្តិសាស្ត្រ (៧មករា ១៩៧៩ - ៧មករា ២០១៨) ក្នុងពេល ដែលប្រទេសជាតិយើងសម្រេចបានសមិទ្ធផលធំៗជាច្រើន ដូចជា ជោគជ័យការបោះឆ្នោតក្រុមប្រឹក្សា ឃុំ សង្កាត់ អាណត្តិទី៤ កាលពីខែមិថុនា ឆ្នាំ២០១៧ ការជំរុញលទ្ធិប្រជាធិបតេយ្យឲ្យកាន់តែមានជំហានរីកលូតលាស់ តាមរយៈការពង្រឹងគោលការណ៍នីតិរដ្ឋ គាស់រំលើងចោលឧបាយកលនៃបដិវត្តន៍ពណ៌នៅកម្ពុជា និងការរីកចម្រើនការក្នុងអភិវឌ្ឍវិស័យសេដ្ឋកិច្ចសង្គម ។

៧មករា គឺជានិមិត្តរូបនៃសន្តិភាព វិបុលភាព និងការអភិវឌ្ឍ ។ នេះជាសច្ចធម៌ប្រវត្តិសាស្ត្រ ដែលគ្មានអ្នកណាអាចបំភ្លៃបានឡើយ ។ យើងទាំងអស់គ្នាចងចាំជានិច្ចថា សន្តិភាពនេះបានមកពីការតស៊ូលះបង់អាយុជីវិត របស់អ្នកស្នេហាជាតិ របស់ថ្នាក់ដឹកនាំគណបក្សប្រជាជនកម្ពុជា ក្នុងការសង្គ្រោះជាតិចេញពីរបបប្រល័យពូជសាសន៍ នៅថ្ងៃ៧មករា ឆ្នាំ១៩៧៩ និងបានឆ្លងកាត់នូវដំណាក់កាលជាច្រើនទៀត ពោរពេញទៅដោយឧបសគ្គរាប់មិនអស់ រហូតដល់ឆ្នាំ១៩៩៨ ទើបយើងបានស្គាល់រសជាតិសន្តិភាពពិតប្រាកដ និងអធិបតេយ្យជាតិពេញបរិបូរណ៌ បើគិតចាប់តាំងពីថ្ងៃទី១៨ មីនា ឆ្នាំ១៩៧០ ដែលបនក្បត់ជាតិ លន់ នល់ ជាអ្នកបម្រើរបស់អាមេរិក ធ្វើរដ្ឋប្រហារផ្តួលរំលំ **ព្រះករុណាព្រះបាទសម្តេចព្រះបរមរតនកោដ្ឋ** ។ អាស្រ័យដោយជ័យជម្នះ ៧មករា ប្រជាជនយើងបានរស់ឡើងវិញ និងបានពួតដៃគ្នាចូលរួមក្នុងកិច្ចការ ការពារជាតិ និងកសាងមាតុភូមិរយៈពេល១០ (១៩៧៩-១៩៨៩) បានបង្កជាបុព្វបទក្នុងដំណើរការស្វែងរកសន្តិភាព និងការបង្រួបបង្រួមជាតិរហូតសម្រេចបានកិច្ចព្រមព្រៀងទីក្រុងប៉ារីស នៅខែតុលា ឆ្នាំ១៩៩១ ។ ប៉ុន្តែកម្ពុជាពុំទាន់ទទួលបានសន្តិភាពពេញលេញទេ រហូតដល់ចុងឆ្នាំ១៩៩៨ អាស្រ័យដោយនយោបាយ ឈ្នះ ឈ្នះ របស់សម្តេចតេជោ **ហ៊ុន សែន** អង្គការចាត់តាំងខាងនយោបាយ និងយោធារបស់ខ្មែរក្រហមត្រូវរលំរលាយ ទើប

At present, the Kingdom of Cambodia has achieved full peace. People are living in harmony, and strengthening national strand of solidarity and unity within a country that is defending firmly foundation of national independence and sovereignty. Cambodia is scoring fruitful achievements in socio-economic development, contributing to improvement of people's living condition and unceasing progress. If we look back and review status of our pitiful motherland and life in unimaginable hardships of our people after salvation of the regime of genocide on 7 January 1979, we are now proud for what we have done and achieved till today. The 7 January day ended a darkest period and ushered in a new era page of independence, peace, freedom, democracy, and social progress. The 7 January day is a living force full of energy of the Cambodian nation. Under the leadership of the Cambodian People's Party, our people in the whole country have been making steadfast efforts and overcoming numerous obstacles with all of their physical and mental strengths to score victories for our motherland.

The Cambodian people in the whole country have been manifesting their joy and participation in the celebration of the 39th anniversary of the historic victory on 7 January (7 January 1979 - 2018) at a time when the country is scoring numerous major achievements such as the fourth-term elections of the commune councils on 4 June 2017 to move democracy to further advancement, through efforts to strengthen principle of rule of law, uprooting ploy of color revolution in Cambodia, and making more progresses in socioeconomic development.

The 7 January day is a symbol of peace, prosperity, and development. It is an historic truth that no one can misconstrue it. We all are remembering always that peace comes from sacrifice of lives of our patriots, leaders of the Cambodian People's Party, and salvation of the country from the regime of genocide on 7 January 1979. We have gone through various phases full of obstacles until 1998 to achieve real peace and full national sovereignty since 18 March 1970, when the traitor Lon Nol launched a coup to remove Samdech Preah Borom Ratanakaod.

Thanks to the victory on 7 January 1979, our people survived and worked together in a ten-year period of national defense and reconstruction (1979-1989) to create a founding course to search for peace and national reconciliation to achieve the Paris Peace Accord in October 1991. However, Cambodia was not yet at full peace, until late 1998, since there was no yet Samdech Techo Hun Sen's win-win policy that dissolved the Khmer Rouge organization militarily and politically. That ended the war, and brought back to peace, national unity, land reunification, and living together under one Constitution for our people. Peace and political stability have provided a great and unprecedented opportunity for socio-economic development in the last roughly 500 years of the Cambodian history.

Under the shade of peace, the Cambodian people started to grab chances for the country's development. We are really proud to see that Cambodia has achieved a striving economic growth up to 7,7% perannum in the last two decades, and continues to achieve growth around 6,9% for 2017 . The poverty rate of 100% in 1979 has dwindled to 53.5% in 2004, and 13.5% in 2014. Our GDP in 1998 was just 253 USD per person. In 2013, it had jumped to 1,042 USD, and in 2017, it has reached 1,435 USD. It will continue to go up to roughly 1,568 USD in 2018. Cambodia ranked fourth in terms of the fastest poverty reduction in the world, and was among the top seven countries in the world with the fastest HDI growth rate in between 1990 and 2015. In 2016, Cambodia rose from s status of low income to lower-middle income country. We hope to become a higher-middle income country by 2030.

Particularly, in 2017, Cambodia's economic sector continues to indicate magnificent progress supported by flow of investments in manufacturing, construction, tourism, and agro-industrial production. Such economic growth and macroeconomic stability allowed our people to search for jobs and make more income. Civil servants and armed forces have achieved income higher and higher from one year

សង្គ្រាមត្រូវបានបញ្ចប់ ប្រទេសជាតិទទួលបានមកវិញនូវសុខសន្តិភាព ឯកភាពជាតិ ឯកភាពទឹកដី ប្រជាជនបានរស់នៅក្រោមដំបូលរដ្ឋធម្មនុញ្ញតែមួយ ។ សុខសន្តិភាព និងស្ថិរភាពនយោបាយបាន ផ្ដល់កាលានុវត្តភាពយ៉ាងធំធេង ដែលមិនធ្លាប់មានដល់ដំណើរការអភិវឌ្ឍន៍សេដ្ឋកិច្ចសង្គម ក្នុងរយៈពេលប្រមាណ ៥០០ឆ្នាំនៃប្រវត្តិសាស្ត្រកម្ពុជា។

ក្រោមម្លប់នៃសន្តិភាព ប្រជាជនកម្ពុជាយើងចាប់ផ្ដើមមានឱកាសអភិវឌ្ឍន៍ប្រទេស ។ យើងពិតជាមាន មោទនភាពក្នុងពេលដែលកម្ពុជាមានសន្ទុះកំណើនសេដ្ឋកិច្ចខ្ពស់រហូតដល់៧,៧%ក្នុងមួយឆ្នាំក្នុងរយៈពេលជាង ២ទស្សវត្សកន្លងមក និងបន្តមានកំណើនក្នុងរង្វង់ ៦,៩% ក្នុងឆ្នាំ២០១៧ ។ អត្រានៃភាពក្រីក្រ ដែលកាលពីឆ្នាំ១៩៧៩ មាន១០០% បានថយចុះមក នៅ ៥៣,៥% ក្នុងឆ្នាំ២០០៤ និង១៣,៥% ក្នុងឆ្នាំ២០១៤ ។ ផលិតផលក្នុងស្រុកសរុបគិតជាមធ្យម សម្រាប់ប្រជាជនម្នាក់នៅឆ្នាំ១៩៩៨ មានត្រឹម តែ ២៥៣ដុល្លារអាមេរិក នៅ ឆ្នាំ២០១៣ កើនដល់ប្រមាណ ១០៤២ដុល្លារ នៅឆ្នាំ២០១៧ កើនដល់ ១៤៣៥ដុល្លារហើយ និងបន្តឡើងដល់ប្រមាណ ១៥៦៨ដុល្លារអាមេរិក នៅឆ្នាំ២០១៨ ។ កម្ពុជាក៏ទទួលបានចំណាត់ថ្នាក់ ជាប្រទេសជោគជ័យបំផុតទី៤ លើពិភពលោក ក្នុងការកាត់បន្ថយអត្រាភាពក្រីក្រជាប្រទេសឈានមុខគេទាំង៧ លើពិភពលោក ក្នុងការកែលម្អសន្ទស្សន៍នៃការអភិវឌ្ឍមនុស្សក្នុងចន្លោះឆ្នាំ១៩៩០ ដល់ឆ្នាំ២០១៥ ។ នៅឆ្នាំ២០១៦ កម្ពុជាបានងើបផុតចេញពីឋានៈជាប្រទេសដែលមានចំណូលទាបទៅជាប្រទេសដែលមានចំណូលមធ្យមកម្រិតទាប ហើយសង្ឃឹមថា នឹងក្លាយជាប្រទេសដែលមានចំណូលមធ្យមកម្រិតខ្ពស់នៅ ឆ្នាំ២០៣០ ។ ដោយឡែកនៅឆ្នាំ២០១៧នេះ វិស័យសេដ្ឋកិច្ចនៅតែបង្ហាញសញ្ញារីកចម្រើនដ៏ធំធេង ដែលទ្រទ្រង់ដោយលំហូរនៃការវិនិយោគវិស័យវាយនភណ្ឌសំលៀកបំពាក់ ទេសចរណ៍ និងផលិតកម្មកសិកម្ម ឧស្សាហកម្ម ។ ការសម្រេចបាននូវកំណើនសេដ្ឋកិច្ច និងស្ថិរភាពម៉ាក្រូសេដ្ឋកិច្ច បានធ្វើឲ្យប្រជាជនកម្ពុជាកាន់តែមានឱកាសស្វែងរកការងារ និងបង្កើនប្រាក់ចំណូល ។ មន្ត្រីរាជការ កងកម្លាំងប្រដាប់អាវុធទទួលបានប្រាក់ចំណូលកាន់តែខ្ពស់ពីមួយឆ្នាំទៅមួយឆ្នាំ តាមរយៈការអនុវត្តគោលនយោបាយតម្លើងប្រាក់បៀវត្សក្នុងគោលដៅជាង ១លានរៀល នៅឆ្នាំ ២០១៨ របស់រាជរដ្ឋាភិបាល ។ កម្មករ និយោជិត រាប់សែននាក់ដែលកំពុងបម្រើការងារក្នុងវិស័យឯកជនក៏ទទួលបានឱកាសក្នុងការបង្កើនប្រាក់ចំណូលរបស់ខ្លួនដែរ ដែលនឹងត្រូវកើនឡើងដល់ ១៧០ដុល្លារ នៅឆ្នាំ២០១៨នេះ ដោយមិនទាន់គិតទៅដល់ការទទួលបាននូវអត្ថប្រយោជន៍ផ្សេងពីការអនុវត្តគោលនយោបាយគាំពារសង្គមរបស់រាជរដ្ឋាភិបាល ។ រាជរដ្ឋាភិបាលកម្ពុជាក៏បានដាក់ចេញនូវវិធានការ គោលនយោបាយចាំបាច់នានាជាបន្តបន្ទាប់ក្នុងគោលដៅដោះស្រាយការលំបាក ក្ដីកង្វល់ និងបំណងប្រាថ្នារបស់ប្រជាជនទូទាំងប្រទេស ព្រមទាំងដោះស្រាយបញ្ហាប្រឈមរបស់ជាតិ ទាំងបញ្ហាសង្គម និងសេដ្ឋកិច្ច ។

ទន្ទឹមនឹងការរីកចម្រើនខាងសេដ្ឋកិច្ច ប្រទេសកម្ពុជាក៏បានខិតខំលើកកម្ពស់លទ្ធិប្រជាធិបតេយ្យលើគោល ការណ៍នីតិរដ្ឋ ដែលបានស្ដែងចេញតាមរយៈការបោះឆ្នោតថ្នាក់ជាតិ និងថ្នាក់ក្រោមជាតិជាបន្តបន្ទាប់ស្របតាម ច្បាប់ និងរដ្ឋធម្មនុញ្ញ ព្រមទាំងប្រកាន់ខ្ជាប់នូវគោលការណ៍ជាសកលនៃការគោរពសិទ្ធិមនុស្សជាមូលដ្ឋានប្រឆាំង ដាច់ខាតរាល់ការជ្រៀតជ្រែកកិច្ចការផ្ទៃក្នុងការញុះញង់ ការរើសអើងពូជសាសន៍ ដែលអាចបង្កឲ្យមានអំពើហិង្សា ការបះបោរ និងបំបែកបំបាក់សាមគ្គីជាតិ ក្រោមផ្លាកលទ្ធិប្រជាធិបតេយ្យ និងសិទ្ធិមនុស្ស បម្រើផលប្រយោជន៍នយោបាយឲ្យជនក្បត់ជាតិ និងពួកបរទេសដែលចង់ផ្លាស់ប្ដូររាជរដ្ឋាភិបាលស្របច្បាប់ និងរុញច្រានមាតុភូមិកម្ពុជា ឲ្យធ្លាក់ចូលក្នុងភ្លើងសង្គ្រាមដោយសារបដិវត្តន៍ពណ៌ ។ ជាមួយគ្នានេះ កិត្យានុភាពរបស់ព្រះរាជាណាចក្រកម្ពុជា ត្រូវបានលើកកម្ពស់នៅលើឆាកអន្តរជាតិ ដោយបានដើរតួនាទីយ៉ាងសកម្មជាមួយបណ្ដារដ្ឋផ្សេងៗ និងសហគមន៍អន្តរជាតិជួយស្វែងរកសន្តិភាពជូនដល់ប្រទេស ដែលកំពុងមានជម្លោះក្រោមក្របខណ្ឌនៃកិច្ចប្រតិបត្តិការរបស់អង្គការសហប្រជាជាតិ ។ កម្ពុជាត្រូវបានអង្គការសហប្រជាជាតិវាយតម្លៃជាប្រទេសជាប់លំដាប់ថ្នាក់លេខ៣៥ ក្នុងចំណោម ១២១ប្រទេស និងលំដាប់ថ្នាក់លេខ៣ ក្នុងចំណោម៨ប្រទេស នៅក្នុងសហគមន៍អាស៊ាន ដែលបានបរិច្ចាគកងកម្លាំង ទៅចូលរួមបេសកកម្មរក្សាសន្តិភាពរបស់អង្គការសហប្រជាជាតិ ។ កម្ពុជាក៏បានដើរតួនាទីសំខាន់ក្នុងការ ចូលរួមធានានូវសន្តិភាព និងសន្តិសុខពិភពលោកតាមរយៈការចូលជាភាគីនៃសន្ធិសញ្ញា និងពិធីសារអន្តរជាតិជាច្រើន ។

សមិទ្ធផលទាំងអស់នេះ គឺបានមកដោយសារប្រទេសជាតិមានសុខសន្តិភាព ។ សុខសន្តិភាពរបស់ប្រទេសជាតិ និងការរស់នៅប្រកបដោយភាពសុខក្សេមក្សាន្តរបស់ប្រជាជន គឺជាអាទិភាពខ្ពស់បំផុតសម្រាប់រាជ-រដ្ឋាភិបាលកម្ពុជាដោយគ្មានយកអ្វីមកទិញដូរបាន និងមិនអាចយកអ្វីមកជំនួសបានឡើយ ។ ចងចាំជានិច្ចនូវស្មារតី៧មករា ប្រជាជនកម្ពុជាទូទាំងប្រទេសរួមគ្នាថែរក្សាឲ្យបាននូវសន្តិភាព ការពារឲ្យបាននូវអធិបតេយ្យជាតិ ទប់ស្កាត់រាល់ឧបាយកល វាយបំបាក់ឲ្យបរាជ័យរាល់ការប៉ុនប៉ងតាមគ្រប់រូបភាព ក្នុងគោលបំណងរុញច្រានប្រទេសជាតិយើងឲ្យធ្លាក់ក្នុងស្ថានភាពវឹកវរ និងអស្ថិរភាពជាថ្មីម្ដងទៀត ។ ខិតខំពង្រឹងឲ្យបានផ្លូវសាមគ្គីភាពឯកភាពជាតិ លើកតម្កល់ខ្ពស់ផលប្រយោជន៍របស់ប្រជាជន ធ្វើអំពើល្អជាមួយប្រជាជន បន្តពង្រឹងឧត្តមភាពរបស់គណបក្ស បន្តបណ្ដុះស្មារតី៧មករា ឲ្យនៅតែមានសកម្មភាពរស់រវើកក្នុងសរសៃឈាមរបស់យើងទាំងអស់គ្នា ក្នុងដំណើរឆ្ពោះទៅដណ្ដើមជោគជ័យកាន់តែធំធេងក្នុងការបោះឆ្នោតជ្រើសតាំងព្រឹទ្ធសភា និងការបោះឆ្នោតរដ្ឋសភា នៅឆ្នាំ២០១៨នេះ ៕

**ទស្សនាវដ្ដីប្រជាជន**

to another through the Royal Government's policy of salary increment to over one million Riel in 2018. Hundreds of thousands of workers and employees working in private sector have also grabbed chances of increasing their incomes, whose minimum salary will reach 170 USD in 2018, including yet other advantages provided by the Royal Government's social protection policy. The Royal Government of Cambodia issues stringently basic measures and necessary policies aimed at resolving difficulties, concerns, and responding to aspirations of people in the whole country, and those challenging social and economic issues of our nation.

While achieving such economic progress, Cambodia has also made efforts to raise high democracy based on principle of rule of law, through consecutive, legal and Constitutional national and sub-national elections, while adhering steadfastly to a universal principle of respect of human rights. Cambodia is resolutely against interference of internal affairs, instigation, and racism - disguised under democracy and respect of human rights - that can bring about violence, rebellion, and breaking of national solidarity, only to serve political interest of traitors and foreign circles who wish to remove legal Royal Government and pushed Cambodia into flame of color revolution war.

Coincidentally, prestige of the Kingdom of Cambodia has been raised high in the international arena, in which Cambodia has been playing active roles with other states and international communities to seek peace for countries in conflict under the framework of cooperation with the United Nations. Cambodia ranked 35th among 125 nations, and third among eight countries in ASEAN, by the United Nations, in provision of troops for the UN peacekeeping operations. Cambodia played significant role in guaranteeing world peace and security by becoming a party to many international treaties and protocols.

These achievements have been real because of our country is in peace. The country's peace and peaceful life of our people is the highest priority for the Royal Government of Cambodia. It is not tradable and/or replaceable. We remember always the spirit of 7 January and the Cambodian people in the whole country unite to keep peace, to defend national sovereignty, to prevent ploys, and to foil attempts of all forms to push the country into havoc and instability once again.

We will strengthen our strand of solidarity, national unity, raise high people's interest, exercise actions of merit with people, continue to strengthen supremacy of the Party, and enliven the spirit of 7-Janaury in everyone on our march towards greater elections of the Senate and the National Assembly in 2018./.

*THE PRACHEACHUN MAGAZINE*

# ជីវភាពសង្គមនៅកម្ពុជា ដំណើរការជាប្រក្រតី និងកាន់តែធានាបានប្រសិទ្ធភាពខ្ពស់

លទ្ធិប្រជាធិបតេយ្យនៅកម្ពុជា បាននឹងកំពុងតែចាក់ឫសទៅក្នុង សង្គមជាតិ និងមានជំហានលូតលាស់យ៉ាងខ្លាំងតាមរយៈកិច្ចខិតខំ ប្រឹងប្រែងរបស់រាជរដ្ឋាភិបាលកម្ពុជា ក្រោមការដឹកនាំរបស់សម្ដេច តេជោ **ហ៊ុន សែន** ស្របទៅតាមស្មារតីនៃរដ្ឋធម្មនុញ្ញដែលជាច្បាប់ កំពូលរបស់កម្ពុជា ។ កន្លងទៅនេះ មជ្ឈដ្ឋានបរទេសមួយចំនួន បានខិតខំប្រឹងប្រែងបង្អាក់ដំណើរការ នៃការអនុវត្តលទ្ធិប្រជាធិបតេយ្យ សេរី ពហុបក្ស នៅប្រទេសកម្ពុជា តាមរយៈការប្រើប្រាស់ កម្លាំងខាងក្នុង ដែលជាអ្នកនយោបាយប្រឆាំងផ្កាប់មុខឲ្យធ្វើ សកម្មភាពបដិវត្តន៍ពណ៌ ដើម្បីផ្ដួលរំលំរាជរដ្ឋាភិបាលស្របច្បាប់ ។ ឧបាយកលដ៏ថោកទាបនេះត្រូវបានរាជរដ្ឋាភិបាលវាយឲ្យបរាជ័យ ជីកគាស់រំលើងដល់ឫសគល់ ឈានទៅរលត់រលាយទាំងស្រុង ។ ប៉ុន្តែប្រឈមមុខនឹងការបរាជ័យដ៏ធ្ងន់ធ្ងរនេះ ពួកបរទេសដែលជា ចៅហ្វាយ និងជនក្បត់ជាតិនៅតែបន្តសកម្មភាពដ៏ពិសពុលរបស់ ខ្លួន ដោយបើកសមរភូមិនៅក្រៅប្រទេស ឃោសនាមួលបង្កាច់ និង កៀងគរបក្សពួកវាយប្រហារមកលើរាជរដ្ឋាភិបាលកម្ពុជារហូតចោទ ប្រកាន់ទាំងបំពានថា ប្រជាធិបតេយ្យនៅកម្ពុជាបានស្លាប់បាត់ទៅ ហើយ ឬក៏ថាកំពុងធ្វើដំណើរថយក្រោយ ។ ពួកនេះថែមទាំងហ៊ាន ដាក់លក្ខខណ្ឌបង្គាប់បញ្ជាឲ្យដោះលែងជនក្បត់ជាតិ កឹម សុខា ការ អនុញ្ញាតិឲ្យគណបក្សសង្គ្រោះជាតិធ្វើសកម្មភាពឡើងវិញ ដោយ មិនបានសិក្សាទៅលើអង្គហេតុ និងអង្គច្បាប់ឲ្យបានច្បាស់លាស់ ដែលទង្វើនេះគឺជាការជ្រៀតជ្រែកចូលកិច្ចការផ្ទៃក្នុងរបស់ប្រទេស កម្ពុជា ជាការរំលោភទៅលើគោលការណ៍ឯករាជ្យជាតិ និងរដ្ឋអធិបតេយ្យយ៉ាងធ្ងន់ធ្ងរបំផុត ។

បច្ចុប្បន្ននេះការអនុវត្តលទ្ធិប្រជាធិបតេយ្យ សេរី ពហុបក្ស នៅ តែមានដំណើរការជាធម្មតា។ កម្ពុជាបានត្រៀមខ្លួនរួចរាល់ហើយ ស្រេចសម្រាប់ការបោះឆ្នោតជ្រើសតាំងសមាជិកព្រឹទ្ធសភា នៅ ថ្ងៃទី២៥ ខែកុម្ភៈ និងការបោះឆ្នោតរដ្ឋសភា នៅថ្ងៃទី២៩ ខែកក្កដា ឆ្នាំ២០១៨ ។ ដំណើរការចុះបញ្ជីគណបក្សនយោបាយឈរឈ្មោះ បោះឆ្នោត និងបេក្ខជនឈរឈ្មោះបោះឆ្នោតព្រឹទ្ធសភា នីតិកាល ទី៤ បានបញ្ចប់កាលពីថ្ងៃទី១២ ធ្នូ កន្លងទៅ ដោយមានគណបក្ស នយោបាយចំនួន៤ បានដាក់ពាក្យស្នើសុំប្រកួតប្រជែង ។ ចំណែក ស្ថាប័នរដ្ឋសភាកំពុងតែបន្តនិរន្តរភាពការងារជាប្រក្រតី ។ អនុវត្ត តាមច្បាប់ស្តីពីគណបក្សនយោបាយ គ.ជ.ប បានប្រកាសពីការ បែងចែកអាសនៈក្រុមប្រឹក្សារាជធានី ខេត្ត និងក្រុមប្រឹក្សាក្រុង ស្រុក ខណ្ឌ ក្រុមប្រឹក្សាឃុំ សង្កាត់ ព្រមទាំងអាសនៈរដ្ឋសភាដែល នៅទំនេរក្រោយពីគណបក្សសង្គ្រោះជាតិត្រូវបានរំលាយ ។ រចនា សម្ព័ន្ធថ្មីនៃថ្នាក់ដឹកនាំរដ្ឋសភា បានរៀបចំធ្វើការបែងចែកស្របតាម នីតិវិធី ហើយបាននឹងកំពុងបំពេញការងារជាស្ថាប័ននីតិបញ្ញត្តិប្រកប ដោយប្រសិទ្ធភាពខ្ពស់ ។ សមាជិករដ្ឋសភាថ្មី និងសមាជិកក្រុម ប្រឹក្សារាជធានី ខេត្ត ក្រុង ស្រុក ខណ្ឌ ឃុំ សង្កាត់ បានបំពេញភារកិច្ច របស់ខ្លួនក្នុងការបម្រើប្រជាជនជាធម្មតា ។ គណៈកម្មាធិការជាតិ រៀបចំការបោះឆ្នោត (គ.ជ.ប) ក៏បានបំពេញភារកិច្ចយ៉ាងត្រឹមត្រូវ ទៅតាមប្រតិទិននៃការងាររបស់ខ្លួន ។ រាជរដ្ឋាភិបាលកម្ពុជាដែល ជាស្ថាប័ននីតិប្រតិបត្តិកំពុងអនុវត្តការដឹកនាំលើគ្រប់វិស័យទាំងអស់ ទាំងសេដ្ឋកិច្ច សង្គមកិច្ច ការពារជាតិ និងកិច្ចការបរទេស ប្រកបដោយ ជោគជ័យជាមួយនឹងសមិទ្ធផលធំៗជាច្រើន និងទទួលបានការគាំទ្រ យ៉ាងខ្លាំងពីសំណាក់ប្រជាជនកម្ពុជាទូទាំងប្រទេស ធ្វើឲ្យជីវភាព សង្គមដំណើរការជាប្រក្រតី ។ បច្ចុប្បន្ននេះនៅកម្ពុជាមានគណបក្ស នយោបាយចំនួន៣៥ បានចុះបញ្ជី និងត្រៀមប្រកួតប្រជែងក្នុងការ បោះឆ្នោតក្នុងឆ្នាំ២០១៨ ។ ការបង្កើតគណបក្សនយោបាយថ្មីមិន ត្រូវបានហាមឃាត់ ឬរឹតត្បិតនោះទេ ។ អង្គការសង្គមស៊ីវិលជាង ៣០០០ ប្រព័ន្ធផ្សព្វផ្សាយជាតិ និងបរទេសរាប់ពាន់ កំពុងធ្វើ សកម្មភាពដោយសេរី ដោយគ្មានការហាមឃាត់ ដែលបង្ហាញឲ្យ ឃើញថា រាជរដ្ឋាភិបាលបានបើកទូលាយសេរីភាពសារព័ត៌មាន នៅកម្ពុជា ហើយវិស័យនេះ កំពុងមានការរីកចម្រើនយ៉ាងឆាប់ រហ័ស ។

ដូច្នេះអ្វីទៅដែលហៅថា ការស្លាប់បាត់បង់នៃលទ្ធិប្រជាធិបតេយ្យ សេរី ពហុបក្ស នៅកម្ពុជា? អ្វីទៅ ដែលហៅថា នៅកម្ពុជាលទ្ធិប្រជាធិបតេយ្យកំពុងដើរថយក្រោយ? តើវាតម្រូវឲ្យទាល់តែមាន គណបក្សនយោបាយមួយដឹកនាំដោយជនក្បត់ជាតិ ដោយមាន ជនបរទេសជាចៅហ្វាយញាក់ខ្សែពីក្រោយប្រព្រឹត្តិសកម្មភាព ដែល ផ្ទុយទៅនឹងរដ្ឋធម្មនុញ្ញ ធ្វើទង្វើល្មើសច្បាប់ បង្កឲ្យមានអសន្តិសុខ និងចលាចលធ្វើឲ្យបែកបាក់ផ្ទៃក្នុងជាតិទើបហៅថា ប្រជាធិបតេយ្យ? សូមកុំយកដំណើរការអនុវត្តប្រជាធិបតេយ្យដែលកំពុងតែ មានសកម្មភាពរស់រវើកមកធ្វើជាចំណាប់ខ្មាំងរបស់បុគ្គលណា ឬ គណបក្សនយោបាយណាមួយឲ្យសោះ ។ សូមកុំយកអាយុជីវិត ប្រជាជនកម្ពុជាមកធ្វើជាល្បែងនយោបាយ និងសូមកុំនាំយកទឹកដី កម្ពុជាឲ្យធ្លាក់ចូលទៅក្នុងភ្នក់ភ្លើងសង្គ្រាមសារជាថ្មីទៀត។ប្រជាជន កម្ពុជាមានការប្ដេជ្ញាចិត្តខ្ពស់ក្នុងការកសាងមាតុភូមិរបស់ខ្លួន ស្រប តាមស្មារតីរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា ផ្អែកលើប្រព័ន្ធ ប្រជាធិបតេយ្យ សេរី ពហុបក្ស ធានាសិទ្ធមនុស្ស គោរពច្បាប់ ទទួលខុសត្រូវចំពោះវាសនាអនាគតជាតិ ឲ្យបានឈានឡើងរីក ចម្រើនលូតលាស់សម្បូររុងរឿងជានិច្ចនិរន្ត ។ យើងប្ដេជ្ញាដាច់ខាត ការពារឯករាជ្យជាតិ អធិបតេយ្យជាតិ រាំងខ្ទប់ដាច់ខាតការជ្រៀត ជ្រែកចូលកិច្ចការផ្ទៃក្នុងរបស់កម្ពុជា និងគាំទ្ររាជរដ្ឋាភិបាលកម្ពុជា ដែលមាន**សម្ដេចតេជោ ហ៊ុន សែន** ជាប្រមុខក្នុងការបន្តបំពេញ បេសកកម្មដ៏ឧត្ដុង្គឧត្ដម ដើម្បីសន្តិភាព និងការអភិវឌ្ឍមាតុភូមិ យើងតអង្វែងរៀងទៅ ៕

# ផ្លែផ្កានៃដំណើរទស្សនកិច្ចរបស់លោកជំទាវ សេខ្វ ហាស៊ីណា នាយករដ្ឋមន្ត្រី បង់ក្លាដេស នៅកម្ពុជា




*សម្តេចអគ្គមហាសេនាបតីតេជោ **ហ៊ុន សែន** នាយករដ្ឋមន្ត្រីនៃព្រះរាជាណាចក្រកម្ពុជា និង លោកជំទាវ **សេខ្វ ហាស៊ីណា** នាយករដ្ឋមន្ត្រីបង់ក្លាដេស អញ្ជើញជាអធិបតីក្នុងពិធីចុះហត្ថលេខាលើឯកសារចំនួន ១១*



*សម្តេចវិបុលសេនាភក្តី **សាយ ឈុំ** ប្រធានព្រឹទ្ធសភានៃព្រះរាជាណាចក្រកម្ពុជា ទទួលជួបសន្ទនាជាមួយ លោកជំទាវ **សេខ្វ ហាស៊ីណា** នាយករដ្ឋមន្ត្រីនៃសាធារណរដ្ឋប្រជាមានិតបង់ក្លាដេស*

លោកជំទាវ **សេខ្វ ហាស៊ីណា** (Sheikh Hasina) នាយករដ្ឋមន្ត្រីនៃសាធារណរដ្ឋប្រជាមានិតបង់ក្លាដេស បានអញ្ជើញមកបំពេញទស្សនៈកិច្ចនៅព្រះរាជាណាចក្រកម្ពុជា ចាប់ពីថ្ងៃទី ៣-៥ ខែធ្នូ ឆ្នាំ២០១៧ ក្នុងគោលបំណងរឹតចំណងមិត្តភាព និងកិច្ចសហប្រតិបត្តិការរវាងប្រទេសទាំងពីរឲ្យកាន់តែរឹងមាំ ។ ក្នុងឱកាសស្នាក់នៅរាជធានីភ្នំពេញ លោកជំទាវ **សេខ្វ ហាស៊ីណា** បានអញ្ជើញចូលក្រាបបង្គំគាល់ **ព្រះករុណា ព្រះបាទសម្តេចព្រះបរមនាថ នរោត្តម សីហមុនី ព្រះមហាក្សត្រ** នៃព្រះរាជាណាចក្រកម្ពុជាផងដែរ។ ព្រះករុណាបានរំឭកអំពីសម្ព័ន្ធភាពជិតស្និទ្ធពិសេសរបស់អតីតព្រះមហាក្សត្រកម្ពុជា ចំពោះបិតាជាតិរបស់បង់ក្លាដេស **បង់ហ្គាបាន់ឌូ សេខ្វ មូជីប៊ូ រ៉ាម៉ាន់** ព្រមទាំងអរគុណចំពោះការកោតសរសើររបស់ប្រជាជន បង់ក្លាដេស ចំពោះអតីតព្រះមហាក្សត្រកម្ពុជា **នរោត្តម សីហនុ** ។ ក្នុងន័យនេះ ព្រះអង្គ បានស្វាគមន៍ការប្រកាសរបស់នាយករដ្ឋមន្ត្រីប្រទេសទាំងពីរ អំពីការដាក់ឈ្មោះផ្លូវសំខាន់មួយនៃប្រទេសរៀងខ្លួនក្នុងរាជធានីភ្នំពេញ និងរដ្ឋធានីដាកា ដើម្បីជានិមិត្តរូបនៃការគោរពថ្នាក់ដឹកនាំដ៏ឆ្នើមទាំងពីរ ។

ក្នុងជំនួបពិភាក្សាការងារជាមួយ **សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន** នាយករដ្ឋមន្ត្រីនៃព្រះរាជាណាចក្រកម្ពុជានៅវិមានសន្តិភាពកាលពីព្រឹកថ្ងៃទី៤ ខែធ្នូ ឆ្នាំ២០១៧ លោកជំទាវ **សេខ្វ ហាស៊ីណា** នាយករដ្ឋមន្ត្រីបង់ក្លាដេស បានថ្លែង កោតសរសើរថា កម្ពុជាគឺជាមិត្តដ៏ជិតស្និទ្ធហើយមានទស្សនៈរួមគ្នាកសាងសន្តិភាពនៅក្នុងតំបន់និងពិភពលោក ។ ប្រមុខរដ្ឋាភិបាលនៃប្រទេសកម្ពុជា និងបង់ក្លាដេសបានប្តេជ្ញាចិត្តរួមគ្នា ដើម្បីលើកកម្ពស់ទំនាក់ទំនងប្រទេសទាំងពីរឲ្យដល់កម្រិតថ្មីមួយទៀត ។ ភាគីទាំងពីរបានឯកភាពរៀបចំកិច្ចប្រជុំគណៈកម្មការចម្រុះលើកទី១ ដឹកនាំដោយរដ្ឋមន្ត្រីក្រសួងការបរទេសនៃប្រទេសទាំងពីរ នៅទីក្រុង ដាកា និងបានសម្រេចចិត្តរៀបចំកិច្ចប្រជុំលើកទី១ នៃគណៈកម្មាធិការពាណិជ្ជកម្មរួម ហៅថា (JTC) ដែលដឹកនាំដោយរដ្ឋមន្ត្រីក្រសួងពាណិជ្ជកម្មនៃប្រទេសទាំងពីរនៅឆ្នាំក្រោយ ។ មេដឹកនាំទាំងពីរក៏បានឯកភាពគ្នាជ្រើសរើសផ្លូវនៅក្នុងរាជធានីភ្នំពេញ និងនៅទីក្រុងដាកា ដើម្បីដាក់ព្រះនាមរបស់ព្រះបិតាជាតិរបស់កម្ពុជា ព្រះករុណា ព្រះបរមរតនកោដ្ឋ និងបិតាជាតិរបស់បង់ក្លាដែស ដែលនេះជានិមិត្តរូបនៃសាមគ្គីភាពរវាងប្រទេសយើងទាំងពីរ ។ សម្តេចតេជោបានថ្លែងថា កម្ពុជាបានផ្តល់នូវការគាំទ្រភ្លាមៗជាមួយសំណូមពររបស់បង់ក្លាដេស នៅក្នុងការរៀបចំបង្កើតឲ្យក្លាយទៅជាដៃគូសន្ទនាតាមវិស័យរបស់អាស៊ាន ហើយកម្ពុជានឹងបន្តធ្វើការជាមួយនឹងដៃគូអាស៊ាន ដើម្បីសម្រេចទៅដល់ការព្រមព្រៀង ។ កម្ពុជា ក៏បានផ្តល់នូវការគាំទ្រជាមួយនឹងភាពជាដៃគូនៅក្នុងមេគង្គ-គង្គា ហើយសម្តេចនឹងធ្វើកិច្ចការនេះជាមួយនាយករដ្ឋមន្ត្រីឥណ្ឌានៅខែមករា ឆ្នាំក្រោយ ព្រមទាំងធ្វើកិច្ចការនេះជាមួយនឹងដៃគូក្នុងមេគង្គផងដែរ ដើម្បីឲ្យបង់ក្លាដេសមានលទ្ធភាពចូលរួមក្នុងក្របខណ្ឌជាដៃគូរវាងមេគង្គ-គង្គា ។ សម្តេចតេជោបានបន្តទៀតថា យើងក៏បានពិភាក្សាទាក់ទងជាមួយ នឹងជនភៀសខ្លួនយ៉ាងច្រើនដែលជាបន្ទុកដ៏ធ្ងន់ធ្ងររបស់បង់ក្លាដេស ហើយយើងវាយតម្លៃខ្ពស់ចំពោះបង់ក្លាដេស បើទោះបីប្រជាជនមានទៅដល់ ១៦០លាននាក់ ក៏នៅទទួលចិញ្ចឹម ប្រជាជនប្រមាណ ១លាននាក់ ថែមទៀតដែលភៀសខ្លួនចេញពីមីយ៉ាន់ម៉ា ។ យើងក៏ពិចារណារួមគ្នា ដើម្បីធ្វើឱ្យមានឡើងនូវមាតុភូមិនិវត្ត ហើយសង្ឃឹមថាភាគីទាំងពីរបង់ក្លាដេស និងមីយ៉ាន់ម៉ារកឃើញនូវដំណោះស្រាយដែលអាច



***សម្ដេចអគ្គមហាពញាចក្រី ហេង សំរិន** ប្រធានរដ្ឋសភា នៃព្រះរាជាណាចក្រកម្ពុជាទទួលជួបសវនាការ និងពិភាក្សាការងារ ជាមួយលោកជំទាវ **សេក្ខ ហាស៊ីណា** នាយករដ្ឋមន្ត្រី នៃសាធារណរដ្ឋប្រជាមានិតបង់ក្លាដែស*

ឲ្យប្រជាជនវិលត្រលប់ទៅកាន់មាតុភូមិវិញ ។ សម្ដេចតេជោបាន អរគុណចំពោះលោកជំទាវ ដែលបានអញ្ជើញសម្ដេចទៅទស្សនកិច្ចនៅបង់ក្លាដេសសារជាថ្មីម្ដងទៀត សម្ដេចសូមទទួលយកនូវការអញ្ជើញនេះដោយការពេញចិត្ត ។ ចំណែកលោកជំទាវនាយករដ្ឋមន្ត្រីបង់ក្លាដេសបានមានប្រសាសន៍ថា ប្រទេសទាំងពីរមានបំណងប្រាថ្នារួមគ្នា ដើម្បីលើកកម្ពស់សន្តិភាព សន្តិសុខ និងការអភិវឌ្ឍ ។ ប្រជាជនទាំងពីរបង់ក្លាដេស និងកម្ពុជាមានប្រពៃណីបូរាណដូចគ្នា ។ ទស្សនកិច្ចរបស់លោកជំទាវមកកម្ពុជាមានផ្លែផ្កាយ៉ាងជ្រាលជ្រៅបំផុត ។ **សម្ដេចតេជោ ហ៊ុន សែន** និងលោកជំទាវមានការប្ដេជ្ញាចិត្ត ដើម្បីលើកកម្ពស់ទំនាក់ទំនងបង់ក្លាដេស និងកម្ពុជាឲ្យដល់កម្រិតថ្មីមួយ និងទំហំថ្មីមួយទៀត ។ លោកជំទាវបានកោតសរសើរ**សម្ដេចតេជោនាយករដ្ឋមន្ត្រី ហ៊ុន សែន** ដែលបានដឹកនាំឲ្យមានកំណើនសេដ្ឋកិច្ចដ៏រឹងមាំ និងការអភិវឌ្ឍនៅកម្ពុជា ។ លោកជំទាវមានការរីករាយ ដែលបានទទួលនូវការធានារបស់សម្ដេចតេជោនូវការគាំទ្រដល់ភាពជាដៃគូសន្ទនាតាមវិស័យរបស់បង់ក្លាដេសនៅក្នុងអាស៊ាន ហើយក្នុងនាមជាប្រទេសគង្គា ។ បង់ក្លាដេសទន្ទឹងរង់ចាំធ្វើការជិតស្និទ្ធជាមួយកម្ពុជា សំដៅឆ្ពោះទៅសម្រេចបំណងប្រាថ្នាសហប្រតិបត្តិការមេគង្គ-គង្គា ។ ឯកសារចំនួន១១ ដែលទាក់ទងទៅនិងទំនាក់ទំនងទ្វេភាគីសហប្រតិបត្តិលើវិស័យសេដ្ឋកិច្ចសង្គម ការងារបណ្ដុះបណ្ដាលត្រូវបានចុះហត្ថលេខាបន្ទាប់ពីជំនួបទ្វេភាគីរវាងលោកជំទាវនាយករដ្ឋមន្ត្រីបង់ក្លាដេស និង**សម្ដេចតេជោ ហ៊ុន សែន** នាយករដ្ឋមន្ត្រីនៃកម្ពុជា។

នៅថ្ងៃទី៤ ខែធ្នូ **សម្ដេចវិបុលសេនាភក្ដី សាយ ឈុំ** ប្រធានព្រឹទ្ធសភានៃព្រះរាជាណាចក្រកម្ពុជា បានទទួលជួបសន្ទនាជាមួយលោកជំទាវ **សេក្ខ ហាស៊ីណា** នាយករដ្ឋមន្ត្រីនៃសាធារណរដ្ឋប្រជាមានិតបង់ក្លាដេស ។ សម្ដេចប្រធានព្រឹទ្ធសភាបានរំលឹកអំពីទំនាក់ទំនងមិត្តភាពការទូតកម្ពុជា-បង់ក្លាដេស ដែលបង្កើតឡើងដោយស្នាព្រះហស្ថ **ព្រះករុណា ព្រះបាទសម្ដេច ព្រះនរោត្តម សីហនុ "ព្រះបរមរតនកោដ្ឋ"** ជាមួយនឹងបិតាជាតិរបស់បង់ក្លាដេស ឯកឧត្តម **បង់ហ្គាបាន់ឌូ សេក មូជីប៊ួរ៉ាម៉ាន់** ។ ទំនាក់ទំនងមិត្តភាពជាប្រពៃណីនេះ ត្រូវបានពង្រឹងពង្រីកជាបន្តបន្ទាប់ ដោយថ្នាក់ដឹកនាំជំនាន់ក្រោយក្នុងគោលដៅដើម្បីផលប្រយោជន៍រួមរបស់ប្រទេសទាំងពីរ ។ ក្នុងនាមព្រឹទ្ធសភាកម្ពុជា សម្ដេចភក្ដីបានសម្ដែងនូវការគាំទ្រ និងលើកទឹកចិត្តឱ្យរដ្ឋាភិបាលទាំងពីរជំរុញឲ្យស្ថាប័ន ដែលមានការពាក់ព័ន្ធអនុវត្តនូវកិច្ចព្រមព្រៀង និងអនុស្សារណៈយោគយល់គ្នារវាងប្រទេសទាំងពីរឱ្យកាន់តែស៊ីជម្រៅ ព្រមទាំងរៀបចំព្រឹត្តិការណ៍ពិព័រណ៍ពាណិជ្ជកម្មដើម្បីជាគុណប្រយោជន៍ ដល់ការពង្រីក ការផ្លាស់ប្ដូរពាណិជ្ជកម្មរវាងប្រទេសទាំងពីរឱ្យកាន់តែរីកចម្រើនថែមទៀត ។ ចំពោះការអញ្ជើញសម្ដេចទៅបំពេញទស្សនកិច្ចនៅសាធារណរដ្ឋប្រជាមានិតបង់ក្លាដេស សម្ដេចប្រធានព្រឹទ្ធសភាបានថ្លែងអំណរគុណ និងសន្យារកពេលវេលាសមស្របណាមួយ ដើម្បីឆ្លើយតបនឹងសេចក្ដីអញ្ជើញនេះ ។ លោកជំទាវ **សេក្ខ ហាស៊ីណា** បានថ្លែងអំណរគុណចំពោះសម្ដេចភក្ដីប្រធាន ព្រឹទ្ធសភា ដែលបានចំណាយពេលវេលាដ៏មានតម្លៃទទួលជួបគណៈប្រតិភូនាឱកាសនេះ ។ លោកជំទាវនាយករដ្ឋមន្ត្រីបាន បញ្ជាក់ពីសារៈសំខាន់នៃទំនាក់ទំនងមិត្តភាព និងកិច្ចសហប្រតិបត្តិការរវាងប្រទេសទាំងពីរ ដែលមានលក្ខណៈស្រដៀងគ្នា និងបទពិសោធន៍នៃការកសាងលទ្ធិប្រជាធិបតេយ្យ និងការអភិវឌ្ឍ ស្រដៀងគ្នា ។ លោកជំទាវ **សេក្ខ ហាស៊ីណា** សង្ឃឹមយ៉ាងមុតមាំថា ទំនាក់ទំនង និងកិច្ចសហប្រតិបត្តិការរវាងសភានៃប្រទេសទាំងពីរ នឹងកាន់តែ ប្រសើរឡើងថែមទៀត តាមរយៈការផ្លាស់ប្ដូរដំណើរទស្សនកិច្ចគ្នាទៅវិញទៅមក ដើម្បីចែករំលែកបទពិសោធន៍ និងទស្សនទាននានា ។

**សម្ដេចអគ្គមហាពញាចក្រី ហេង សំរិន** ប្រធានរដ្ឋសភានៃព្រះរាជាណាចក្រកម្ពុជាក៏បានទទួលជួបសវនាការ និងពិភាក្សាការងារទ្វេភាគីជាមួយលោកជំទាវ **សេក្ខ ហាស៊ីណា** នាយករដ្ឋមន្ត្រីនៃសាធារណរដ្ឋប្រជាមានិតបង់ក្លាដែសផងដែរ ។ សម្ដេចចក្រីបានចាត់ទុកដំណើរទស្សនកិច្ច របស់លោកជំទាវនាយករដ្ឋមន្ត្រីបង់ក្លាដេស មកកាន់កម្ពុជានា ពេលនេះថា ជាការផ្ដល់នូវកិត្តិយសដ៏ធំធេងសម្រាប់ប្រជាជន និងប្រទេសកម្ពុជា និងជាការជំរុញឲ្យទំនាក់ទំនង និងកិច្ចសហប្រតិបត្តិការរវាងប្រទេសជាតិទាំងពីរកាន់តែប្រសើរឡើងបន្ថែមទៀត ។ ជា ការឆ្លើយតបលោកជំទាវ **សេក្ខ ហាស៊ីណា** បានគូសបញ្ជាក់ថា ដំណើរទស្សនកិច្ចរបស់លោកជំទាវ គឺដើម្បីបង្ខិតប្រទេសទាំងពីរ កម្ពុជា-បង់ក្លាដេស ឲ្យកាន់តែខិតជិតគ្នា ព្រមទាំងមានកិច្ចសហប្រតិបត្តិការកាន់តែប្រសើរជាងមុនទាំងក្នុងស្ថាប័ននីតិប្បញ្ញត្តិទាំងក្នុងស្ថាប័ននីតិប្រតិបត្តិនៃប្រទេសទាំងពីរ ។ លោកជំទាវក៏បាន ជម្រាបជូនសម្ដេចចក្រីថា តាមរយៈដំណើរទស្សនកិច្ចជាផ្លូវការនេះរាជរដ្ឋាភិបាលកម្ពុជា និងរដ្ឋាភិបាលបង់ក្លាដេសបានចុះហត្ថលេខាលើឯកសារចំនួន ១១ ដែលនេះ គឺជាផ្លែផ្កាថ្មីនៃការពូនជ្រុំកិច្ចសហប្រតិបត្តិការទ្វេភាគីរវាងកម្ពុជា និងបង់ក្លាដេសដែលប្រទេសយើងទាំងពីរធ្លាប់មានប្រវត្តិសាស្ត្រប្រហាក់ប្រហែលគ្នា ឬដូចគ្នា តែម្ដងពោលគឺកម្ពុជា និងបង់ក្លាដែសសុទ្ធតែធ្លាប់ជួបប្រទះដូចគ្នា នូវអំពើប្រល័យពូជសាសន៍ និងកលយុគនៃសង្គ្រាមហែកហួរជា ដើម ។

ក្នុងឱកាសស្នាក់នៅរាជធានីភ្នំពេញ លោកជំទាវ **សេក្ខ ហាស៊ីណា** ក៏បានអញ្ជើញចូលរួមក្នុងវេទិកាធុរកិច្ចកម្ពុជាបង់ក្លាដេស ដោយមានការចូលរួមពីមន្ត្រីពាក់ព័ន្ធ និងថ្នាក់ដឹកនាំសភាពាណិជ្ជកម្មនៃប្រទេសទាំងពីរផងដែរ ៕

# សម្តេចតេជោ ហ៊ុន សែន អញ្ជើញចូលរួមក្នុងកិច្ចប្រជុំជាន់ខ្ពស់នៃបក្សកុម្មុយនីស្តចិនសន្ទនាជាមួយគណបក្សនយោបាយនៅលើពិភពលោក

✵ សម្តេចតេជោ គឺជាមិត្តចាស់ មិត្តពិតប្រាកដ និងជាមិត្តគួរជាទីទុកចិត្តរបស់ប្រជាជន និងបក្សកុម្មុយនីស្តចិន

✵ ទោះបស្ចិមប្រទេសចាត់ទុកកម្ពុជាជាអ្វីក៏ដោយ ចិននៅតែគាំទ្រកម្ពុជាដោយគ្មានការងាករេ



*__សម្តេចតេជោ ហ៊ុន សែន__ នាយករដ្ឋមន្ត្រី នៃព្រះរាជាណាចក្រកម្ពុជា ជួបសន្ទនា ការងារជាមួយឯកឧត្តម __ស៊ី ជីនភីង__ អគ្គលេខា នៃគណៈកម្មាធិការមជ្ឈឹមបក្សកុម្មុយនីស្តចិន*



*__សម្តេចតេជោ ហ៊ុន សែន__ នាយករដ្ឋមន្ត្រីនៃព្រះរាជាណាចក្រកម្ពុជា អញ្ជើញថ្លែងសុន្ទរកថា គន្លឹះក្នុងកិច្ចប្រជុំជាន់ខ្ពស់នៃបក្សកុម្មុយនិស្តចិន សន្ទនាជាមួយគណបក្សនយោបាយនៅលើពិភពលោក*

ពីថ្ងៃទី២៩ ខែវិច្ឆិកា ដល់ថ្ងៃទី២ ខែធ្នូ ឆ្នាំ២០១៧ តបតាមការអញ្ជើញរបស់ឯកឧត្តម **ស៊ី ជីនភីង** អគ្គលេខានៃគណៈកម្មាធិការមជ្ឈឹមបក្សកុម្មុយនីសចិន និងជាប្រធានាធិបតីនៃសាធារណរដ្ឋប្រជាមានិតចិន **សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន** ប្រធានគណបក្សប្រជាជនកម្ពុជា និងជានាយករដ្ឋមន្ត្រីនៃព្រះរាជាណាចក្រកម្ពុជា បានដឹកនាំគណៈប្រតិភូជាន់ខ្ពស់អញ្ជើញចូលរួមក្នុងកិច្ចសន្ទនាជាន់ខ្ពស់រវាងបក្សកុម្មុយនីស្តចិន ជាមួយគណបក្សនានាជុំវិញពិភពលោក ។ ជាមួយគ្នានេះ សម្តេចតេជោក៏បានជួបពិភាក្សាការងារជាមួយបណ្តាមេដឹកនាំចិនសំខាន់ៗនិងអ្នកវិនិយោគទុនចិនធំៗមួយចំនួនទៀត ដើម្បីកៀរគរការបណ្តាក់ទុននៅកម្ពុជាឲ្យបានច្រើនថែមទៀត ខណៈដែលកម្ពុជាកំពុងជំរុញគោលនយោបាយអភិវឌ្ឍន៍វិស័យឧស្សាហកម្មឆ្នាំ២០១៥-២០២៥ ឲ្យទទួលបានជោគជ័យ ។

នៅថ្ងៃទី១ ខែធ្នូ **សម្តេចតេជោ ហ៊ុន សែន** បានជួបសន្ទនាការងារជាមួយឯកឧត្តម **ស៊ី ជីនភីង** អគ្គលេខានៃគណៈកម្មាធិការមជ្ឈឹមបក្សកុម្មុយនីស្តិចិន ដែលក្នុងឱកាសនោះឯកឧត្តមបានមានប្រសាសន៍ថា សម្តេចតេជោគឺជាមិត្តចាស់ មិត្តពិតប្រាកដ និងជាមិត្តគួរជាទីទុកចិត្តរបស់ប្រជាជន និងបក្សកុម្មុយនីស្តចិន។បច្ចុប្បន្ននេះ ទំនាក់ទំនងនៃប្រទេសទាំងពីរកម្ពុជា-ចិន មានភាពល្អប្រសើរជាងពេលណាៗទាំងអស់ ។ មិនតែប៉ុណ្ណោះភាគីទាំងពីរនៅតែបន្តពង្រឹងទំនាក់ទំនងរវាងប្រជាជន និងប្រជាជនគ្មានពេលឈប់ ពោលគឺជាទំនាក់ទំនងពិតសម្រាប់ប្រជាជននៃប្រទេសទាំងពីរ ដែលថ្នាក់ដឹកនាំនៃប្រទេសទាំងពីរមានការគាំទ្រគ្នាទៅវិញទៅមក ។ ដោយសារឆ្នាំ២០១៨ គឺជាខួប ៦០ឆ្នាំនៃការបង្កើតទំនាក់ទំនងការទូតរបស់ប្រទេសទាំងពីរ ភាគីទាំងពីរបានសន្យារួមគ្នាហើយថា និងពង្រឹងទំនាក់ទំនងកិច្ចសហប្រតិបត្តិការនៃប្រទេសទាំងពីរឲ្យកាន់តែរឹងមាំថែមទៀត ។ **សម្តេចតេជោ ហ៊ុន សែន** ប្រធានគណបក្សប្រជាជនកម្ពុជា និងជានាយករដ្ឋមន្ត្រីនៃព្រះរាជាណាចក្រកម្ពុជា មានប្រសាសន៍ថា សម្តេចពិតជាមានការសប្បាយរីករាយ ដោយបានជួបឯកឧត្តមប្រធានាធិបតីសាជាថ្មីម្តងទៀត នៅទីក្រុងប៉េកាំង ។ សម្តេចតេជោ បានសម្តែងការអបអរសាទរជូនចំពោះឯកឧត្តម **ស៊ី ជីនភីង** ដែលត្រូវបានអង្គមហាសន្និបាតបក្សកុម្មុយនីស្តចិនលើកទី១៩ បោះឆ្នោតជ្រើសតាំងជាអគ្គលេខានៃគណៈកម្មាធិការមជ្ឈឹមបក្សកុម្មុយនីស្តិចិនសាជាថ្មីម្តងទៀត ។ ក្នុងជំនួបពិភាក្សាគ្នានោះ សម្តេចតេជោបានស្នើដល់ឯកឧត្តមប្រធានាធិបតី ធ្វើយ៉ាងណាជំរុញការសាងសង់ផ្លូវល្បឿនលឿនភ្នំពេញក្រុងព្រះសីហនុឲ្យបានចេញជារូបរាង ដោយសារវាឆ្លើយតបទៅនឹងចក្ខុវិស័យ ផ្លូវមួយខ្សែក្រវាត់មួយ របស់ឯកឧត្តមប្រធានាធិបតី និងជាប៉ូលសេដ្ឋកិច្ចរបស់ប្រទេសកម្ពុជា ។ សម្តេចតេជោក៏បានស្នើដល់ឯកឧត្តមប្រធានាធិបតី ជួយដល់អង្គការសង្គមស៊ីវិល និងផ្នែកផ្សេងៗទៀតរបស់ប្រទេសកម្ពុជា ។ ឯកឧត្តមប្រធានា ធិបតីចិនមានប្រសាសន៍ថា អ្វីដែលឯកឧត្តមចង់ឮពីសម្តេច គឺសន្តិភាព និងស្ថេរភាពនយោបាយរបស់ប្រទេសកម្ពុជា ។ នៅប្រទេសចិនបានកំណត់ថា អ្នកដែលឲ្យគុណមកយើង យើងត្រូវតែសងគុណទៅគេវិញ ពោលគឺ យើងនឹងកសាងសហគមន៍ដែលមានវាសនារួមគ្នាជាមួយនឹងប្រទេសកម្ពុជា ។ ឯកឧត្តម **ស៊ី ជីនភីង** បានថ្លែងបន្តថា បើទោះបស្ចិមប្រទេសចាត់ទុកកម្ពុជាជាអ្វីក៏ដោយ ក៏ចិនបានប្រកាសរួចហើយថា ចិននឹងបន្តជួយគាំទ្រដោយគ្មានការងាករេដល់ប្រទេស

កម្ពុជា ពិសេសគាំទ្រដល់**សម្ដេចតេជោ ហ៊ុន សែន** ក្នុងការបន្តដឹកនាំរាជរដ្ឋាភិបាល និងគណបក្សប្រជាជនកម្ពុជាតទៅមុខទៀត ។ ជាមួយគ្នានេះមេដឹកនាំចិនបានសន្យាបញ្ជូនអ្នកឯកទេសរបស់ខ្លួនក្នុងការជួយដល់ប្រទេសកម្ពុជា ពិសេសការជំរុញក្រុមហ៊ុនចិនទៅបណ្ដាក់ទុន នៅកម្ពុជាឲ្យកាន់តែច្រើនឡើងថែមទៀត ។

នៅថ្ងៃទី១ ខែធ្នូ ឆ្នាំ២០១៧ **សម្ដេចតេជោ ហ៊ុន សែន** បានអញ្ជើញចូលរួមក្នុងកិច្ចប្រជុំជាន់ខ្ពស់នៃបក្សកុម្មុយនីស្តចិនសន្ទនាជាមួយគណបក្សនយោបាយនៅលើពិភពលោកក្រោមប្រធានបទ: «រួមគ្នាកសាង សហគមន៍នៃអនាគតរួមសម្រាប់មនុស្សជាតិ និងពិភពលោកស្រស់ស្អាត» ។ នៅក្នុងកិច្ចប្រជុំនោះ សម្ដេចតេជោបានថ្លែងសុន្ទរកថាគន្លឹះដោយបញ្ជាក់ថា៖ **យើងត្រូវតែគោរពអធិបតីភាព និងជម្រើសផ្លូវដើររបស់ ប្រទេសដោយខ្លួនឯង មិនថាប្រទេសនោះធំ ឬតូច ខ្លាំង ឬ ខ្សោយ នោះទេ ។ ប្រទេសទាំងអស់ត្រូវតែប្រកាន់ខ្ជាប់នូវគោលការណ៍មិនជ្រៀតជ្រែកកិច្ចការផ្ទៃក្នុងផងគ្នា និងត្រូវគោរពសិទ្ធរបស់ប្រទេសដទៃ ក្នុងការជ្រើសរើសប្រព័ន្ធគ្រប់គ្រង និងមាគ៌ាអភិវឌ្ឍន៍ឯករាជ្យ និងគ្មានការរំខាន ។ អ្វីដែលល្អសម្រាប់ប្រទេសមួយមិនប្រាកដថា ល្អសម្រាប់ប្រទេសផ្សេងទៀតនោះទេ ដោយសារតែលក្ខណៈពិសេសដោយឡែកផ្សេងគ្នារបស់ ប្រទេសនីមួយៗនៅក្នុងគ្រប់ទិដ្ឋភាពនៃជីវភាពសង្គម ។ សម្ដេចតេជោ ហ៊ុន សែន** បានថ្លែងទៀតថា៖ បទពិសោធន៍នៃការអភិវឌ្ឍនយោបាយរបស់កម្ពុជា នៅក្នុងយុគសម័យនៃប្រវត្តិសាស្ត្រទំនើបរបស់ពិភពលោក គឺនៅមានលក្ខណៈក្មេងខ្ចីនៅឡើយ។ ប៉ុន្តែយើងកំពុងរៀនសូត្រយ៉ាងឆាប់រហ័សសំដៅពង្រឹង **«លទ្ធិប្រជាធិបតេយ្យប្រជាជន»** របស់កម្ពុជាឲ្យមានភាពរស់រវើក និងរឹងមាំ ។ តម្លៃស្នូលនៃ **«លទ្ធិប្រជាធិបតេយ្យប្រជាជន»** របស់យើងគឺៈ ទី១-ការប្តូរបេជ្ញាលើកកម្ពស់ និងការធានានូវការគោរពសិទ្ធិស្វ័យសម្រេចរបស់ប្រជាជាតិកម្ពុជា នៅក្នុងអធិបតេយ្យភាព និងបូរណភាពទឹកដីដ៏ពេញលេញរបស់ខ្លួនដោយគ្មានការជ្រៀតជ្រែក និងរំលោភបំពានពីខាងក្រៅ ទី២-ការធានារក្សាឲ្យបានដាច់ខាតនូវសន្តិភាព ស្ថេរភាព និងភាពសុខដុមរមនាសង្គម ដែលជាបុព្វល័ក្ខខ័ណ្ឌមិនអាចខ្វះបានសម្រាប់ការអភិវឌ្ឍប្រទេស ក៏ដូចជាសម្រាប់ភាពក្សេមក្សាន្តរបស់ប្រជាជាតិ និងសម្រាប់ជីវភាពរស់នៅថ្លៃថ្នូរសមរម្យរបស់ប្រជាជន ទី៣- ការគោរពប្រតិបត្តិយ៉ាងខ្ជាប់ខ្ជួនឥតងាករេនូវគោលការណ៍នីតិរដ្ឋ និងប្រព័ន្ធនយោបាយសេរីពហុបក្ស ដែលក្នុងនេះប្រជាពលរដ្ឋមានសិទ្ធិសេរីភាពគ្រប់យ៉ាងដ៏ពេញលេញ នៅក្រោមវិធាននៃច្បាប់ជាពិសេសសិទ្ធិក្នុងការជ្រើសរើសអ្នកដឹកនាំប្រទេស តាមរយៈការបោះឆ្នោតជាទៀងទាត់និងដោយសេរីត្រឹមត្រូវ និងយុត្តិធម៌ និងទី៤-ការប្ដេជ្ញាអភិវឌ្ឍស្ថាប័នរដ្ឋ ដោយឈរលើគោលការណ៍ប្រតិតុល្យភាព អភិបាលកិច្ចល្អ និងគុណធិបតេយ្យ ឲ្យក្លាយជាឧបករណ៍ប្រកបដោយប្រសិទ្ធភាព សក្តិសិទ្ធភាព និងពោរពេញដោយសមត្ថភាពសម្រាប់បម្រើប្រទេសជាតិ និងប្រជាជនកម្ពុជាគ្រប់ស្រទាប់ជាន់ថ្នាក់ ។

ដោយឡែក នៅក្នុងពិធិលៀងសាយភោជន៍ជាមហាកិត្តិយសជូន**សម្ដេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន** ប្រធានគណបក្សប្រជាជនកម្ពុជា និងជានាយករដ្ឋមន្ត្រីនៃព្រះរាជាណាចក្រកម្ពុជា ឯកឧត្តម **សុខ ចាន់** រដ្ឋមន្ត្រីក្រសួងទំនាក់ទំនងអន្តរជាតិនៃគណៈកម្មាធិការមជ្ឈឹមបក្សកុម្មុយនីស្ដចិន មានប្រសាសន៍ ថា ថ្នាក់ដឹកនាំកំពូលៗ នៃគណៈកម្មាធិការមជ្ឈឹមបក្សកុម្មុយនីស្តចិនធ្វើជាខ្នងបង្អែកដ៏រឹងមាំសម្រាប់សម្ដេចតេជោ ក្នុងការបន្តដឹកនាំរាជរដ្ឋាភិបាល និងប្រទេសកម្ពុជារយៈពេលយូរអង្វែងតទៅមុខទៀត ។ ឯកឧត្តមរដ្ឋមន្ត្រីក៏បានចាត់ទុកថា វត្តមានរបស់**សម្ដេចតេជោ ហ៊ុន សែន** ដែលបានអញ្ជើញមកកាន់ប្រទេសចិននៅពេលនេះ គឺជាការផ្ដល់នូវមហាកិត្តិយសដ៏ខ្ពង់ខ្ពស់បំផុតចំពោះបក្សរដ្ឋ និងប្រជាជនចិន ក្នុងការពង្រីកនូវកាលានុវត្តភាពរបស់ខ្លួនលើការកសាងនិងអភិវឌ្ឍសេដ្ឋកិច្ច សង្គម ឲ្យកាន់តែរឹងមាំថែមទៀត។ ឯកឧត្តមរដ្ឋមន្ត្រីក៏បានវាយតម្លៃខ្ពស់ និងកោតសរសើរចំពោះកំណើនសេដ្ឋកិច្ចរបស់ប្រទេសកម្ពុជា ក្រោមការដឹកនាំប្រកបដោយកិត្តិបណ្ឌិតរបស់សម្ដេចតេជោនាយករដ្ឋមន្ត្រីក្នុងការពង្រឹងសន្តិភាព សន្តិសុខ ស្ថេរភាពនយោបាយ និងការអភិវឌ្ឍសេដ្ឋកិច្ច សង្គមមានការរីកចម្រើនលើគ្រប់វិស័យ ដែលនោះបានបង្ហាញឲ្យឃើញពីប្រៀបឈ្នះក្នុងនាមជាមេដឹកនាំកំពូលមួយរូបដែលមានបញ្ញាញាណឈ្លាសវៃ និងប៉ិនប្រសព្វបំផុត ។ **សម្ដេចតេជោ ហ៊ុន សែន** បានថ្លែងនូវអំណរគុណជូនចំពោះបក្សរដ្ឋនិងប្រជាជនចិនដែលតែងតែគាំទ្រផ្ដល់នូវការជួយឧបត្ថម្ភគ្រប់បែបយ៉ាង ក្នុងការជួយដល់ដំណើរការស្តារ និងអភិវឌ្ឍន៍ប្រទេសកម្ពុជាឡើងវិញ ។ សម្ដេចតេជោក៏បានចាត់ទុកថា ការគាំទ្ររបស់ប្រទេសចិន គឺពិតជាមានអត្ថន័យ មិនត្រឹមតែបានរួមចំណែកជួយដល់ការជំរុញកំណើនសេដ្ឋកិច្ចជាតិ ប៉ុណ្ណោះទេ គឺបានរួមចំណែកផងដែរដល់ការពង្រឹងឯករាជ្យភាព និងការខ្ពង់ខ្ពស់មុខមាត់របស់ប្រទេសកម្ពុជាលើឆាកអន្តរជាតិផងដែរ ។

**សម្ដេចតេជោ ហ៊ុន សែន** ក៏បានអនុញ្ញាតឲ្យថ្នាក់ដឹកនាំក្រុមហ៊ុនធំៗចំនួន ៣របស់ប្រទេសចិន ដែលកំពុងធ្វើការវិនិយោគក្នុងប្រទេសកម្ពុជា ក្នុងនោះរួមមាន ក្រុមហ៊ុន China Road & Bridge Corporation ក្រុមហ៊ុន Henan Transport Investment Group និងក្រុមហ៊ុន Greenland Holding Group ចូលជួបសំដែងការគួរសមពិសេស ដើម្បីស្វែងរកឱកាសវិនិយោគបន្ថែមទៀតក្នុង ប្រទេសកម្ពុជា ។ ក្នុងជំនួបពិភាក្សាគ្នានោះ លោកប្រធានក្រុមហ៊ុនទាំងនោះ បានរាយការណ៍ជូនសម្ដេចតេជោពីគម្រោង ៤ ដែលក្រុមហ៊ុនបាននិងកំពុងអនុវត្តន៍ក្នុងប្រទេសកម្ពុជាតាមរយៈការសាងសង់ស្ពាន ផ្លូវ និងហេដ្ឋារចនាសម្ព័ន្ធផ្សេងៗទៀត ។ លោកប្រធានក្រុមហ៊ុនក៏បានជម្រាបជូនសម្ដេចតេជោដែរថាគម្រោងទាំង ៤ដែលក្រុមហ៊ុនរបស់លោកបានលើកឡើងនេះ គឺក្រុមហ៊ុននឹងខិតខំរៀបចំបែបបទឲ្យបានហើយរួចរាល់ ដើម្បីឈានទៅចុះហត្ថលេខាលើកិច្ចព្រមព្រៀងក្នុងដំណើរទស្សនកិច្ចផ្លូវការ របស់ឯកឧត្តមនាយករដ្ឋមន្ត្រីចិន **លី ខឺឈាំង** ដែលនឹងអញ្ជើញមកចូលរួមកិច្ចប្រជុំកំពូលមេគង្គ-ឡាងឆាន ក្នុងប្រទេសកម្ពុជានាខែមករា ឆ្នាំ២០១៨ ដែលស្របគ្នា និងខួប៦០ ឆ្នាំនៃថ្ងៃបង្កើតទំនាក់ទំនងការទូតនៃប្រទេសទាំងពីរ កម្ពុជា-ចិន ។

ការអញ្ជើញចូលរួមរបស់**សម្ដេចតេជោ ហ៊ុន សែន** ក្នុងកិច្ចប្រជុំនេះ និងជំនួបរបស់សម្ដេចតេជោជាមួយថ្នាក់ដឹកនាំជាន់ខ្ពស់ចិន បានផ្ដល់សារៈសំខាន់យ៉ាងខ្លាំងនោះគឺ ជាការបង្ហាញវត្តមានរបស់ប្រទេសកម្ពុជាបន្ថែមទៀតនៅលើផែនទីពិភពលោក ហើយក៏ជាការពង្រឹងនយោបាយការបរទេសរបស់កម្ពុជា ជាមួយបណ្ដាប្រទេសនៅលើពិភពលោក និងជំរុញប្រទេសកម្ពុជាទៅក្នុងកិច្ចសហប្រតិបត្តិការកាន់តែប្រសើរឡើង លើវិស័យសេដ្ឋកិច្ច ៕

# ពិធីបួងសួងសុំសេចក្តីសុខចម្រើនដល់ព្រះរាជាណាចក្រកម្ពុជានៅមុខប្រាសាទអង្គរវត្ត



***សម្តេចតេជោ ហ៊ុន សែន** និង**សម្តេចកិត្តិព្រឹទ្ធបណ្ឌិត ប៊ុន រ៉ានី ហ៊ុន សែន** អញ្ជើញចូលរួមក្នុង*
*ពិធីបួងសួងសុំសេចក្តីចម្រើនជូនដល់ព្រះរាជាណាចក្រកម្ពុជា នៅមុខប្រាសាទអង្គរវត្ត*

រាជរដ្ឋាភិបាលកម្ពុជា បានរៀបចំពិធីបួងសួងសុំសេចក្តីសុខជូនដល់ព្រះរាជាណាចក្រកម្ពុជា នៅមុខប្រាសាទអង្គរវត្ត ខេត្តសៀមរាប នៅថ្ងៃទី២-៣ ខែធ្នូ ឆ្នាំ២០១៧ ក្រោមអធិបតីភាពដ៏ខ្ពង់ខ្ពស់ **សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន** នាយករដ្ឋមន្ត្រី នៃព្រះរាជាណាចក្រកម្ពុជា និង**សម្តេចកិត្តិព្រឹទ្ធបណ្ឌិត ប៊ុន រ៉ានី ហ៊ុន សែន** ។ ពិធីនេះក៏ជួនគ្នានឹងពេលវេលា ដែលប្រជាជនកម្ពុជា យើងទូទាំងប្រទេសចូលរួមអបអរសាទរខួបអនុស្សាវរីយ៍លើកទី៣៩ ទិវាបង្កើតរណសិរ្សសាមគ្គីសង្គ្រោះជាតិកម្ពុជា (២ ធ្នូ ១៩៧៨ - ២ ធ្នូ ២០១៧) បច្ចុប្បន្នមានឈ្មោះថា រណសិរ្សសាមគ្គីអភិវឌ្ឍន៍មាតុភូមិកម្ពុជា ដែលជាចលនាតស៊ូរំដោះ... ផ្តួលរំលំរបបប្រល័យពូជសាសន៍នាថ្ងៃទី៧ ខែមករា ឆ្នាំ១៩៧៩ ។

នៅរសៀលថ្ងៃទី២ ខែធ្នូ នេះ នៅមុខប្រាសាទអង្គរវត្ត **សម្តេចតេជោ ហ៊ុន សែន** និង**សម្តេចកិត្តិព្រឹទ្ធបណ្ឌិត ប៊ុន រ៉ានី ហ៊ុន សែន** បានអញ្ជើញចូលរួមពិធីក្រុងពាលីតាមប្រពៃណី និងទំនៀមទម្លាប់នៃព្រះពុទ្ធសាសនា ដែលនៅក្នុងពិធីនោះក៏មានការចូលរួមរបស់មន្ត្រីរាជរដ្ឋាភិបាល និងសមាជិក សមាជិកា រដ្ឋសភា ព្រឹទ្ធសភាផងដែរ ។ បន្ទាប់ពីពិធីក្រុងពាលី **សម្តេចតេជោ ហ៊ុន សែន** និងសម្តេចកិត្តិព្រឹទ្ធបណ្ឌិត បានអញ្ជើញចូលរួមក្នុងពិធីសូត្រមន្តចម្រើនព្រះបរិត្តដែលមានព្រះសង្ឃចំនួន៥០០អង្គនៅមុខប្រាសាទអង្គរវត្ត ។

នៅព្រឹកថ្ងៃទី០៣ ខែធ្នូ ឆ្នាំ២០១៧ **សម្តេចតេជោ ហ៊ុន សែន** និង**សម្តេចកិត្តិព្រឹទ្ធបណ្ឌិត ប៊ុន រ៉ានី ហ៊ុនសែន** បានអញ្ជើញរាប់បាត្រប្រគេនព្រះសង្ឃចំនួន ៥.១២០អង្គ ដើម្បីបួងសួងសុំសេចក្តីចម្រើនជូនដល់ព្រះរាជាណាចក្រកម្ពុជា នៅមុខប្រាសាទអង្គរវត្ត ដែលពិធីនេះមានការយាងនិមន្ត និងចូលរួមពីសម្តេចព្រះមហាសង្ឃរាជទាំងពីរគណៈ សម្តេចព្រះសង្ឃក្នុងឋានានុក្រម មន្ត្រីរាជរដ្ឋាភិបាល សិស្សានុសិស្ស និងប្រជាពលរដ្ឋជាច្រើនកុះករផងដែរ ។ បន្ទាប់ពី**សម្តេចតេជោ ហ៊ុន សែន** បូជាទៀន ធូប និងថ្វាយភួងផ្កាភ្ញីនៅវានអាសនៈរួចមក ពិធីបួងសួងបានប្រព្រឹត្តទៅតាមគន្លងប្រពៃណីទំនៀមទម្លាប់ ។ សម្តេចតេជោ សម្តេចកិត្តិព្រឹទ្ធបណ្ឌិត អ្នកឧកញ៉ា ឯកឧត្តម លោកជំទាវ អស់លោក លោកស្រី លោកអាចារ្យបានធ្វើពិធីឧទ្ទិសបួងសួងសូមព្រះបារមីដ៏ស័ក្តិសិទ្ធិ ដែលគង់ប្រថាប់ថែរក្សានៅលើទឹកដីអង្គរ ក៏ដូចជានៅក្នុងកម្ពុជរដ្ឋទាំងមូល ព្រមទាំងបារមីព្រះអង្គចេកព្រះអង្គចម លោកយាយទេព តាដំបងដែក លោកតារាជ ព្រះអង្គតូច ព្រះអង្គធំគង់នៅខ្នងភ្នំគូលែន និងបារមីអារុក្ខអារក្ស អ្នកតាគ្រប់ទិសទី និង





*ពិធីបួងសួងសូមឲ្យបារមីស័ក្ដិសិទ្ធិជួយថែរក្សាព្រះរាជាណាចក្រកម្ពុជា បានជួបតែសុខសន្តិភាព និងមានការអភិវឌ្ឍរីកចម្រើនតទៅអនាគត*

ទេវតាគង់ថែរក្សា នៅតាមប្រាង្គប្រាសាទនានានៅលើទឹកដីដ៏ស័ក្តិសិទ្ធិតាមជួយថែរក្សាព្រះរាជាណាចក្រកម្ពុជាឲ្យជួបតែសេចក្តីសុខចម្រើនតរៀងទៅ ។ ពិធីបុណ្យនេះជាការសម្តែងនូវភារៈជាអ្នកគោរពដឹងគុណ និងធ្វើបដិការកិច្ចចំពោះបុព្វបុរសរបស់យើងទាំងអស់គ្នា សូមជួយឱ្យព្រះរាជាណាចក្រកម្ពុជា បានជួបតែសុខសន្តិភាព និងមានការអភិវឌ្ឍរីកចម្រើនតទៅអនាគត ។

ឯកឧត្តម **ថោង ខុន** រដ្ឋមន្ត្រីក្រសួងទេសចរណ៍បានឲ្យដឹងថា៖ នេះគឺជាពិធីប្រពៃណីមួយដែលអតីតមេដឹកនាំ និងមេដឹកនាំជំនាន់មុនរបស់យើងបានរៀបចំជារៀងរាល់ឆ្នាំ ដែលត្រូវធ្វើការអធិស្ឋានឱ្យប្រទេសជាតិមានសន្តិភាពការអភិវឌ្ឍ និងប្រជាពលរដ្ឋមានជីវភាពកាន់តែប្រសើរឡើង ។ សន្តិភាពគឺជាគ្រឹះដ៏រឹងមាំបំផុតសម្រាប់ការអភិវឌ្ឍប្រទេស ។ ឯកឧត្តមរដ្ឋមន្ត្រីបានបន្តទៀតថា៖ ចំនួនភ្ញៀវទេសចរមកកាន់អង្គរវត្តបន្តកើនឡើង ដែលបង្ហាញពីទំនុកចិត្តរបស់អ្នកវិនិយោគ និងទេសចរណ៍នៅក្នុងប្រទេសកម្ពុជា ។ ប្រទេសមួយដែលមានអ្នកទេសចរ និងវិនិយោគិនមកច្រើននោះ គឺជាប្រទេសដែលមានសន្តិភាពនិងមានស្ថិរភាពនយោបាយ ដែលមានន័យថាប្រទេសនេះមានទំនុកចិត្តពីបណ្តាប្រទេសដទៃទៀត ។ តាមការប៉ាន់ប្រមាណគិតត្រឹមដំណាច់ឆ្នាំ២០១៧ ភ្ញៀវទេសចរជាង ៥,៦លាននាក់ នឹងមកទស្សនាប្រទេសកម្ពុជាជាភស្តុតាងបង្ហាញថា កម្ពុជាពិតជាមានសុខសន្តិភាពពេញលេញ ។

គួរបញ្ជាក់ថា បានជារាជរដ្ឋាភិបាលជ្រើសរើសប្រាសាទអង្គរវត្តជាទីតាំងសម្រាប់រៀបចំពិធីសាសនាដ៏ធំបែបនេះ គឺដោយសារពីអតីតកាល ព្រះរាជាខ្មែរ និងមន្ត្រីធំៗក្នុងរាជការ សុទ្ធសឹងធ្លាប់បានរៀបចំពិធីបួងសួងបែបនេះនៅទីដ៏ពិសិទ្ធ និងជាទីសក្ការៈនេះដែរ ។ ក្នុងជំនាន់ព្រះករុណាព្រះបាទសម្តេច ព្រះបរមរតនកោដ្ឋ ព្រះអង្គក៏ធ្លាប់បានរៀបចំពិធីបួងសួងដ៏ធំមួយនៅអង្គរវត្ត ក្រោយទទួលបានឯករាជ្យជាតិពីអាណានិគមនិយមបារាំង ។ បច្ចុប្បន្ននេះរមណីយដ្ឋានអង្គរនៅតែបន្តល្បីល្បាញក្រោមដំបូលសុខសន្តិភាព និងការអភិវឌ្ឍនៅកម្ពុជា ។ តាំងពីឆ្នាំ១៩៩៨ ជាពេលដែលកម្ពុជាទទួលបានសន្តិភាពពេញលេញលើផ្ទៃប្រទេស ក្រោមនយោបាយឈ្នះ-ឈ្នះរបស់ប្រមុខរាជរដ្ឋាភិបាលកម្ពុជា **សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន** នាយករដ្ឋមន្ត្រីនៃព្រះរាជាណាចក្រកម្ពុជា បានធ្វើឲ្យកិត្តិសព្ទអង្គរខ្ចរខ្ចាយកាន់តែខ្លាំងទៅកាន់ឆាកអន្តរជាតិ ។ ក្រោមដំបូលសន្តិភាព និងស្ថិរភាពនយោបាយនេះរមណីយដ្ឋានអង្គរក៏កំពុងតែបន្តភាពល្បីល្បាញ និងកាន់តែទាក់ទាញភ្ញៀវទេសចរជាតិ និងអន្តរជាតិកាន់តែច្រើនឡើងៗ ឥតឈប់ឈរពីមួយថ្ងៃទៅមួយថ្ងៃ និងទទួលបានការវាយតម្លៃជាប់ចំណាត់ថ្នាក់លេខ ១ជាប់គ្នាពីស្ថាប័នវាយតម្លៃធំៗលើពិភពលោកដូចជា Archaeo Madness, Trip Advisor, Lonely Planet ជាដើម ។ ការទាក់ទាញភ្ញៀវទេសចរមកកាន់រមណីយដ្ឋានអង្គរទាំងអស់នេះ ក្រៅពីភាពល្បីល្បាញនៃភាពអស្ចារ្យរបស់ប្រាសាទអង្គរ ក៏នៅមានកត្តាដ៏សំខាន់មួយទៀត ដែលយើងមិនអាចបំភ្លេចបាននោះគឺ សន្តិភាព និងស្ថិរភាពនយោបាយដែលរាជរដ្ឋាភិបាលកម្ពុជាបានពុះពារដណ្តើមមកបាន និងកំពុងតែបន្តរក្សាដោយប្រុងប្រយ័ត្នបំផុត ។ នេះក៏ជាមោទនភាពជាតិមួយដែលកូនខ្មែរគ្រប់រូបត្រូវយល់ដឹង និងចូលរួមថែរក្សាទាំងអស់គ្នា ពោលគឺ ថែរក្សាទាំងស្នាដៃបុព្វបុរសដែលបានបន្សល់ទុក និងចូលរួមថែរក្សានូវសមិទ្ធផលដែលថ្នាក់ដឹកនាំកម្ពុជា បច្ចុប្បន្នបានប្រឹងប្រែងកសាងមកឲ្យបានគង់វង្សយូរអង្វែង ។

នៅក្នុងពិធីនោះ ក៏មានការប្រគុំតន្ត្រីនៅមុខប្រសាទអង្គរវត្តទន្ទឹម នឹងនេះដែរ ក៏មានកម្មវិធីរត់ប្រណាំងពាក់កណ្តាលម៉ារ៉ាតុងអន្តរជាតិអង្គរលើកទី២២ ដោយមានភ្ញៀវទេសចរជាតិនិងអន្តរជាតិប្រមាណ ១០.០០០នាក់ មកពី ៧៦ប្រទេស ចូលរួមអបអរសាទរ ក្នុងពិធីដ៏អធិកអធមនេះទៀតផង ៕



*ពិធីសម្តែងរបាំបួងសួងសុំសេចក្តីសុខនៅមុខប្រាសាទអង្គរវត្ត*

# សម្តេចតេជោ ហ៊ុន សែន ៖ ប្រជាធិបតេយ្យដែលគ្មានការគ្រប់គ្រងដោយច្បាប់ គឺអនាធិបតេយ្យ

- ❋ មានវត្តមាន ហ៊ុន សែន នៅទីនេះ សូមកុំបារម្ភពីសង្គ្រាមកើតឡើងឲ្យសោះ
- ❋ ប្រជាធិបតេយ្យ សេរី ពហុបក្ស មិនក្លាយជាចំណាប់ខ្មាំងរបស់អ្នកណាមួយទេ
- ❋ ប្រជាជនកម្ពុជាបានត្រៀមរួចរាល់ហើយ សម្រាប់ការបោះឆ្នោត



*សម្តេចតេជោ ហ៊ុន សែន អញ្ជើញជួបសំណេះសំណាលជាមួយ កម្មករ កម្មការិនី និយោជិត ក្នុងបរិយាកាសរីករាយក្រៃលែង*

ក្នុងខែធ្នូ ឆ្នាំ២០១៧ **សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន** នាយករដ្ឋមន្ត្រីនៃព្រះរាជាណាចក្រកម្ពុជាបានអញ្ជើញជួបសំណេះសំណាលជាមួយ កម្មករ កម្មការិនី និយោជិត កីឡាករ កីឡាការិនី ព្រមទាំងបញ្ចុះបឋមសិលាកសាងសមិទ្ធផលមួយចំនួន ។ សម្តេចតេជោបានថ្លែងសារនយោបាយ និងបានបកស្រាយបញ្ហាមួយចំនួនដែលទាក់ទងនឹងព្រឹត្តិការណ៍នយោបាយថ្មីៗនៅកម្ពុជា ។

ព្រឹកថ្ងៃទី៦ ខែធ្នូ **សម្តេចតេជោ ហ៊ុន សែន** បានបន្តជួបជាមួយ កម្មករ និយោជិត ចំនួន១៥.៧៤២នាក់ នៅតំបន់អូរដឹម ផ្លូវជាតិលេខ៤ ខណ្ឌពោធិសែនជ័យ រាជធានីភ្នំពេញ ។ ក្នុងឱកាសនោះ សម្តេចតេជោបានថ្លែងទាក់ទងទៅ នឹងការទទួលយកជនជាតិខ្មែរ ដែលអាមេរិកគ្រោងនឹងបញ្ជូនមកវិញ ដោយសម្តេចបានបញ្ជាក់ថា៖ «ក្នុងឋានៈជានាយករដ្ឋមន្ត្រីនៃព្រះរាជាណាចក្រកម្ពុជា ខ្ញុំសូមប្រកាសទទួលយកបងប្អូនត្រឡប់មកកម្ពុជាវិញ មិនឲ្យគេធ្វើបាបឡើយ״ ។ ជាមួយនឹងការប្រកាសដូចនេះសម្តេចតេជោក៏បានបញ្ជាឲ្យក្រសួងមហាផ្ទៃ ក្រសួងការបរទេស និងស្ថាប័នពាក់ព័ន្ធដទៃទៀត ធ្វើការចរចាជាមួយអាមេរិកក្នុងករណីដឹកជញ្ជូនពលរដ្ឋខ្មែរមកវិញ និងការផ្គត់ផ្គង់ជីវភាពដល់ពួកគេ ។ សម្តេចតេជោក៏បានស្នើអាមេរិកពិចារណាផ្តល់ជំនួយក្នុងកម្រិតណាមួយ ដើម្បីឲ្យពលរដ្ឋខ្មែរអាចរស់នៅបានក្នុងប្រទេសកម្ពុជា ក្នុងពេលពួកគេត្រូវបញ្ជូនមកក្នុងដំណាក់កាលដំបូងៗ ។

ទាក់ទងទៅនឹងសេចក្តីអំពាវនាវរបស់ទណ្ឌិត សម រង្ស៊ី ដែលញុះញង់ឲ្យកងកម្លាំងប្រដាប់អាវុធប្រឆាំងនឹងរាជរដ្ឋាភិបាលស្របច្បាប់ ។ សម្តេចតេជោ បានលើកជាសំណួរថា៖ «បើសិនជាកងទ័ពបះបោរ តើអ្វីនឹងកើតឡើង? សុំផ្តាំទៅជនក្បត់ជាតិឯងថា អ្នកឯងស្គាល់សភាពការណ៍កម្ពុជាតិចពេកហើយ។ អ្នកឯងស្គាល់កម្លាំងប្រដាប់អាវុធនៅកម្ពុជាតិចពេកហើយ ។ អ្នកឯងស្គាល់ប្រជាជនកម្ពុជាតិចពេកហើយ។ ប្រជាជនកម្ពុជាបើទោះបីនៅលំបាក ក៏ប៉ុន្តែប្រជាជាតិមួយនេះ ស្រឡាញ់សន្តិភាពនឹងមិនលុះទៅដោយអំពើញុះញង់អកុសលរបស់អ្នកទេ ។ ឥឡូវសាកល្បងគិតមើល ប្រសិនបើមានការបះបោរដោយកងទ័ពណាមួយ សង្គ្រាមវានឹងផ្ទុះ ។ តើអ្នកទាំងអស់គ្នាបានទទួលផលអ្វីទៀត״ ។

សម្តេចតេជោបន្ថែមថា លទ្ធិប្រជាធិបតេយ្យ និងការអភិវឌ្ឍវាមិនចាប់ផ្តើមក្នុងផ្ទៃនៃសង្គ្រាមនោះទេ គឺវាចាប់ផ្តើមនៅក្នុងផ្ទៃនៃសន្តិភាពតែប៉ុណ្ណោះ ។ សូមមើលអតីតកាលរបស់យើង ។ វេទនាណាស់ទម្រាំមានឱកាសដូចសព្វថ្ងៃនេះ ។ រក្សាសន្តិភាពបានទើបរក្សានូវការងាររបស់យើង ។ រក្សាបាននូវស្ថិរភាពនយោបាយ និងសន្តិសុខ សណ្តាប់ធ្នាប់សង្គម បានទើបរក្សាបាននូវរក្សាសុវត្ថិភាព ការងារដែលក្មួយៗមាន ។ សម្តេចតេជោបានសង្កត់ធ្ងន់ថា៖ «នៅពេលដែលមានវត្តមាន ហ៊ុន សែន នៅទីនេះសូមកុំបារម្ភពីសង្គ្រាមកើតឡើងឲ្យសោះ ។ ហ៊ុន សែន រួមជាមួយនឹងថ្នាក់ដឹកនាំនៃគណបក្សប្រជាជនគឺជា អ្នកធានាតែមួយគត់អំពីសន្តិភាព និងការអភិវឌ្ឍនៅក្នុងប្រទេស ។ ព្រោះមនុស្សម្នាក់នេះបានឈរនៅជាបង្គោលជាមួយនឹងថ្នាក់ដឹកនាំដទៃទៀតតាំងពីរំដោះវ៉ៃប៉ុលពត ។ ទប់ស្កាត់ការវិលត្រឡប់នៃរបបប៉ុលពត ស្វែងរកសន្តិភាព និងទប់ស្កាត់នៃសង្គ្រាមដែលគេបង្កមិនចេះចប់មិនចេះហើយ ជាពិសេសទប់ស្កាត់បដិវត្តន៍ពណ៌នៅឆ្នាំ២០១៣ និងដើមឆ្នាំ២០១៤ និងជាបន្តបន្ទាប់មក ។ ដូច្នេះមានវត្តមាន ហ៊ុន សែន គឺមានវត្តមានសន្តិភាព នេះគឺជារឿងពិតមិនមែនជារឿងក្លែងក្លាយហើយលើកខ្លួនឯងនោះទេ״។

❋ ព្រឹកថ្ងៃទី៩ ខែធ្នូ **សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន** នាយករដ្ឋមន្ត្រីនៃព្រះរាជាណាចក្រកម្ពុជា ត្រូវបានតែងតាំងជា «ឯកអគ្គរដ្ឋទូតសុច្ឆន្ទៈពិភពលោកសម្រាប់វិស័យទេសចរណ៍ និងគោលដៅនៃការអភិវឌ្ឍប្រកបដោយចីរភាព״ ។ ស្របពេលគ្នានេះ រាជធានីភ្នំពេញក៏ទទួលបានជ័យលាភី «ជារាជធានីនៃវប្បធម៌ និងទេសចរណ៍ពិភពលោក״ ដែលផ្តល់ដោយលោកសាស្ត្រាចារ្យ **អានតុន ការ៉ាហ្គា** (Anton Caragea) ប្រធានក្រុមប្រឹក្សាទេសចរណ៍ និងពាណិជ្ជកម្មអឺរ៉ុប ។ មានប្រសាសន៍ក្នុងពិធីនេះ សម្តេចតេជោ បញ្ជាក់ថា កម្ពុជាបានកំណត់តម្លៃទេសចរណ៍របស់ខ្លួនជាទេសចរវប្បធម៌ និងធម្មជាតិ។ យើងត្រូវធ្វើកិច្ចការទាំងឡាយ

ដើម្បីអភិរក្សនូវកេរដំណែលប្រវត្តិសាស្រ្ត កុំឲ្យបាត់លក្ខខណ្ឌដែលកំណត់ ដោយអង្គការយូណេស្កូ ។ បើមិនដូច្នោះ អ្វីៗដែលយើងបានដាក់បញ្ចូលជាបេតិកភណ្ឌពិភពលោករួចហើយ អាចនឹងបាត់បង់លក្ខណៈសម្បត្តិរបស់វា ។ សម្តេចតេជោបានអំពាវនាវឲ្យប្រជាជននៅទូទាំងប្រទេស និងការអភិវឌ្ឍក្នុងវិស័យឯកជនទាំងអស់សូមគោរពនូវបទដ្ឋានគតិយុត្តិ ធ្វើយ៉ាងណាកុំឲ្យវិស័យទេសចរណ៍បំពានទៅលើវិស័យវប្បធម៌ ។ ផ្ទុយទៅវិញត្រូវឲ្យវិស័យទេសចរណ៍រីកចម្រើន ដោយយកវិស័យវប្បធម៌ និងធម្មជាតិជាគោលដៅ ។ ធ្វើបាន បែបនេះទើបមាននិរន្តរភាព និងចីរភាពមិនត្រឹមតែ២០៣០ ទេ អាចឈានទៅដល់ឆ្នាំ៣.០០០ ក៏អាចថាបាន ។ ត្រូវប្រឹងប្រែងរួមគ្នាដើម្បីងើបឈរឡើង ដើម្បីដំណើរការទៅអនាគតទាំងអស់គ្នា ។

✵ ថ្ងៃទី១៣ ខែធ្នូ សម្តេចតេជោប្រមុខរាជរដ្ឋាភិបាលកម្ពុជាបានបន្តអញ្ជើញជួបសំណេះសំណាលជាមួយ កម្មករ និយោជិត ចំនួន ១៥.១៣៣នាក់ទៀត មកពីរោងចក្រសហគ្រាសចំនួន១៣ នៅតំបន់កប់ស្រូវ ខណ្ឌពោធិ៍សែនជ័យ រាជធានីភ្នំពេញ ។ នៅទីនោះសម្តេចបានប្រកាសអំពីសេវាសុខភាព សង្គមមួយទៀតចំពោះសមាជិកក្រុមប្រឹក្សាឃុំសង្កាត់ ប្រធានភូមិ អនុប្រធានភូមិ ជំនួយការភូមិ ដែលនឹងទទួលបាននូវការពិនិត្យព្យាបាលជំងឺនៅមន្ទីរពេទ្យរដ្ឋដោយមិនបង់ប្រាក់ ។ សម្តេចតេជោបញ្ជាក់ថា កន្លងទៅរាជរដ្ឋាភិបាល បានដាក់ចេញចំពោះក្របខណ្ឌគោលនយោបាយចំពោះកម្មករ ចំពោះមន្ត្រីរាជការ ស្រ្តីនៅក្នុងជួរកងកម្លាំងប្រដាប់អាវុធ និងមន្ត្រីដែលជាកីឡាររួចហើយ ហើយពេលនេះក្របខណ្ឌគោលនយោបាយនេះ ត្រូវបានពង្រីកវិសាលភាពទៅដល់មន្ត្រីថ្នាក់ឃុំ ថ្នាក់ភូមិ ។ សម្តេចតេជោបន្តថាមន្ត្រីថ្នាក់ឃុំសង្កាត់ និងថ្នាក់ភូមិទាំងអស់មានចំនួនប្រមាណជិតប្រាំមួយម៉ឺននាក់ ដែលក្នុងនោះមានក្រុមប្រឹក្សាឃុំសង្កាត់មានចំនួន ៤៣.១៤៩នាក់ និងប្រធានភូមិ អនុប្រធានភូមិ និងជំនួយការភូមិ មានចំនួន១១.៥៧២នាក់ នឹងត្រូវបានទទួលនូវរបបនៃការពិនិត្យព្យាបាលជំងឺ ដោយឥតគិតថ្លៃពីមន្ទីរពេទ្យរដ្ឋទាំងអស់ដូចកម្មករដែរ ។ សម្រាប់ស្រ្តីនៅថ្នាក់ឃុំ ថ្នាក់ភូមិក៏ទទួលបានអត្ថប្រយោជន៍ដូចកម្មការិនីដែរនៅពេលសម្រាលកូន ។ វិសាលភាពនេះ ត្រូវបានដាក់នៅក្រោមមូលនិធិសមធម៌របស់រាជរដ្ឋាភិបាល ។

**សម្តេចតេជោ ហ៊ុន សែន** ក៏បានថ្លែងផងដែរ ទៅដល់ការព្យួរថវិកាជំនួយរបស់សហភាពអឺរ៉ុប ដល់គណៈកម្មាធិការជាតិរៀបចំការបោះឆ្នោត (គ.ជ.ប.) ។ សម្តេចតេជោបញ្ជាក់ថា រាជរដ្ឋាភិបាលមានលុយគ្រប់គ្រាន់សម្រាប់រៀបចំការបោះឆ្នោតទៅតាមការគ្រោងទុក ។ កម្ពុជាបន្តនូវការអនុវត្តលទ្ធិប្រជាធិបតេយ្យសេរីពហុបក្ស ។ ទោះបីគ្មានការចូលរួមរបស់បក្សប្រឆាំងក៏ដោយ ក៏ការបោះឆ្នោតនៅតែបន្ត ។ លទ្ធិប្រជាធិបតេយ្យ សេរី ពហុបក្ស នឹងមិនក្លាយទៅជាចំណាប់ខ្មាំងរបស់អ្នកណាម្នាក់ទេ ។ សម្តេចតេជោមានប្រសាសន៍ថា យើងត្រូវខិតខំថែទាំសន្តិភាព ដែលយើងរកបានដោយលំបាក ។ ថែទាំជាមួយដំណើរការលទ្ធិប្រជាធិបតេយ្យ សេរីពហុបក្ស ដែលនៅក្នុងឆ្នាំ២០១៨ ខាងមុខយើងនឹងបោះឆ្នោតជ្រើសរើសសមាជិកព្រឹទ្ធសភានៅថ្ងៃទី២៥ ខែកុម្ភៈ និងការបោះឆ្នោតរដ្ឋសភានៅ



*__សម្តេចតេជោ ហ៊ុន សែន__ អញ្ជើញជាអធិបតីដ៏ខ្ពង់ខ្ពស់ក្នុងសម្ពោធដាក់ឱ្យប្រើប្រាស់ពិធីហេដ្ឋារចនាសម្ព័ន្ធអគារហ្វឹកហ្វឺនជំនាញចារកម្ម*

ថ្ងៃទី២៩ ខែកក្កដា ។ នេះជាពេលវេលាដែលយើងត្រូវបន្តជំហានទៅមុខ ជំហានដែលប្រជាជនចង់បាន ។ គ្មានការចូលរួមរបស់អ្នកក៏ការបោះឆ្នោតនៅតែបន្ត ។ សម្តេចតេជោសង្កត់ថា ច្បាប់នៅកម្ពុជារដ្ឋធម្មនុញ្ញនៅកម្ពុជាក៏មិនបានតម្រូវឲ្យទៅចុះហត្ថលេខាពីប្រធានាធិបតីនៃប្រទេសនានា ឬពីអគ្គលេខាធិកាអង្គការសហប្រជាជាតិ ទើបហៅថា ការបោះឆ្នោតស្របច្បាប់នោះដែរ ។ ប្រជាជនចូលរួមបោះឆ្នោត គឺជាការគ្រប់គ្រាន់ ។ ឥឡូវប្រជាជនបានត្រៀមរួចរាល់ហើយសម្រាប់ការបោះឆ្នោត ។ រាជរដ្ឋាភិបាលក៏មានទុនគ្រប់គ្រាន់ដែរសម្រាប់ការរៀបចំការបោះឆ្នោត ។ ដំណើរការនឹងចាប់ផ្តើមតាមការគ្រោងទុក ។ ការបោះឆ្នោតនាពេលខាងមុខមានគណបក្សច្រើននឹងចូលរួមបោះឆ្នោត ។ មានមនុស្សតែ ១១៨នាក់ទេ ដែលត្រូវបានហាមឃាត់មិនឲ្យចូលរួមនយោបាយ ។ ដូចនេះនៅមានមនុស្សច្រើនទៀតបានចូលរួម ។ សម្តេចតេជោបានស្នើឲ្យធ្វើការសិក្សា ពីច្បាប់បក្សនយោបាយរបស់ប្រទេសអូស្រ្តាលី ដែលទើបតែចេញកាលពីសប្តាហ៍មុន គឺធ្ងន់ធ្ងរជាងច្បាប់នៅកម្ពុជាទៅទៀត ។ ចុះហេតុអ្វីគេមិននាំគ្នាទៅស្តីបន្ទោសឲ្យអូស្រ្តាលីផង? សម្តេចតេជោបញ្ជាក់ថា ប្រទេសដែលគ្រប់គ្រងដោយច្បាប់ទើបជាប្រទេស ដែលមានប្រជាធិបតេយ្យ និងរក្សាបាននូវដំណើរការប្រជាធិបតេយ្យពិតប្រាកដ ។ ប្រជាធិបតេយ្យដែលគ្មានការគ្រប់គ្រងដោយច្បាប់ ឬនិយាយមួយបែបដោយគ្មាននីតិរដ្ឋ គឺជាដំណើរអនាធិបតេយ្យដែលមិនអាចគ្រប់គ្រងបានហើយទីបំផុតវានាំមកនូវវិនាសកម្ម និងការខ្លោចផ្សារសម្រាប់ប្រទេស ។

✵ ព្រឹកថ្ងៃទី១២ ខែធ្នូ សម្តេចតេជោបានអញ្ជើញជាអធិបតីដ៏ខ្ពង់ខ្ពស់ ក្នុងពិធីសម្ពោធដាក់ឱ្យប្រើប្រាស់នូវហេដ្ឋារចនាសម្ព័ន្ធអគារហ្វឹកហ្វឺនជំនាញចារកម្ម និងបុកគ្រឹះសាងសង់សាលប្រជុំនៃអគ្គនាយកដ្ឋានស្រាវជ្រាវចារកិច្ច ដែលមានតម្លៃជាងបីលានដុល្លារអាមេរិក នៅខណ្ឌព្រែកព្នៅ រាជធានីភ្នំពេញ ។

**សម្តេចតេជោ ហ៊ុន សែន** បានថ្លែងថា៖ «យើងមិនអាចឲ្យកើតមានភេរវកម្មនៅលើទឹកដីកម្ពុជា ហើយយើងក៏មិនចង់ឃើញប្រទេសនៅក្នុងតំបន់របស់យើងកើតមាននូវអំពើភេរវកម្មផងដែរ ។ ចំណុចនេះយើងនៅតែបន្តការខិតខំជាមួយប្រទេសទាំងអស់នៅលើពិភព

លោក ដើម្បីបន្តការប្រយុទ្ធប្រឆាំងជាមួយភេរវកម្ម ។ ប៉ុន្តែកម្ពុជាក៏ត្រូវមានការងារមួយ ដែលត្រូវធ្វើបន្តទៀតនោះ គឺការទប់ស្កាត់ការកើតមានបដិវត្តន៍ពណ៌ ។ យើងវ៉ៃបំបាក់ឆ្អឹងខ្នង ផ្តាច់ក្បាល និងរំលាយដងខ្លួននៃអង្គការភេរវកម្មនៃអង្គការបដិវត្តន៍ពណ៌ នៅក្នុងប្រទេសរួចស្រេចទៅហើយ ។ ប៉ុន្តែអ្នកដែលគាំទ្រវាមិនទាន់ផុតជីវិតទេ ។ ការប៉ុនប៉ងរបស់គេចំពោះយើងនៅតែមាន ។ ដូច្នេះទោះដោយតម្លៃណាក៏ដោយ មិនត្រូវឲ្យមានបដិវត្តន៍ពណ៌នៅកម្ពុជានោះទេ ។ នេះប្រហែលជាលើកដំបូងនៅក្នុងប្រវត្តិសាស្ត្រនៃបដិវត្តន៍ពណ៌ដែលពួកគេត្រូវបានបរាជ័យនៅក្នុងឆ្នាំ២០១៣ និងដើមឆ្នាំ២០១៤ និងក្រោយមកទៀត ។ មូលហេតុសំខាន់នៅត្រង់ថាក្បាលម៉ាស៊ីនរបស់រាជរដ្ឋាភិបាលមានការសាមគ្គីភាពគ្នាខ្ពស់ ។ ប្រជាជនមិនចង់ឃើញសង្គ្រាមកើតឡើងវិញ ទោះដោយទម្រង់ណាក៏ដោយ ជារដ្ឋប្រហារ ឬជាបដិវត្តន៍ពណ៌ ក្រោមហេតុផលនៃលទ្ធិប្រជាធិបតេយ្យ និងសិទ្ធិមនុស្សនោះទេ ។ កងកម្លាំងប្រដាប់អាវុធ គឺនៅឈរជាមួយរាជរដ្ឋាភិបាល ការពាររាជរដ្ឋាភិបាល ។ កំណើនសេដ្ឋកិច្ចនៅតែល្អ អតិផរណានៅគ្រប់គ្រងបានក្នុងក្របខណ្ឌរក្សាស្ថេរភាពនយោបាយ និងស្ថេរភាពនៃម៉ាក្រូសេដ្ឋកិច្ច ។ ពិតមែនតែយើងកាត់ក្បាល ឯដងខ្លួនយើងរំលាយ ក៏ប៉ុន្តែឧបាយកលពិសពុលនៃអ្នកបញ្ជាពីខាងក្រោយមិនទាន់ផុតរលត់នៅឡើយទេ ។ យើងត្រូវតែតាមមើលឲ្យជាប់ យើងបានដឹងរួចមកហើយនូវរចនាសម្ព័ន្ធចាត់តាំងនៃបដិវត្តន៍ពណ៌នៅកម្ពុជា ។ ទោះដោយតម្លៃណាក៏ដោយយើងមិនត្រូវឲ្យកើតឡើងបដិវត្តន៍ពណ៌ ដែលនាំដល់ការស្លាប់ប្រជាជនរាប់ម៉ឺន រាប់សែន រាប់លាននាក់នោះទេ ។ ជាប់គុកម្នាក់ពីរអ្នក ឬក៏ស្លាប់មនុស្សក្នុងរយៈពេលកន្លងទៅ គឺបណ្តាលមកពីមូលហេតុនៃបដិវត្តន៍ពណ៌នោះឯង ។ បើសិនជាគេរកឃើញរឿងនេះ វាក៏គ្មានរឿងអ្វីកើតឡើងនៅកម្ពុជានោះដែរ ។ ខ្ញុំក៏សង្ឃឹមថា អ្នកទាំងឡាយដែលធ្លាប់បានបញ្ជាបដិវត្តន៍ពណ៌ និងរួមចំណែកធ្វើបដិវត្តន៍ពណ៌នឹងបញ្ចប់ជាមួយទង្វើទាំងអស់នេះព្រោះថា នៅទីនេះ គឺជាតំបន់ដែលខ្ញុំកំពុងនិយាយនៅចំពោះមុខចារកម្មកងទ័ព ។ អ្នកបានដឹងហើយថា ឈ្មោះខឿនការពារជាតិរបស់ប្រជាជន គឺមិនមែនជាឈ្មោះធម្មតានោះទេ ហើយក៏មិនមែនគ្រាន់តែមានកម្លាំងចារកម្ម នៅទូទាំងកងទ័ពនោះដែរ ប៉ុន្តែប្រជាជនកម្ពុជាមានបញ្ញាគ្រប់គ្រាប់ក្នុងការវិនិច្ឆ័យ ទៅលើសកម្មភាពទាំងឡាយនោះ ។ សូមបញ្ជាក់ជូនអ្នកថា ក្នុងសម័យសង្គ្រាម គ្រាន់តែពាក្យដែលថា ៣មិន ១រាយការណ៍ ក៏ជាការទប់ស្កាត់ការវាយប្រហារត្រីភាគីក្នុងដំណាក់កាលនោះដែរ ។ ប្រហែលជាត្រូវសិក្សាបន្ថែមទៀតហើយ ជាពិសេសអ្នកដែលធ្លាប់ធ្វើសេចក្តីថ្លែងការណ៍ វិភាគទាក់ទិនជាមួយកម្ពុជា អ្នកគួរសិក្សាមើលឲ្យច្បាស់ថា ហេតុអ្វីវិស័យការពារជាតិរបស់ប្រជាជន វិស័យការពារជាតិ ដែលដឹកនាំដោយរាជរដ្ឋាភិបាល ហើយដែលក្នុងនោះគណបក្សដែលឈ្នះឆ្នោតគណបក្សគ្រប់គ្រងប្រទេសតាំងពីដើមទីមក ហេតុអ្វីបានជាកម្លាំងដ៏ខ្លាំង ការហ៊ុំព័ទ្ធពីខាងក្រៅ និងមានមហាអំណាចគាំទ្រត្រីភាគីវ៉ៃគណបក្ស វ៉ៃរាជរដ្ឋាភិបាល ជំនាន់សាធារណរដ្ឋប្រជាមានិតកម្ពុជា រដ្ឋកម្ពុជាមិនដួលរំលំ? អ្នកត្រូវតែសិក្សាឲ្យច្បាស់ប្រសិនបើអ្នកស្ទើរភ្លើង អ្នកនឹងទទួលបរាជ័យ" ។

❋ ព្រឹកថ្ងៃទី១៥ ខែធ្នូ សម្តេចតេជោបានអញ្ជើញជាអធិបតីដ៏ខ្ពង់ខ្ពស់នៅក្នុងពិធីប្រគល់ប្រាក់រង្វាន់រាជរដ្ឋាភិបាលជូនដល់កីឡាករកីឡាការិនី ជ័យលាភីមេដាយក្នុងការប្រកួតជើងឯកគ្រប់កម្រិតជាលក្ខណៈអន្តរជាតិនៅវិមានសន្តិភាព ។ ក្នុងព្រឹត្តិការណ៍នេះ សម្តេចតេជោបានថ្លែងទាក់ទងទៅនឹងការគំរាមជាថ្មីទៀត របស់ក្រុមសភាសហភាពអឺរ៉ុបអំពីការបន្តឹងទិដ្ឋាការ និងការបង្កកទ្រព្យសម្បត្តិ ។

**សម្តេចតេជោ ហ៊ុន សែន** មានប្រសាសន៍ថា៖ «អ្នកខ្លះកំពុងសង្ឃឹមទៅលើការបង្កកទ្រព្យសម្បត្តិរបស់មេដឹកនាំកម្ពុជានៅក្រៅប្រទេស ។ សូមអញ្ជើញធ្វើទៅ ។ ខ្ញុំរុញឲ្យអ្នកធ្វើទៅដើម្បីឲ្យបានដឹងថា មេដឹកនាំកម្ពុជា ណាខ្លះមានលុយនៅក្រៅប្រទេស? សូមអញ្ជើញធ្វើទៅ វាមិនបានធ្វើឲ្យប៉ះក្បាល ហ៊ុន សែន ទេ លើកលែងតែអ្នកឯងវ៉ៃទន្រ្ទានយកប្រទេសខ្ញុំទាំងមូល ។ ប៉ុន្តែអ្នកឯងហ៊ានចូលអ្នកឯងនឹងចោលខ្មោចនៅស្រុកខ្មែរដែរ ។ ប៉ុន្តែដំណាក់កាលនេះពិភពលោកនេះគេមិនធ្វើបែបនេះទេ ។ គេប្រើគ្នាឯងឲ្យធ្វើគ្នាឯងតែប៉ុណ្ណោះ ។ ព្រោះគេក៏ធ្លាប់ងាប់លើដីយើងរាប់មិនអស់ដែរ ។ អ្នកខ្លះយកខ្មោចទៅវិញមិនទាន់អស់ផង" ។ សម្តេចតេជោបានបន្តថា មិនបាច់គំរាមទេ ។ ខ្ញុំអំពាវនាវឲ្យអ្នកឯងធ្វើឲ្យលឿនមក ហើយគូសមកមនុស្សណាខ្លះ ដែលអ្នកឯងហាមឃាត់មិនឲ្យចូលប្រទេសអ្នកឯង ។ សម្តេចលើកជាសំណួរថា តើនៅពេលដែលគេមិនហាមឃាត់សួរថា មនុស្សទាំងអស់នឹងត្រូវការទៅរស់នៅស្រុកគេទើបរស់ឬអី?។ ពាក់ព័ន្ធទៅនឹងការដាក់ទណ្ឌកម្មរបស់សភាសហភាពអឺរ៉ុប សម្តេចតេជោបានលើកឡើងថា វិធានការទណ្ឌកម្មតាមសំណូមពររបស់អ្នក មិនមែនអ្នកណាក៏ចេះតែធ្វើតាមទេ ។ កុងត្រាកិច្ចសន្យានៃការបញ្ជាទិញទំនិញពីកម្ពុជាគេបានចុះហត្ថលេខារួចហើយ សួរថាតើវិស័យឯកជនគេព្រមធ្វើតាមទេ? បើធ្វើតាមគឺត្រូវសងគេ ។ រឿងរឹតបន្តឹងទិដ្ឋាការនេះទៀតសោតត្រូវមើលពាក្យគេឲ្យច្បាស់ រឹតបន្តឹងទិដ្ឋាការ មិនមែនទណ្ឌកម្មទិដ្ឋាការទេ គឺវាមានន័យខុសគ្នា ។ តែទោះបីជាដាក់ទណ្ឌកម្មទិដ្ឋាការក៏អត់ងាប់ខ្មែរដែរ ។ រឿងធំជាងមិនមែនមកពីកត្តាសម្ពាធនេះ សម្ពាធនោះទេ ។ ពិភពលោកបច្ចុប្បន្នមានឥរិយាបទនយោបាយការបរទេសឯករាជ្យផ្សេងៗគ្នា កម្រិតខុសៗគ្នា ។ សម្តេចតេជោបន្ថែមថា ជារឿងធម្មតាទេ យើងទៅវាយបំបាក់ជើងកូនរបស់គេ នៅពេលដែលកូនរបស់គេចូលមកលួចប្លន់យើង ។ ឱគេច្បាស់ជាខឹងហើយ ។ ដឹងហើយអ្នកដែលយើងវាយបំបាក់ជើងជាអ្នកណា? បដិវត្តន៍ពណ៌អ្នកណាជាអ្នកបញ្ជាវា? ។

❋ ព្រឹកថ្ងៃទី១៧ ខែធ្នូ សម្តេចតេជោនាយករដ្ឋមន្ត្រីកម្ពុជាបានអញ្ជើញជាអធិបតីដ៏ខ្ពង់ខ្ពស់ក្នុង ពិធីជួបសំណេះសំណាលជាមួយតំណាងកម្មករ កម្មការិនី សរុបជិតប្រាំពាន់នាក់នៅសាលមហោស្រពកោះពេជ្រ រាជធានីភ្នំពេញ។

ក្នុងឱកាសនោះ សម្តេចតេជោបានថ្លែងថា «កត្តាកំណត់ គឺនៅក្នុងផ្ទៃក្នុងរបស់កម្ពុជា មិនមែននៅលើពួកបរទេសជាអ្នកកំណត់នោះទេ ។ ប្រសិនជានៅលើពួកបរទេសជាអ្នកកំណត់ដដែលនោះខ្មែរគឺជាឆ្កែស៊ុទ្ធ ដែលថា ដើរតាមអញ ទើបអញទំលាក់ឆ្អឹងឲ្យស៊ុ ។



***សម្តេចតេជោ ហ៊ុន សែន** អញ្ជើញជាអធិបតីភាពដ៏ខ្ពង់ខ្ពស់ក្នុងពិធីបុណ្យសមុទ្រលើកទី៦*

ឯករាជ្យ អធិបតេយ្យភាពរបស់ជាតិមួយមានតម្លៃធំណាស់ ។កុំធ្វើជាសត្វឆ្កែគ្រាន់តែដើម្បីជាមួយឆ្អឹងឬ សាច់មួយដុំវាមិនថ្លៃថ្នូរទេ» ។

សម្តេចតេជោបានបន្តថា ឧទាហរណ៍ដូចជាការគំរាមថា បើមិនដើរតាមអញ កាត់ផ្តាច់នេះកាត់ផ្តាច់នោះ។ លោកឯងធ្វើទៅ ។ លោកឯងជ្រើសរើសមនុស្សប៉ុន្មាននោះ ឬជ្រើសរើសប្រជាជន ១៥លាននាក់?។ លោកឯងជ្រើសរើសទំនាក់ទំនងជាមួយបុគ្គលមួយក្រុម ឬក៏លោកឯងជ្រើសរើសទំនាក់ទំនងរវាងប្រទេស និងប្រទេស?។ ពិភពលោកមានទៅមានមក។ ពាក្យរឹតបន្តឹងទិដ្ឋាការសុំអញ្ជើញ! វាចំណេញលុយខ្មែរតើ។ គេក៏ត្រូវការចូលស្រុកខ្មែរដែរ។ យើងរឹតបន្តឹងវិញទៅ ព្រោះខ្មែរមិនមែនមានទំនាក់ទំនងតែប្រទេសមួយក្រុមឯណា។ ខ្មែរមានទំនាក់ទំនងជាមួយពិភពលោក។

✵ រយៈពេលបីថ្ងៃចាប់ពីថ្ងៃទី២២ ដល់ថ្ងៃទី២៤ ខែធ្នូ ឆ្នាំ២០១៧ ព្រះរាជាណាចក្រកម្ពុជា បានប្រារព្ធពិធីបុណ្យសមុទ្រប្រចាំឆ្នាំលើកទី៦ ដែលប្រព្រឹត្តិទៅនៅទីរួមខេត្តកែបស្ថិតជាប់នឹងឆ្នេរសមុទ្រតែម្តង។ បុណ្យសមុទ្រលើកនេះក្រោមប្រធានបទ "**ឆ្នេរសមុទ្របៃតងៈ អនាគត គឺបច្ចុប្បន្ន**" និងអមដោយពាក្យស្លោក "**និរន្តរភាពទេសចរណ៍សម្រាប់ការអភិវឌ្ឍ**" ។ ពិធីដ៏អធឹកអធមនេះ ប្រព្រឹត្តិទៅក្រោមអធិបតីភាពដ៏ខ្ពង់ខ្ពស់របស់ **សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន** នាយករដ្ឋមន្ត្រីនៃព្រះរាជាណាចក្រកម្ពុជា។

សម្តេចតេជោ ប្រមុខរាជរដ្ឋាភិបាលក៏បានអញ្ជើញចូលរួមសម្ពោធអគារសិក្សាដ៏ស្កឹមស្កៃមួយខ្នងកម្ពស់បីជាន់មាន ១៨បន្ទប់នៅវិទ្យាល័យ **ប៊ុន រ៉ានី ហ៊ុន សែន** ចរិយាវង្ស ក្នុងភូមិដំណាក់ចំបក់ សង្កាត់អូរក្រសារ ក្រុងកែប ។ សមិទ្ធិនេះ ជាអំណោយរបស់**សម្តេចតេជោ** និង**សម្តេចកិត្តិព្រឹទ្ធបណ្ឌិត ប៊ុន រ៉ានី ហ៊ុន សែន** ។ សម្តេចតេជោបានសម្រេចផ្តល់អគារសិក្សានេះកាលពីថ្ងៃទី ៣ ខែសីហា ឆ្នាំ២០១៦ ក្នុងអំឡុងពេលដែលសម្តេចតេជោអញ្ជើញមកសំណេះសំណាលជាមួយមន្ត្រីរាជការនៅក្នុងខេត្តកែប។

នាឱកាសបើកបុណ្យសមុទ្រ សម្តេចតេជោបានសង្កត់ធ្ងន់អំពីចំណុចចម្បង គឺសន្តិភាព ស្ថិរភាពនៅកម្ពុជា។ សម្តេចតេជោមានប្រសាសន៍ថា ដើម្បីជំរុញកំណើនភ្ញៀវទេសចរត្រូវធានាឲ្យមាននូវវត្តមានជាអចិន្ត្រៃយ៍នៃសន្តិភាព និងអវត្តមានជាអចិន្ត្រៃយ៍នូវ





***សម្តេចតេជោ ហ៊ុន សែន** អញ្ជើញសម្ពោធដាក់ឲ្យប្រើប្រាស់ជាផ្លូវការ អគារសិក្សាថ្មី ១ខ្នង ៣ជាន់ ១៨បន្ទប់ នៅវិទ្យាល័យ **ប៊ុន រ៉ានី ហ៊ុន សែន** ចរិយាវង្ស*

សង្គ្រាមនិងកលយុគ។ ផ្តើមចេញពីចំណុចខាងលើនេះ សម្តេចតេជោអំពាវនាវដល់ប្រជាពលរដ្ឋទាំងមូល ត្រូវរួបរួមគ្នាការពារនូវសុខសន្តិភាព ដែលរកមកបានដោយលំបាកមិនត្រូវឲ្យប្រទេសឬក្រុមណាមួយមកបំផ្លាញសន្តិភាពទោះក្នុងលក្ខខណ្ឌណាក៏ដោយ។

សម្តេចតេជោបន្តថា យើងត្រូវរក្សាឲ្យបាននូវសមុទ្របៃតង។ រក្សាឲ្យបានជាឈ្មោះជាតារារះនាទិសនិរតី។ អភិវឌ្ឍន៍តំបន់ឆ្នេរបន្ថែម ។ ការពារឆ្នេរ ការពារបរិស្ថានធម្មជាតិ ត្រូវធ្វើឲ្យឆ្នេរសមុទ្រកម្ពុជានៅតែស្អាតជានិច្ច ។ ខិតខំកសាងហេដ្ឋារចនាសម្ព័ន្ធបន្ថែមដូចជាការតភ្ជាប់ មានផ្លូវគោក ផ្លូវដែក ផ្លូវអាកាស ដើម្បីបំរើភ្ញៀវទេសចរ។ ត្រូវការពារសន្តិសុខ សណ្តាប់ធ្នាប់សង្គមឲ្យបានល្អគ្រប់ទីកន្លែងកុំឲ្យមានក្រុមគ្រឿងញៀន ចោរឆក់ ប្លន់។ មិនត្រូវឲ្យសមុទ្រកម្ពុជាក្លាយទៅជាកន្លែងជ្រកកោននៃពួកគ្រឿងញៀន ឬពួកភេរវកម្មណាមួយឡើយ។ ត្រូវជំរុញការផលិត ផលិតផលបំរើវិស័យទេសចរណ៍អោយបានច្រើនដូចជា បង្កើនការដាំដុះដំណាំបែបធម្មជាតិសម្រាប់លក់ចែកចាយដល់ភ្ញៀវទេសចរ ។ ការចិញ្ចឹមសត្វ ចិញ្ចឹមត្រីជាដើម ជាពិសេសតាមសណ្ឋាគារនានាត្រូវយកចិត្តទុកដាក់ និងទិញផលិតផលធម្មជាតិពីប្រជាពលរដ្ឋដើម្បីបម្រើភ្ញៀវទេសចរ ។

# កម្ពុជាប្រារព្ធខួបអនុស្សាវរីយ៍លើកទី៣៩ ថ្ងៃកំណើត រណសិរ្សសាមគ្គីអភិវឌ្ឍន៍មាតុភូមិកម្ពុជា



***សម្តេច ហេង សំរិន*** *ប្រធានរណសិរ្ស* ***សម្តេច ជា ស៊ីម*** *អនុប្រធានរណសិរ្ស ធ្វើដំណើរត្រួតពល ក្នុងឱកាសពិធីមីទ្ទីញប្រកាសរណសិរ្សសាមគ្គីសង្គ្រោះជាតិកម្ពុជា*



***សម្តេចតេជោ ហ៊ុន សែន*** *អញ្ជើញជួបសំណេះសំណាលជាមួយប្រជាជនក្នុងតំបន់រំដោះ*

កម្ពុជាបានប្រារព្ធពិធីអបអរសាទរខួបអនុស្សាវរីយ៍លើកទី៣៩ ថ្ងៃកំណើតរណសិរ្សសាមគ្គីអភិវឌ្ឍន៍មាតុភូមិកម្ពុជា ដែលមានឈ្មោះដើមរណសិរ្សសាមគ្គីសង្គ្រោះជាតិកម្ពុជា (២ធ្នូ១៩៧៨ - ២ធ្នូ ២០១៧) នៅសាលសន្និសីទចតុមុខកាលពីព្រឹកថ្ងៃទី២ ខែធ្នូ ក្រោមអធិបតីភាពដ៏ខ្ពង់ខ្ពស់**សម្តេចអគ្គមហាពញាចក្រី ហេង សំរិន** ប្រធានរដ្ឋសភានៃព្រះរាជាណាចក្រកម្ពុជា និងជាប្រធានក្រុមប្រឹក្សាជាតិរណសិរ្សសាមគ្គីអភិវឌ្ឍន៍មាតុភូមិកម្ពុជា។

មានប្រសាសន៍ក្នុងឱកាសនេះ **សម្តេចចក្រី ហេង សំរិន** បានបញ្ជាក់ថា ស្មារតី ២ធ្នូ និងស្មារតី ៧មករា នៅតែបានចារឹកជាប់ក្នុងក្រអៅបេះដូងរបស់ប្រជាជនកម្ពុជាគ្រប់រូប និងបានប្រែក្លាយទៅជាកម្លាំងសាមគ្គីដ៏ធំក្នុងការបង្កើតឡើង នូវសមិទ្ធផលនានាលើគ្រប់វិស័យសម្រាប់សង្គមជាតិទាំងមូល។ ពីមួយឆ្នាំទៅមួយឆ្នាំ ក្រោមពន្លឺនៃសន្តិភាពនិងសេរីភាពព្រះរាជាណាចក្រកម្ពុជា យើងមានការអភិវឌ្ឍលើគ្រប់វិស័យសមិទ្ធផលធំៗជាច្រើន បានរីកស្គុះស្គាយពេញផ្ទៃប្រទេស ទាំងនេះគឺជាកញ្ចក់ឆ្លុះបញ្ចាំងឲ្យឃើញពី សមិទ្ធផល និងជោគជ័យថ្មីៗបន្ថែមទៀត ដែលនឹងកើតឡើងនៅ ក្នុងឆ្នាំ២០១៨ និងឆ្នាំខាងមុខបន្តបន្ទាប់ទៀត។

សម្តេចចក្រីបានថ្លែងទៀតថា រយៈពេល ៣៩ឆ្នាំកន្លងទៅនេះ បន្ទាប់ពីថ្ងៃជ័យជម្នះ៧មករា១៩៧៩ក្រោមការដឹកនាំដ៏ត្រឹមត្រូវ និងប្រកបដោយចក្ខុវិស័យវែងឆ្ងាយរបស់គណបក្សប្រជាជនកម្ពុជា តាមរយៈការជម្នះរាល់ឧបសគ្គ និងការលំបាកយ៉ាងច្រើនឥតគណនាធ្វើឲ្យប្រទេសជាតិសម្រេចបានសមិទ្ធផលធំៗ និងសំខាន់ៗជាប្រវត្តិសាស្ត្រ ដែលបាននាំឲ្យចាកផុតពីស្រមោលអតីតកាលដ៏សែនឈឺចាប់ និងកំពុងបោះជំហានទៅមុខយ៉ាងស្វាហាប់លើមាគ៌ាសុខសន្តិភាពពេញលេញ ស្ថិរភាពនយោបាយសណ្តាប់ធ្នាប់សង្គម និងមានការអភិវឌ្ឍលើគ្រប់វិស័យ។

គួរបញ្ជាក់ថា រណសិរ្សសាមគ្គីសង្គ្រោះជាតិកម្ពុជា បច្ចុប្បន្នមានឈ្មោះថា រណសិរ្សសាមគ្គីអភិវឌ្ឍន៍ កម្ពុជាបានបង្កើតឡើងនៅថ្ងៃទី ២ធ្នូ ឆ្នាំ១៩៧៨ នៅស្រុកស្នួល ខេត្តក្រចេះ ដែលត្រូវបានបង្កើតឡើងដោយថ្នាក់ដឹកនាំនៃគណបក្សប្រជាជនកម្ពុជា ដើម្បីវាយផ្តួលរំលំពីរបបប្រល័យពូជសាសន៍ ប៉ុល ពត សង្គ្រោះប្រទេសជាតិ នាថ្ងៃទី ៧មករា ឆ្នាំ១៩៧៩។ ដោយការរីកចម្រើនរឹងមាំឥតឈប់ឈរ**រណសិរ្សសាមគ្គីសង្គ្រោះជាតិកម្ពុជា** បានប្តូរឈ្មោះមកជា **"រណសិរ្សសាមគ្គីកសាងការពារមាតុភូមិកម្ពុជា"** និងចុងក្រោយនេះ គឺ **"រណសិរ្សសាមគ្គីអភិវឌ្ឍន៍មាតុភូមិកម្ពុជា"** ៕





*ពិធីអបអរសាទរខួបអនុស្សាវរីយ៍លើកទី៣៩ ថ្ងៃកំណើតរណសិរ្សសាមគ្គីអភិវឌ្ឍន៍មាតុភូមិកម្ពុជា*

# សម្ដេចក្រឡាហោម ស ខេង បញ្ជាឲ្យប៉ូលិសនៅមូលដ្ឋានផ្សព្វផ្សាយ ពីកំហុសក្បត់ជាតិរបស់អតីតមេដឹកនាំបក្សប្រឆាំង





***សម្ដេចក្រឡាហោម ស ខេង*** *ឧបនាយករដ្ឋមន្ត្រី និងជា រដ្ឋមន្ត្រីក្រសួងមហាផ្ទៃ អញ្ជើញចូលរួមសន្និបាត ស្ដីពីការពង្រឹងការងារប៉ុស្ដិ៍នគរបាល រដ្ឋបាលទូទាំងប្រទេសលើក ទី២*

**សម្ដេចក្រឡាហោម ស ខេង** ឧបនាយករដ្ឋមន្ត្រី និងជា រដ្ឋមន្ត្រីក្រសួងមហាផ្ទៃ បានបញ្ជាឲ្យនគរបាលនៅទូទាំងប្រទេស ធ្វើការបកស្រាយផ្សព្វផ្សាយអប់រំឲ្យប្រជាពលរដ្ឋនៅគ្រប់មូលដ្ឋាន បានយល់ពីកំហុសរបស់លោក កឹម សុខា និងអតីតគណបក្ស សង្គ្រោះជាតិ ឃុបឃិតជាមួយបរទេស ធ្វើសកម្មភាពផ្ដួលរំលំរដ្ឋ អំណាចស្របច្បាប់តាមរយៈការរៀបចំបដិវត្តន៍ពណ៌ ដែលផ្ទុយពី គោលការណ៍នៃលទ្ធិប្រជាធិបតេយ្យ សេរីពហុបក្ស ដែលបទល្មើស នេះមានចែងច្បាស់លាស់នៅក្នុងក្រមព្រហ្មទណ្ឌ និងច្បាប់ស្ដីពី គណបក្សនយោបាយ ។

ការបញ្ជារបស់សម្ដេចក្រឡាហោមបានធ្វើឡើងនៅក្នុងសន្និបាត ស្ដីពីការពង្រឹងការងារប៉ុស្ដិ៍នគរបាល រដ្ឋបាលទូទាំងប្រទេសលើក ទី២ នៅមជ្ឈមណ្ឌលសន្និបាត និងពិព័រណ៍កោះពេជ្រ កាលពីព្រឹក ថ្ងៃទី១៣ ខែធ្នូ ឆ្នាំ២០១៧ ។

**សម្ដេចក្រឡាហោម ស ខេង** បានបញ្ជាក់ថា " បច្ចុប្បន្ននេះ សភាពការណ៍សន្តិសុខ នយោបាយ បាននឹងកំពុងវិវត្តក្នុងបរិបទថ្មី មួយ និងដោយមានសមាសភាពចូលរួមមានកម្រិតទូទាំងប្រទេស ។ ហេតុនេះ យើងក៏ត្រូវចូលរួមផ្សព្វផ្សាយឲ្យបានទូលំទូលាយជូន ប្រជាពលរដ្ឋបានយល់ដឹងទាំងអស់គ្នា ។ សភាពការណ៍នោះ គឺកាលពីថ្ងៃទី០៣ ខែកញ្ញា ឆ្នាំ២០១៧ លោក កឹម សុខា ជាអតីត ប្រធានគណបក្សសង្គ្រោះជាតិត្រូវបានឃាត់ខ្លួនបញ្ជូនទៅតុលាការ ពីបទក្បត់ជាតិ ។ នៅថ្ងៃទី១៦ ខែវិច្ឆិកា ឆ្នាំ២០១៧ គណបក្ស សង្គ្រោះជាតិ និងមេដឹកនាំចំនួន ១១៨រូប ត្រូវបានសាលដីកា តុលាការកំពូលប្រកាសរំលាយ និងផ្អាកសកម្មភាពនយោបាយ រយៈពេល៥ឆ្នាំ ។ ទាក់ទងនឹងព្រឹត្តិការណ៍នេះ មានសាធារណៈជន ជាច្រើនបានយល់ពីហេតុផលដែលនាំឲ្យមានរឿងហេតុ ហើយគាំ ទ្រចំពោះចំណាត់ការរបស់រាជរដ្ឋាភិបាល និងតុលាការ។ ប៉ុន្តែក៏ នៅមានមួយចំនួនដែលមិនទាន់យល់ ឬក៏យល់បានដែរ ប៉ុន្តែ អាស្រ័យដោយនិន្នាការនយោបាយស្ថិតនៅម្ខាង ឬក៏លំអៀង ហេតុនេះ ទើបមានសំណូមពរតម្រូវឲ្យមន្ត្រីនគរបាលជាតិនិយាយ ជារួម និងដោយឡែកមន្ត្រីប៉ុស្ដិ៍នគរបាលរដ្ឋបាល ដែលមាន ការងារប្រចាំថ្ងៃនៅផ្ទាល់ជាមួយប្រជាជន ជួយធ្វើការបកស្រាយ ផ្សព្វផ្សាយ អប់រំ ឲ្យប្រជាពលរដ្ឋនៅគ្រប់មូលដ្ឋានយល់ច្បាស់ពី កំហុសរបស់លោក កឹម សុខា និងគណបក្សសង្គ្រោះជាតិ ដែល មានទោសធ្ងន់ធ្ងរ មិនអាចអត់អោនឲ្យបានដោយសារពួកគេបាន ឃុបឃិតជាមួយបរទេស ធ្វើសកម្មភាពផ្ដួលរំលំរដ្ឋអំណាចស្រប ច្បាប់ តាមរយៈការរៀបចំបដិវត្តន៍ពណ៌ ផ្ទុយពីគោលការណ៍នៃ លទ្ធិប្រជាធិបតេយ្យ សេរី ពហុបក្ស ដែលបទល្មើសនេះ មាន ចែងច្បាស់លាស់នៅក្នុងក្រមព្រហ្មទណ្ឌ និងច្បាប់ស្ដីពីគណបក្ស នយោបាយ " ។

សម្ដេចក្រឡាហោម បានលើកឡើងថា៖ «បរទេសមួយចំនួន ចោទប្រកាន់មកលើការដឹកនាំរបស់រាជរដ្ឋាភិបាលថា បានធ្វើឲ្យ លទ្ធិប្រជាធិបតេយ្យនៅកម្ពុជាដើរថយក្រោយ ឬថា ធ្វើការគាប សង្កត់ បំបិទសិទ្ធិសេរីភាព ជាមូលដ្ឋានដែលចែងនៅក្នុងសេចក្ដី ថ្លែងការណ៍ជាសកល។ល។ យើងត្រូវបញ្ជាក់ឲ្យច្បាស់ថា បញ្ហា នេះគឺជា ការចាំបាច់ក្នុងការអនុវត្តច្បាប់ដើម្បីពង្រឹងនីតិរដ្ឋ ពង្រឹង លទ្ធិប្រជាធិបតេយ្យ និងមិនមានន័យថា ព្រះរាជាណាចក្រកម្ពុជា ដែលមានរាជរដ្ឋាភិបាលដឹកនាំដោយគណបក្សប្រជាជនកម្ពុជា បាន បោះបង់ចោលនូវលទ្ធិប្រជាធិបតេយ្យនោះទេ ។

ស្ថានភាពសន្តិសុខ សណ្ដាប់ធ្នាប់សាធារណៈ និងសុវត្ថិភាព សង្គមឆ្នាំ២០១៧ មានលក្ខណៈល្អប្រសើរ បើទោះជាមាន សកម្មភាពញុះញង់ បង្កើតឲ្យមានកូដកម្ម បាតុកម្មប្រឆាំងពីក្រុម អគតិជ្រុលនិយម ក្នុងចេតនាបំពុលបរិយាកាសនយោបាយ និង សន្តិសុខសង្គមក្តី ក៏បញ្ហាទាំងនោះ ត្រូវបានដោះស្រាយដោយ សន្តិវិធី ដោយទប់ស្កាត់បាននូវអំពើហិង្សា និងបង្រួមទំនាស់មិន អោយរីករាលដាលបង្កអោយមានចលាចលសង្គមបានឡើយ ៕

# សកម្មភាពសមាជិករដ្ឋសភា ព្រឹទ្ធសភា រាជរដ្ឋាភិបាល និងមន្ត្រីគណបក្ស





ឯកឧត្តម **ខួន ញឹល** សមាជិកគណៈអចិន្ត្រៃយ៍ គណៈកម្មាធិការកណ្តាល គណបក្សប្រជាជនកម្ពុជាអនុប្រធាន ទី២ រដ្ឋសភា នៃព្រះរាជាណាចក្រកម្ពុជា និងជាប្រធាន ក្រុមការងារគណបក្សថ្នាក់កណ្តាល ចុះជួយខេត្តកំពង់ធំ នៅព្រឹកថ្ងៃទី១៩ខែធ្នូឆ្នាំ២០១៧នេះបានអញ្ជើញជួបសំណេះសំណាល សួរសុខទុក្ខផ្ទាល់ និងនាំយកថវិកា សម្ភារៈប្រើប្រាស់ ស្បៀងអាហារជាច្រើន និងសង់ផ្ទះឡើងវិញ ជូនចំពោះគ្រួសាររងគ្រោះដោយភ្លើងឆេះផ្ទះទាំងស្រុង ចំនួន ៣គ្រួសារ រស់នៅក្នុងភូមិត្រពាំងជ្រៃ ឃុំបល្ល័ង្គ ស្រុកបារាយណ៍ ខេត្តកំពង់ធំ ។

ឯកឧត្តម **ខួន ញឹល** បានមានប្រសាសន៍ទៅកាន់គ្រួសាររងគ្រោះ ដោយបញ្ជាក់ពីទឹកចិត្តក្រៀមក្រំ ចូលរួមការសោកស្តាយដោយទទួលបានព័ត៌មាននេះ ។ ឯកឧត្តមបណ្ឌិត បានថ្លែងអំណរគុណដល់ព្រះសង្ឃ ជាព្រះអនុគណស្រុកបារាយណ៍ សាខាកាកបាទក្រហម កងកម្លាំង និងអាជ្ញាធរខេត្តកំពង់ធំ និងស្រុកបារាយណ៍ ដែលបានចូលរួមអន្តរាគមន៍ លើការងារមនុស្សធម៌នេះទាន់ពេលវេលា ។



ថ្ងៃទី ១៤ ខែធ្នូ ឆ្នាំ២០១៧ លោកជំទាវ **ម៉ែន សំអន** សមាជិកាគណៈអចិន្ត្រៃយ៍គណៈកម្មាធិការកណ្តាល ឧបនាយករដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងទំនាក់ទំនងជាមួយរដ្ឋសភា-ព្រឹទ្ធសភា និងអធិការកិច្ចតំណាងដ៏ខ្ពង់ខ្ពស់ **សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន** នាយករដ្ឋមន្ត្រីនៃព្រះរាជាណាចក្រកម្ពុជា បានអញ្ជើញជាអធិបតីក្នុងពិធីអប-អរសាទរខួបលើកទី២៥ នៃការដាក់បញ្ចូលរមណីយដ្ឋានអង្គរក្នុងបញ្ជីបេតិកភណ្ឌពិភពលោកនៅលើទឹកដីសៀមរាប។ លោកជំទាវបានបញ្ជាក់ថា ជោគជ័យដ៏ធំធេងនេះមិនមែនជាការចៃដន្យនោះទេ គឺពិតជាបានមក ពីការខិតខំប្រឹងប្រែងថែរក្សា និងអភិរក្សពីរាជរដ្ឋាភិបាលកម្ពុជា ដែលដឹកនាំដោយ**សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុនសែន**នាយករដ្ឋមន្ត្រីនៃព្រះរាជាណាចក្រកម្ពុជាដែលតែងតែយកចិត្តទុកដាក់ខ្ពស់ក្នុងការលើកស្ទួយវប្បធម៌និងបេតិកភណ្ឌជាតិ។



ថ្ងៃទី១៣ ខែធ្នូ ឆ្នាំ២០១៧ ឯកឧត្តម **ទេព ងន** សមាជិកគណៈអចិន្ត្រៃយ៍គណៈកម្មាធិការកណ្តាល អនុប្រធានទី២ ព្រឹទ្ធសភា បានជួបសវនាការជាមួយគណៈប្រតិភូព្រឹទ្ធសភានៃសាធារណរដ្ឋឆែក ។ ក្នុងជំនួបនោះ ភាគីទាំងពីរបានឯកភាពគ្នាបន្តខិតខំពង្រឹងពង្រីកទំនាក់ទំនងសហប្រតិបត្តិការ រវាងប្រទេសទាំងពីរ ជាពិសេសរវាងស្ថាប័ននីតិប្បញ្ញត្តិនៃប្រទេសទាំងពីរ។ សាធារណរដ្ឋឆែក បានចាត់ទុកកម្ពុជាជាប្រទេសអាទិភាពក្នុងការផ្តល់ជំនួយអភិវឌ្ឍន៍ និងជាដៃគូស្និតរមួតក្នុងចំណោមប្រទេសអាស៊ាន។



ក្នុងខែធ្នូ ឆ្នាំ២០១៧ ឯកឧត្តមនាយឧត្តមសេនីយ៍ **គន់ គីម** សមាជិកគណៈអចិន្ត្រៃយ៍គណៈកម្មាធិការ កណ្តាលគណបក្សប្រជាជនកម្ពុជា អគ្គមេបញ្ជាការរងកងយោធពលខេមរភូមិន្ទ និងជាប្រធានសេនាធិការចម្រុះបានអញ្ជើញចុះសួរសុខទុក្ខ និងពិនិត្យមើលពីជីវភាពរស់នៅរបស់នាយទាហាន នាយទាហានរង និងកងទ័ពនៅវរសេនាតូចលេខ៣៧២ ចំណុះកងពលតូចអន្តរាគមន៍លេខ៧។

# សកម្មភាពសមាជិករដ្ឋសភា_ព្រឹទ្ធសភា_រាជរដ្ឋាភិបាល និងមន្ត្រីគណបក្ស



ថ្ងៃទី ១៤ ខែធ្នូ ឆ្នាំ២០១៧ ឯកឧត្តមនាយឧត្តមសេនីយ៍ **មាស សុភា** សមាជិកគណៈអចិន្ត្រៃយ៍គណៈកម្មាធិការកណ្តាលគណបក្សប្រជាជនកម្ពុជា អគ្គមេបញ្ជាការរងកងយោធពលខេមរភូមិន្ទ មេបញ្ជាការកងទ័ពជើងគោក ប្រធានក្រុមការងារថ្នាក់ជាតិចុះជួយខេត្ត ព្រះវិហារ រួមជាមួយ ឯកឧត្តម **អ៊ុន ចាន់ដា** អភិបាលនៃគណៈអភិបាល ខេត្តព្រះវិហារ អញ្ជើញជាអធិបតីក្នុងពិធីចែកវិញ្ញាបនបត្រសម្គាល់ម្ចាស់អចលនវត្ថុជូនប្រជាពលរដ្ឋ ស្ថិតក្នុងភូមិចំបក់សែនជ័យ ភូមិធម្មជាតិសម្តេចតេជោ ឃុំស្រអែម និងភូមិសុខសែនជ័យឃុំកន្ទួត ស្រុកជាំក្សាន្ត ចំនួន ៤.៤៣៥ ក្បាលដីនៅវត្តគីរីតេជោស្វរៈ។



ថ្ងៃទី៩ ខែធ្នូ ឆ្នាំ២០១៧ ឯកឧត្តម **ចម ប្រសិទ្ធ** សមាជិកគណៈកម្មាធិការកណ្តាលគណបក្សប្រជាជនកម្ពុជា ទេសរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងឧស្សាហកម្ម និងសិប្បកម្ម និងជាប្រធានក្រុមការងារថ្នាក់កណ្តាលចុះជួយខេត្តកែប បាននាំក្រុមគ្រូពេទ្យស្ម័គ្រចិត្តចុះពិនិត្យ ព្យាបាលជំងឺជូនប្រជាពលរដ្ឋដោយឥតគិតថ្លៃជាង ៣០០នាក់ នៅក្នុងបរិវេណវិទ្យាល័យ **ហ៊ុន សែន** ចំការដូង ក្នុងភូមិភ្នំលាវ ឃុំពងទឹក ស្រុកដំណាក់ចង្អើរ ខេត្តកែប។



ថ្ងៃទី១០ ខែធ្នូ ឆ្នាំ២០១៧ ឯកឧត្តម **ជា សុផារ៉ា** សមាជិកគណៈកម្មាធិការកណ្តាលគណបក្សប្រជាជនកម្ពុជា ទេសរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងរៀបចំដែនដី នគរូបនីយកម្ម និងសំណង់ បានអញ្ជើញជាអធិបតីក្នុងពិធីសម្ពោធដាក់ឲ្យប្រើប្រាស់មហាកុដិ, ព្រះពុទ្ធរូប និងសមិទ្ធផលនានានៅវត្តបទុមព្រឹក្ស (ហៅវត្តជើងច្រង់) នៅភូមិជើងច្រង់ ឃុំទួលស្នួល ស្រុកក្រូចឆ្មារ ខេត្តត្បូងឃ្មុំ។



ថ្ងៃទី១៦ ខែធ្នូ ឆ្នាំ២០១៧ ឯកឧត្តម **ត្រាំ អ៊ីវតឹក** សមាជិកគណៈកម្មាធិការ-កណ្តាលគណបក្សប្រជាជនកម្ពុជា រដ្ឋមន្ត្រីក្រសួងប្រៃសណីយ៍និងទូរគមនាគមន៍ ប្រធានក្រុមការងារថ្នាក់កណ្តាលចុះជួយស្រុកទឹកផុស និងស្រុកកំពង់លែងខេត្តកំពង់ឆ្នាំង បានអញ្ជើញជាអធិបតីក្នុងពិធីប្រកាសបញ្ចូលសមាជិកគណបក្សប្រជាជនកម្ពុជាថ្មី (ជាអតីតសមាជិកមកពីគណបក្សសង្គ្រោះជាតិ) ចំនួន១៦នាក់ និងសំណេះសំណាលជាមួយសមាជិកគណបក្សប្រជាជនកម្ពុជាចំនួន ៥៦៧នាក់ នៅទីស្នាក់ការគណបក្សប្រជាជនកម្ពុជាស្រុកកំពង់លែង។



ថ្ងៃទី៧ ខែធ្នូ ឆ្នាំ២០១៧ ឯកឧត្តម **ជា ខេង** សមាជិកគណៈកម្មាធិការកណ្តាលគណបក្សប្រជាជនកម្ពុជា ប្រធានគណៈកម្មការទី២ ព្រឹទ្ធសភា និងជាប្រធានក្រុមមិត្តភាពទ្វេភាគីព្រឹទ្ធសភាកម្ពុជាសភាតួកគីបានអញ្ជើញជាអធិបតីភាពក្នុងពិធីសម្ពោធដាក់ឲ្យប្រើប្រាស់អណ្តូងស្នប់ ដែលឧបត្ថម្ភដោយអង្គការសន្ទនាមេគង្គ (MDI) ជូនប្រជាពលរដ្ឋនៅភូមិតាប៉ាវបំពេញទេស និងភូមិឈូកសណ្តល់ ឃុំរកាពប្រាំ ស្រុកត្បូងឃ្មុំ ខេត្តត្បូងឃ្មុំ។

# សកម្មភាពសមាជិករដ្ឋសភា_ព្រឹទ្ធសភា_រាជរដ្ឋាភិបាល និងមន្ត្រីគណបក្ស



ថ្ងៃទី០៩ ខែធ្នូ ឆ្នាំ ២០១៧ ឯកឧត្តម **ម៉ម ប៊ុននាង** ប្រធានស្តីទីគណៈកម្មការទី១០ព្រឹទ្ធសភា និងជាសមាជិកព្រឹទ្ធសភាប្រចាំភូមិភាគទី៣ (ខេត្តកណ្តាល) បានអញ្ជើញជួបសំណេះសំណាលជាមួយក្រុមប្រឹក្សាឃុំ មេភូមិ ប្រជាការពារ ស្ត្រី ដែលទើបសម្រាលកូនមានជីវភាពក្រីក្រ និងប្រជាពលរដ្ឋចាស់ជរាសរុបចំនួន៥៨នាក់ នៅឃុំកំពង់ស្វាយ ស្រុកកៀនស្វាយ ខេត្តកណ្តាល។ ឯកឧត្តមបានលើកឡើងថា ស្ត្រីដែលទើបសម្រាលកូន និងអ៊ុំ ពូ មីងដែលមានវ័យចាស់ជរា ត្រូវតែមានការពិនិត្យ និងថែទាំសុខភាពឲ្យបានខ្ពស់ព្រោះរដូវនេះជារដូវធ្លាក់ខ្យល់ ហើយក្តៅ ដែលអាចងាយនឹងបង្កឲ្យមានជំងឺបានយ៉ាងឆាប់រហ័ស។



ថ្ងៃទី ១៧ ខែ ធ្នូ ឆ្នាំ ២០១៧ ឯកឧត្តម **ចាន់ ចេស្តា** អភិបាលនៃគណៈអភិបាលខេត្តកំពត លោកជំទាវអភិបាលរងខេត្ត បានដឹកនាំមន្ត្រីរាជការរួមទាំងថ្នាក់ដឹកនាំមន្ទីរជុំវិញខេត្ត ថ្នាក់ដឹកនាំស្រុក អាជ្ញាធរឃុំ និងកងកម្លាំងប្រដាប់អាវុធចុះជួយច្រូតកាត់ស្រូវជូនបងប្អូនប្រជាពលរដ្ឋ ដែលខ្វះខាតកម្លាំងពលកម្ម ស្ថិតនៅភូមិបឹងធំខាងលិច ឃុំអង្គសុរភី ស្រុកកំពង់ត្រាច ។ ឯកឧត្តមតែងតែយកចិត្តទុកដាក់ដឹកនាំមន្ត្រីរបស់រដ្ឋបាលខេត្ត ព្រមទាំងកងកម្លាំង ចុះជួយដល់ប្រជាពលរដ្ឋ ក្នុងការដកស្ទូង ភ្ជួររាស់ ច្រូត កាត់ ជាប់ជាប្រចាំ ដែលជាប្រពៃណីដ៏ល្អរបស់ ថ្នាក់ដឹកនាំដែលបានផ្សារភ្ជាប់សាមគ្គីល្អជាមួយប្រជាជន។

ថ្ងៃទី១៩ ខែធ្នូ ឆ្នាំ២០១៧ ឯកឧត្តម **ស ថាវី** សមាជិកគណកម្មាធិការកណ្តាលអភិបាល នៃគណៈអភិបាលខេត្តឧត្តរមានជ័យ បានជួបសំណេះសំណាល និងជូនដំណើរយុទ្ធជនស្ម័គ្រចិត្តចូលបម្រើក្នុងជួរកងយោធពលខេមរភូមិន្ទបំពេញក្របខណ្ឌ័ឲ្យយោធភូមិភាគទី១ កងទ័ពជើងគោក នៅខេត្តឧត្តរមានជ័យ ។





ថ្ងៃទី៨ ខែធ្នូ ឆ្នាំ២០១៧ ឯកឧត្តម **ឡាយ វណ្ណា:** សមាជិកគណៈកម្មាធិកាកណ្តាលគណបក្សប្រជាជនកម្ពុជា អភិបាលនៃគណៈអភិបាលខេត្តតាកែវ បានអញ្ជើញចុះសួរសុខទុក្ខកម្មការិនីចំនួន ១២៣នាក់ដួលសន្លប់ក្នុងរោងចក្រជេឌី & តូយូស៊ីមា ខូអិលធីឌី ស្ថិតនៅឃុំពត់ស ស្រុកបាទី និងនាំយកអំណោយសម្តេចកិត្តិព្រឹទ្ធបណ្ឌិត **ប៊ុន រ៉ានី ហ៊ុន សែន** ប្រធានកាកបាទក្រហមកម្ពុជា និងឯកឧត្តមឧបនាយករដ្ឋមន្ត្រីប្រចាំការ **ប៊ិន ឈិន** រដ្ឋមន្ត្រីស្តីទីនៃទីស្តីការគណៈរដ្ឋមន្ត្រី និងប្រធានក្រុមការងារថ្នាក់ជាតិចុះជួយខេត្តតាកែវ ទៅចែកជូនផង។



ថ្ងៃទី១៩ ខែធ្នូ ឆ្នាំ២០១៧ លោកជំទាវ **បាន ស្រីមុំ** អ្នកតំណាងរាស្ត្រមណ្ឌលប៉ៃលិន បានដឹកនាំក្រុមការងារចុះជួយប្រមូលទិន្នផលប្រជាពលរដ្ឋ ដែលមានជីវភាពខ្វះខាត គ្រួសារជនពិការ និងមិនមានលទ្ធភាពជួលកម្លាំងពលកម្ម នៅឃុំសាលាក្រៅ ស្រុកសាលាក្រៅ ខេត្តប៉ៃលិន ដោយមានការចូលរួមពីប្អូនៗសហភាពសហព័ន្ធយុវជនកម្ពុជាខេត្តប៉ៃលិនផងដែរ។ លោកជំទាវតែងតែគិតគូពីសុខទុក្ខរបស់ប្រជាពលរដ្ឋគ្រប់កាលៈទេសៈ ដោយតម្កល់ផលប្រយោជន៍ប្រជាពលរដ្ឋជាចម្បង និងលើកស្ទួយជីវភាព រស់នៅប្រជាពលរដ្ឋឲ្យកាន់តែល្អប្រសើរឡើងជាបណ្តើរៗ ក្រោមដំបូលសុខសន្តិភាព ស្ថេរភាព និងការអភិវឌ្ឍ របស់សង្គមជាតិ។

# សកម្មភាពរបស់ក្រុមការងារយុវជនគណបក្ស





កាលពីព្រឹកថ្ងៃទី០៣ ខែធ្នូ ឆ្នាំ២០១៧ នៅទីស្នាក់ការកណ្ដាលគណបក្សប្រជាជនកម្ពុជា (គ៨៥) ក្រុមការងារយុវជនគណបក្សនៃក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ ក្រោមការសម្របសម្រួលរបស់ឯកឧត្តមបណ្ឌិត **ហ៊ែល ចំរើន** ប្រធានក្រុមការងារយុវជនគណបក្សប្រចាំក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ បានរៀបចំបទបបកថាស្ដីពី "**សារតាបុព្វហេតុ និងទស្សនវិស័យនយោបាយរបស់គណបក្សប្រជាជនកម្ពុជា**" ឧទ្ទេសនាមដោយឯកឧត្តម **គាត ស៊ុនអ៊ី** ប្រធានគណៈឃោសនាអប់រំនៃគណៈកម្មាធិការកណ្ដាលគណបក្សប្រជាជនកម្ពុជាជូនយុវជនគណ-បក្សប្រចាំក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ ប្រមាណជាង ១000 រូប។ ពិធីនេះក៏មានការចូលរួមជាគណៈអធិបតីភាពដោយ ឯកឧត្តមបណ្ឌិតសភាចារ្យ **អូន ព័ន្ធមុនីរ័ត្ន** សមាជិកគណៈកម្មាធិការកណ្ដាលគណ-បក្សប្រជាជនកម្ពុជា និងជាប្រធានគណៈកម្មាធិការគណបក្សក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ, ឯកឧត្តម **កែ ម៉ុនខៀង** សមាជិក គណៈកម្មាធិការកណ្ដាល និងជាប្រធានក្រុមការងារយុវជនថ្នាក់កណ្ដាល។



*ថ្ងៃទី២៤ ខែវិច្ឆិកា ឆ្នាំ២០១៧ ក្រុមសកម្មជនយុវជនគណបក្សក្រសួងសាធារណការ និងដឹកជញ្ជូន បានបើកក្នុងវគ្គបណ្ដុះបណ្ដាលក្រោមប្រធានបទ* ***"យុវជនឆ្ពោះទៅកាន់ការបោះឆ្នោតឆ្នាំ២០១៨"*** *ក្រោមអធិបតីភាព ឯកឧត្តមទេសរដ្ឋមន្ត្រី* ***ស៊ុន ចាន់ថុល*** *ប្រធានគណៈកម្មាធិការគណបក្សក្រសួង និងបិទវគ្គបណ្ដុះបណ្ដាលនេះដោយឯកឧត្តម* ***កែ ម៉ុនខៀង*** *សមាជិកគណៈកម្មាធិការកណ្ដាល និងជាប្រធានក្រុមការងារយុវជនគណបក្សថ្នាក់កណ្ដាល។*



នៅព្រឹកថ្ងៃច័ន្ទ ទី១១ ខែធ្នូ ឆ្នាំ២០១៧ ឯកឧត្តម **កែ ម៉ុន ខៀង** ប្រធានក្រុមការងារយុវជនគណបក្សថ្នាក់កណ្ដាលឯកឧត្តម **ហ៊ុន ម៉ាណែត** អនុប្រធានក្រុមការងារយុវជនគណបក្សថ្នាក់កណ្ដាល ព្រមទាំងសមាជិក របស់ក្រុមការងារយុវជនគណបក្សថ្នាក់កណ្ដាល បានជួបពិភាក្សាការងារជាមួយគណៈប្រតិភូបក្សកុម្មុយនីស្តចិនដែលដឹកនាំដោយឯកឧត្តម Ou Yaping អគ្គលេខារងសាលាបក្ស នៃគណៈកម្មាធិការមជ្ឈិមបក្សកុម្មុយនីស្តចិន នាទីស្នាក់ការកណ្ដាលរបស់គណបក្សប្រជាជនកម្ពុជា (គ៨៥) ។



*នៅថ្ងៃអាទិត្យ ១៤រោច ខែមិគសិរ ឆ្នាំរកា ព.ស ២៥៦១ ព្រឹកថ្ងៃទី ១៧ ខែធ្នូ ឆ្នាំ២០១៧ គណៈកម្មាធិការគណបក្សខេត្តបាត់ដំបង បានរៀបចំពិធីប្រកាសស្ដីពីការបំពេញបន្ថែម សមាសភាពក្រុមការងារយុវជនគណបក្សខេត្តបាត់ដំបង ប្រកាសស្ដីពីការកែសម្រួល និងបំពេញបន្ថែមសមាសភាពក្រុមការងារយុវជនគណបក្សក្រុងបាត់ដំបង និងប្រកាសបញ្ចូលសមាជិកគណបក្សប្រជាជនកម្ពុជា នៃគណៈកម្មាធិការគណបក្សមូលដ្ឋានសាកលវិទ្យាល័យបាត់ដំបងចំនួន ៤៩១នាក់ ក្រោមអធិបតីភាពឯកឧត្តម* ***កែ ម៉ុនខៀង*** *សមាជិកគណៈកម្មាធិការកណ្ដាលគណបក្ស អនុប្រធានគណៈឃោសនាអប់រំ នៃគណៈកម្មាធិការកណ្ដាល និងជាប្រធានក្រុមការងារយុវជនគណបក្សថ្នាក់កណ្ដាល ឯកឧត្តម* ***ច័ន្ទ សុផល*** *សមាជិកគណៈកម្មាធិការកណ្ដាល គណបក្ស និងជាប្រធានគណៈកម្មាធិការគណបក្សខេត្តបាត់ដំបង នាទីស្នាក់ការគណបក្សខេត្តបាត់ដំបង ។*



នារសៀលថ្ងៃសៅរ៍ ៦រោច ខែមិគសិរ ឆ្នាំរកា ព.ស២៥៦១ ត្រូវនឹងថ្ងៃទី០៩ ខែធ្នូ គ.ស ២០១៧ ឯកឧត្តម **ឃឹម ម៉ុនសុខ** សមាជិកគណៈកម្មាធិការកណ្ដាល និងជាប្រធានគណៈកម្មាធិការគណបក្សខេត្តសៀមរាប អញ្ជើញចូលរួមក្នុងពិធីប្រកាសសុពលភាពក្រុមការងារយុវជនគណបក្សខេត្ត និងការបែងចែកភារកិច្ចក្រុមការងារយុវជនគណបក្សខេត្ត ចុះជួយក្រុង-ស្រុក ទាំង១២ ទូទាំងខេត្ត សៀមរាប។

# សកម្មភាពរបស់ក្រុមការងារយុវជនគណបក្ស



*ថ្ងៃទី០២ ខែធ្នូ ឆ្នាំ២០១៧ នៅទីស្នាក់ការគណបក្សស្រុកល្វាឯម បានបើកវគ្គអប់រំនយោបាយ និងផ្សព្វផ្សាយសភាពការណ៍ថ្មីៗនៅកម្ពុជា ជូនដល់យុវជនគណបក្សស្រុក ក្រោមអធិបតីភាព ឯកឧត្តម* ***កៅ ថាច*** *គណៈពង្រឹងស្រុកល្វាឯម និងមានការចូលរួមពីក្រុមគ្រូឧទ្ទេស របស់ក្រុមការងារយុវជនគណបក្សថ្នាក់កណ្ដាលដែលដឹកនាំដោយឯកឧត្តម* ***គង់ បូរ៉ា*** *សមាជិកក្រុមការងារយុវជនគណបក្សថ្នាក់កណ្ដាល ជូនដល់ក្រុមសកម្មជន ជាយុវជនចំនួន ២២០នាក់។*

ថ្ងៃច័ន្ទ ១រោច ខែមិគសិរ ឆ្នាំរកា នព្វស័ក ពុទ្ធសករាជ ២៥៦១ ត្រូវនឹងថ្ងៃទី០៤ ខែធ្នូ ឆ្នាំ២០១៧ មានប្រារព្ធពិធីប្រកាសបញ្ចូលសមាជិកគណបក្សប្រជាជនកម្ពុជាថ្មី ចំនួន ១១រូប (១រូប អតីតភាពគណបក្សសង្គ្រោះជាតិ) កម្មវិធីនេះប្រារព្ធឡើងនៅទីស្នាក់ការស្រុកបរិបូរណ៍ ខេត្តកំពង់ឆ្នាំង។





*នៅថ្ងៃទី ២៥-២៦ ខែ វិច្ឆិកា ឆ្នាំ ២០១៧ នៅស្នាក់ការគណបក្សស្រុករវៀង មានរៀបចំវគ្គបណ្ដុះបណ្ដាលក្រុមយុវជនគណបក្សចំនួន ៤ ឃុំគឺ ឃុំរស្មី រហ័ស រុងរឿង រីករាយ អ្នកចូលរួមសរុបចំនួន៩៥ នាក់ស្រី ៤៥ នាក់។ វគ្គបណ្ដុះបណ្ដាលនេះបានការឧបត្ថម្ភពី លោក* ***ពឹង ទ្រីដា*** *ប្រធានក្រុមការងារខេត្តចុះជួយស្រុក និងប្រធានក្រុមការងារចុះជួយឃុំរុងរឿង រហ័ស និងរីករាយ។*

ថ្ងៃទី២៤ ខែវិច្ឆិកា ឆ្នាំ២០១៧ នៅទីស្នាក់ការគណៈកម្មាធិការគណបក្សខេត្តកែប បានរៀបចំពិធីបញ្ចូលសមាជិកបក្សថ្មីជាយុវជនតាមមន្ទីរអង្គភាពចំនួន ០៥បន្ថែមទៀត និងកែសម្រួលសមាសភាពតាមសាខាបក្សសរុបចំនួន ២០៥នាក់។ ក្នុងពិធីនេះក៏មានការបញ្ចូលសមា-ជិកថ្មីជាបេក្ខជនឈរឈ្មោះ ដែលអតីតជាគណបក្សសង្គ្រោះជាតិ បានសុំវិលមករួមរស់ជាមួយគណបក្សប្រជាជនកម្ពុជាចំនួន ៥រូប ផងដែរ ៕





*កាលពីព្រឹកថ្ងៃទី២៥ ខែវិច្ឆិកា ឯកឧត្តមបណ្ឌិត* ***ជ្រុន ថេវ៉ាវ៉ាត*** *អនុប្រធានគណៈពង្រឹងស្រុកព្រៃឈរ និងជាប្រធានជនបង្គោលយុវជន បានអញ្ជើញជាអធិបតីក្នុងពិធីសំណេះសំណាល និងផ្សព្វផ្សាយអំពីស្ថានភាពនយោបាយបច្ចុប្បន្នដល់យុវជនស្រុក ព្រៃឈរចំនួន ៧៣១ នាក់ នៅទីស្នាក់ការបក្សស្រុកព្រៃឈរ ។ នាព្រឹកថ្ងៃទី០១ ខែធ្នូ ឆ្នាំ២០១៧ នៅឃុំកោះកែវ ស្រុកល្វាឯម ខេត្តកណ្ដាលក៏មានរៀបចំពិធីសំណេះ-សំណាល ផ្សព្វផ្សាយអំពីស្ថានការណ៍នយោបាយកម្ពុជាបច្ចុប្បន្ន ក្រោមអធិបតីភាព ឯកឧត្តម* ***សួន ម៉េងគា*** *អនុប្រធានទី២ គណៈពង្រឹងមូលដ្ឋាន ស្រុកល្វាឯមផងដែរ។*

ថ្ងៃព្រហស្បត្តិ៍ ១២កើត ខែមិគសិរ ឆ្នាំរកា នព្វស័ក ព.ស. ២៥៦១ ត្រូវនឹងថ្ងៃទី៣០ ខែវិច្ឆិកា ឆ្នាំ២០១៧ ក្រុមការងារយុវជនគណបក្សស្រុកភ្នំព្រឹក ខេត្តបាត់ដំបង បានរៀបចំកិច្ចប្រជុំជីវភាពប្រចាំខែវិច្ឆិកា ឆ្នាំ២០១៧ របស់ខ្លួននៅទីស្នាក់ការគណបក្សស្រុកភ្នំព្រឹក ក្រោមអធិបតីភាពលោក **ជា សុផាត** អនុប្រធានគណៈកម្មាធិការគណបក្សស្រុក និងលោក **ទូច សុគុណ** សមាជិកអចិន្ត្រៃយ៍គណបក្សស្រុក ដើម្បីត្រួតពិនិត្យលើសកម្មភាពកន្លងមក និងលើកផែនការសម្រាប់ខែធ្នូ ឆ្នាំ២០១៧។



# សមិទ្ធផលសំខាន់ៗមួយចំនួននៃវិស័យសេដ្ឋកិច្ច

**ក្នុងរយៈពេល៩ខែ ដើមឆ្នាំ២០១៧ នេះ :**

❋ចំណូលថវិកាជាតិអនុវត្តបានប្រមាណ ១១.៩៨០ ប៊ីលានរៀល និងចំណាយថវិកាជាតិអនុវត្តបានប្រមាណ ៩.៦១៧ ប៊ីលានរៀល ។ តុល្យភាពនៃថវិកាជាតិមានអតិរេក ២.៣៦២,៦ ប៊ីលានរៀល ។

❋ការងារពាណិជ្ជកម្មមានការនាំចេញចំនួន ៣៤.៧៦៤,៧ ប៊ីលានរៀល និងការនាំចូលមាន ៤១.០០៥,៩ប៊ីលានរៀល ។ ប្រតិបត្តិការជញ្ជីងពាណិជ្ជកម្មអន្តរជាតិរបស់កម្ពុជា មានឱនភាព ៦.២៤១,២ប៊ីលានរៀល ។

❋ផលនេសាទស្រស់នាំចេញអនុវត្តបាន ៦.៩៥០តោន ស្មើនឹង ៤៦,៣៣%នៃផែនការ ១៥.០០០តោន បើធៀបនឹងរយៈពេលឆ្នាំមុនកើនឡើង ១៥០តោន ។ ផលនេសាទកែច្នៃអនុវត្តបាន ៣.៨៨០តោន ស្មើនឹង ៧៧,៦០% នៃផែនការ ៥.០០០តោន ធៀបនឹងរយៈពេលដូចគ្នាឆ្នាំមុនកើនឡើង ១៨០តោន ។ ចំណូលពីវិស័យជលផលទទួល បាន ២.៥៧៧.១១១.១៨៣រៀល ស្មើនឹង ៨៥,៩០% នៃផែនការ ៣.០០០.០០០.០០០រៀល ធៀបនឹងរយៈពេល ដូចគ្នាឆ្នាំមុនកើនឡើង ៩៩២.៦៨៥.៥៤៣រៀល ។

**ក្នុងរយៈពេល ១១ខែ ដើមឆ្នាំ២០១៧ នេះ :**

❋កម្ពុជាប្រមូលផលជ័រកៅស៊ូបានចំនួន ១៥២.៩៦២តោន កើនឡើងចំនួន ៣៦.៦១៣តោន ស្មើនឹង៣១% បើធៀបនឹងរយៈពេលដូចគ្នាទៅនឹងឆ្នាំមុន និងទទួលបានថវិកាជិត ២៥០លានដុល្លារ ។ តម្លៃលក់ជ័រកៅស៊ូមធ្យមគឺ ១.៦២៥ដុល្លារ ក្នុង១តោន កើនឡើង ៤៥២ដុល្លារ ក្នុង១តោន ស្មើនឹង ៣៨% បើធៀបរយៈពេលដូចគ្នាកាលពីឆ្នាំមុន ។ គិតមកដល់ពេលនេះ កម្ពុជាមានផ្ទៃដីកៅស៊ូសរុបចំនួនជិត ៤៤ម៉ឺនហិកតា ក្នុងនោះផ្ទៃដែលអាចចៀរជ័របានចំនួន ១៧ម៉ឺនហិកតា និងផ្ទៃដីថែទាំជិត ២៧ម៉ឺនហិកតា ។

❋ចំណូលពន្ធ-អាករគ្រប់ប្រភេទ ដែលអគ្គនាយកដ្ឋានពន្ធដារប្រមូលបានមានចំនួន ៧.៣១០,៥១ពាន់លានរៀល (ប្រមាណ ១.៨២៧,៦៣លានដុល្លារអាមេរិក) ស្មើនឹង ១០៦,៥២% នៃគោលដៅកំណត់ក្នុងច្បាប់ហិរញ្ញវត្ថុសម្រាប់ការគ្រប់គ្រងឆ្នាំ២០១៧ ។ បើធៀបនឹងរយៈពេលដូចគ្នានៃឆ្នាំ២០១៦ ការប្រមូលចំណូលពន្ធ-អាករគ្រប់ប្រភេទ កើនឡើងចំនួន ១.៦៧៦,១៥ពាន់លានរៀល (ប្រមាណ ៤១៩,០៤លានដុល្លារ) ស្មើនឹង ២៩,៧៥% ។ មានការកើនឡើងនូវប្រាក់ពន្ធស្ទើរគ្រប់ប្រភេទពន្ធ ជាពិសេសប្រភេទពន្ធ-អាករសំខាន់ៗមានដូចជាពន្ធលើប្រាក់ចំណូលកើនឡើង៣១,១% អាករលើតម្លៃបន្ថែមកើនឡើង ២៩,៨% ខណៈដែលអាករពិសេសកើនឡើង ១៥,០% និងពន្ធលើប្រាក់បៀវត្សមានការកើនឡើងចំនួន ៨,៦% ។

❋ ការនាំចេញអង្ករមានចំនួន ៥៦២.២៣៧ តោន កើនឡើង ១៧,២០% បើធៀបនឹងរយៈពេល ដូចគ្នាឆ្នាំ២០១៦។ អង្ករកម្ពុជាត្រូវបាននាំចេញទៅកាន់ ៦៣ ប្រទេស ក្នុងនោះប្រទេសចិនឈរលំដាប់ទី១ មានចំនួន ១៦៤. ៩៧៦ តោន, ប្រទេសបារាំងឈរលំដាប់ទី២ មានចំនួន ៧០.៧៤១ តោន, ប្រទេសប៉ូឡូញ ឈរលំដាប់ទី៣ មានចំនួន ៤១.៤៦៩ តោន ។ បច្ចុប្បន្នការនាំចេញអង្ករមានចំនួន៨៤ក្រុមហ៊ុន។ គួរបញ្ជាក់ថា ការនាំចេញអង្កររបស់កម្ពុជាសរុបក្នុងឆ្នាំ២០១៦ មានចំនួន ៥៤២.១៤៤ តោន ធៀបនឹងឆ្នាំ២០១៥ ដែលការនាំចេញអង្ករមានចំនួន៥៣៨.៣៩៦តោន។ ឆ្នាំ២០១៤ ការនាំចេញអង្ករកម្ពុជា មានចំនួន ៣៨៧.០៦១ តោន និងឆ្នាំ២០១៣ ការនាំចេញអង្ករមាន ចំនួន៣៧៨.៨៥១។

❋ ភ្ញៀវទេសចរបរទេសចំនួន ២.១៨៩.៨០៤ នាក់បានទិញបណ្ណចូលទស្សនារមណីយដ្ឋានអង្គរក្នុងខេត្តសៀមរាប និងទទួលបានចំណូល៩៥.៦៦១.២៤១លានដុល្លារអាមេរិក។ចំនួនទេសចរបរទេស ទិញបណ្ណចូល ទស្សនាអង្គររយៈពេល ១១ខែ ឆ្នាំនេះ បានកើនឡើង ១២,៤៣% បើធៀបនឹងរយៈពេល ១១ ខែ កាលពីឆ្នាំ២០១៦។

- ក្នុងរយៈពេល១០ខែ ឆ្នាំ២០១៧ កម្ពុជាទទួលបានភ្ញៀវទេសចរអន្តរជាតិជាង ៤,៣លាននាក់ កើនបាន ជាង ១០% បើធៀបនឹងរយៈពេលដូចគ្នាឆ្នាំ២០១៦ ។ ក្រសួងទេសចរណ៍ព្យាករណ៍ថា នៅឆ្នាំ២០១៧នេះ កម្ពុជា នឹងទទួលបានភ្ញៀវទេសចរអន្តរជាតិ ៥,៥លាននាក់ នៅឆ្នាំ២០២០ និងទទួលបាន៧លាននាក់ ។

❋ ការងារបង្កបង្កើន ផលស្រូវរដូវវស្សាបានបញ្ចប់ដោយសម្រេចបាន ១០៦,៤៥% នៃ ផែនការ ២.៤៩៦.៧៩០ ហិកតា។ ក្នុងនោះ ការប្រើប្រាស់ដោយគ្រឿងយន្តសម្រាប់ផលិតកម្មកសិកម្មគឺស្មើនឹង ៩៣,៧៣% ធៀបនឹងការប្រើប្រាស់ដោយគោក្របី មាន ៦,២៧%។ ការប្រមូលផលស្រូវរដូវវស្សារហូតដល់ពេលនេះ សម្រេចបានចំនួន ១.២៧៥. ៤៣០ ហ.ត លើផ្ទៃដីអនុវត្តសរុប ២.៦៥៧.៧៦៨ ហ.ត ដោយទទួល បានបរិមាណផលសរុបចំនួន ៤.០៧២.៤០៨ តោន លើសឆ្នាំមុន ចំនួន ៥២៦.២៨៩ តោន។ ទិន្នផលគិតជាមធ្យម ៣,១៩៣ តោន / ហ.ត លើសឆ្នាំមុន ២២ គ.ក្រ / ហ.ត ៕

# ថវិកាឆ្នាំ២០១៨ ជាថវិកាយុទ្ធសាស្ត្រនៃការពូនផ្តុំកម្លាំង និងធនធានជាអតិបរមា ដើម្បីការអភិវឌ្ឍ ប្រកបដោយគុណភាព និងចីរភាព




*សម័យប្រជុំរដ្ឋសភាលើកទី៩ នីតិកាលទី៥ ធ្វើការពិភាក្សា និងអនុម័តសេចក្តីព្រាងច្បាប់ស្តីពីហិរញ្ញវត្ថុសម្រាប់ការគ្រប់គ្រងឆ្នាំ ២០១៨ និងទូទាត់ថវិកាជាតិ ឆ្នាំ២០១៦*

សេចក្តីព្រាងច្បាប់ស្តីពីហិរញ្ញវត្ថុសម្រាប់ការគ្រប់គ្រងឆ្នាំ២០១៨ និងទូទាត់ថវិកាជាតិ ឆ្នាំ២០១៦ ត្រូវបានអង្គប្រជុំគណៈរដ្ឋមន្ត្រី ពិភាក្សា និងអនុម័តនៅថ្ងៃទី២៧ ខែតុលា ឆ្នាំ២០១៧ ហើយច្បាប់នេះត្រូវបានរដ្ឋសភាសម័យប្រជុំលើកទី៩ នីតិកាលទី៥ ធ្វើការពិភាក្សា និងអនុម័តនៅថ្ងៃទី១៧ ខែវិច្ឆិកាឆ្នាំ២០១៨ ។

ថវិកាឆ្នាំ២០១៨ គឺជាឧបករណ៍ដ៏មានប្រសិទ្ធភាពមួយក្នុងការជួយឲ្យរាជរដ្ឋាភិបាល អាចឆ្លើយតបទៅនឹងបំណងប្រាថ្នារបស់ប្រជាជន និងអាចសម្រេចបុព្វហេតុចម្បងៗរបស់ខ្លួន ជាពិសេសការបង្កើន ល្បឿននៃការអភិវឌ្ឍ ការលើកកម្ពស់ប្រសិទ្ធភាពសេវាសាធារណៈ និងការចូលរួមដោះស្រាយបញ្ហាជា ច្រើនទៀតរបស់ជាតិ និងប្រជាជន ។ យោងតាមច្បាប់នេះបង្ហាញថា ក្របខណ្ឌថវិកាឆ្នាំ២០១៨ **គឺចំណូលក្នុងប្រទេស ថវិការដ្ឋ ឬថវិកាជាតិ** ត្រូវបានគ្រោងចំនួន ១៨.៥៨៧.០០៣ លានរៀល ស្មើនឹង ១៨,៧៥% នៃ ផ.ស.ស និងមានកំណើន ១១,៩% ធៀបនឹងច្បាប់ឆ្នាំ២០១៧ ឯ**ចំណាយសរុបថវិការដ្ឋ ឬថវិកាជាតិ** ត្រូវបានគ្រោងចំនួន ២៤.៣៧៥.១០២លានរៀល ស្មើនឹង ២៤,៥៩% នៃផ.ស.ស និងមានកំណើន ១៥,២% ធៀបនឹងច្បាប់ឆ្នាំ២០១៧ ។ ជា**លទ្ធផលអតិរេកថវិកា ចរន្ត**អាចរក្សាបានក្នុងកម្រិតប្រមាណ ២,៤៨% នៃផ.ស.ស នៅឆ្នាំ២០១៨ និងមានឱនភាពថវិកា សរុបស្មើនឹង -៥,៨៤% នៃផ.ស.ស ស្របតាមគោលនយោបាយវិត្តារកម្មថវិកាប្រយ័ត្នប្រយែងរបស់រាជរដ្ឋាភិបាល ។ ទំហំសេដ្ឋកិច្ចជាតិ (ផ.ស.សតាមថ្លៃបច្ចុប្បន្ន) បានកើនឡើងពី ៦១.៣២៦.៩២៨ លានរៀលឬសមមូលនឹងប្រមាណ១៥.២៣៧លានដុល្លារអាមេរិក ក្នុងឆ្នាំ២០១៣ ដល់ ៨៩.៥០៩.៤២២លានរៀល ឬសមមូលនឹងប្រមាណជាង ២២.១៧២លានដុល្លារអាមេរិក ក្នុងឆ្នាំ២០១៧ ហើយនឹងបន្តឡើងដល់ ៩៩.១១៦.០៤១លានរៀល សមមូលនឹងប្រមាណជាង ២៤.៥៥២លានដុល្លារអាមេរិក នៅឆ្នាំ២០១៨ ។

នៅក្នុងទិសដៅជាយុទ្ធសាស្ត្រកំណត់ចំណាយថវិកាថ្នាក់ជាតិនេះដែរគឺ: **ចំណាយលើបន្ទុកបុគ្គលិក** ត្រូវបានគ្រោងចំនួន ៧.៩១៤.៩២៤លានរៀល សម្រាប់(១)-ការដំឡើងបៀវត្សមូលដ្ឋានក្នុងអត្រា ១២,០% តាមតម្លៃឯកតាសន្ទស្សន៍ ២.១៣០រៀល ដោយអនុវត្តចាប់ពីខែមករា ឆ្នាំ២០១៨, (២)-ការដំឡើងប្រាក់ដំណាច់មុខងារនឹងត្រូវអនុវត្តចាប់ពីខែមេសាឆ្នាំ២០១៨តាមកម្រិតចន្លោះពី ៤០.០០០រៀល ទៅ ១០០. ០០០រៀល, (៣)-ការដំឡើងប្រាក់ឧបត្ថម្ភប្រចាំខែសម្រាប់មន្ត្រីជាប់កិច្ចសន្យាពី ៥០០.០០០រៀល ទៅដល់ ៦០០.០០០រៀល ដោយអនុវត្តចាប់ពីខែមករា ដល់ខែធ្នូ ឆ្នាំ២០១៨, (៤)-ការដំឡើងរបបសោធនប្រចាំខែទាបបំផុតពី ៤២០.០០០រៀល ទៅដល់ ៤៨០.០០០រៀល ជូនដល់និវត្តជនដែលជាអតីតមន្ត្រី រាជការស៊ីវិល និងកងកម្លាំងប្រដាប់អាវុធ ព្រមទាំងផ្តល់បន្ថែមចន្លោះពី ២០.០០០រៀល និង ៤០.០០០រៀល ជូនដល់និវត្តជនដោយផ្អែកលើកម្រិតរបបសោធនប្រចាំខែ ដោយគិតចាប់ពីខែមេសា ឆ្នាំ២០១៨ ។

ជារួមនៅឆ្នាំ២០១៨ បៀវត្សអប្បបរមារបស់មន្ត្រីរាជការស៊ីវិល និងកងកម្លាំងប្រដាប់អាវុធនឹងត្រូវបានកើនឡើងជិត ៣ដង ធៀបនឹងឆ្នាំ២០១៣ ដែលមានស្ថានភាពផ្លាស់ប្តូរដូចខាងក្រោម៖

- **បៀវត្សមន្ត្រីរាជការស៊ីវិល** នឹងត្រូវបានតម្លើងពីចំនួន ៨៥៣. ៥០០រៀល នៅឆ្នាំ២០១៧ ដល់ប្រមាណ ៩១៤.៤៥០រៀល នៅខែមករា ឆ្នាំ២០១៨ ហើយនឹងត្រូវបានដំឡើងដល់ប្រមាណ ១.០១៤ ៤៥០រៀល ចាប់ពីខែមេសា ឆ្នាំ២០១៨ បើធៀបឆ្នាំ ២០១៣ បៀវត្សនេះមានត្រឹម ៣៤៤.០០០ រៀល ប៉ុណ្ណោះ

- **បៀវត្សគ្រូបង្រៀន និងគ្រូពេទ្យ** នឹងត្រូវបានដំឡើងពីចំនួន ៩៥៣.៥០០រៀល នៅឆ្នាំ២០១៧ ដល់ប្រមាណ ១.០១៤.៤៥០រៀល នៅខែមករា ឆ្នាំ២០១៨ ហើយនឹងត្រូវបានដំឡើងដល់ប្រមាណ ១.១១៤.៤៥០រៀល ចាប់ពីខែមេសា ឆ្នាំ២០១៨ បើធៀបឆ្នាំ២០១៣ បៀវត្សគ្រូបង្រៀនមានត្រឹម ៤០០.០០០រៀល និងបៀវត្សគ្រូពេទ្យមានត្រឹម ៣៦០.០០០រៀល ប៉ុណ្ណោះ

- **បៀវត្សនគរបាល (ពលបាលត្រី)** នឹងត្រូវបានដំឡើងពីចំនួន ៩៣៧.៩៧៧រៀល (គិតបញ្ចូលទាំងរបបអង្គរ) នៅឆ្នាំ២០១៧ ដល់ប្រមាណ ៩៩៨.៩២៧រៀល (គិតបញ្ចូលទាំងរបបអង្គរ) នៅខែមករា ឆ្នាំ២០១៨ ហើយនឹងត្រូវបានដំឡើងដល់ប្រមាណ ១.០៩៨.៩២៧.រៀល (គិតបញ្ចូលទាំងរបបអង្គរ) ចាប់ពីខែមេសា ឆ្នាំ២០១៨ បើធៀបឆ្នាំ២០១៣ បៀវត្សនេះមានត្រឹម ៣៨០.០០០ រៀលប៉ុណ្ណោះ

-**បៀវត្សយោធិន (ពលទោ)** នឹងត្រូវបានដំឡើងពីចំនួន ៨២២.៥០០រៀល (មិនគិតបញ្ចូលរបបអង្គរ) នៅឆ្នាំ២០១៧ ដល់ប្រមាណ ៨៧៦.៥៥០.រៀល (មិនគិតបញ្ចូលរបបអង្គរ) នៅខែមករា ឆ្នាំ ២០១៨ ហើយនឹងត្រូវបានដំឡើងដល់ ៩៧៦.៥៥០រៀល ចាប់ពីខែមេសា ឆ្នាំ២០១៨ បើគិតបញ្ចូលរបបអង្គរត្រូវជាប្រមាណ ១.០៣៥.០២៧រៀល បើធៀបឆ្នាំ២០១៣ បៀវត្សនេះមានត្រឹម ៣១៦.០០០រៀល ប៉ុណ្ណោះ ។

ទន្ទឹមនេះ រាជរដ្ឋាភិបាលក៏បានកែសម្រួលនូវកម្រិតអប្បបរមានៃប្រាក់បៀវត្សជាប់ពន្ធលើប្រាក់បៀវត្ស ដើម្បីអនុគ្រោះដល់មន្ត្រីរាជការ គ្រូបង្រៀន គ្រូពេទ្យ និងកម្មករនិយោជិត ដែលទទួលបានប្រាក់បៀវត្ស ១.២០០.០០០រៀល ឬ តិចជាងឲ្យរួចផុតពីការបង់ពន្ធលើប្រាក់បៀវត្ស ។

ក្រៅពីបានដំឡើងប្រាក់បៀវត្សជូនមន្ត្រីរាជការ និងកងកម្លាំងប្រដាប់អាវុធជាង ១លានរៀល រាជរដ្ឋាភិបាលក៏បានគ្រោង**ថវិកាចំនួន ៣០.០០០លានរៀល សម្រាប់រៀបចំជាមូលនិធិថែទាំសុខភាពជូនមន្ត្រីរាជការស៊ីវិល កងកម្លាំងប្រដាប់អាវុធគ្រប់ប្រភេទ និងនិវត្តជន** ។ ទន្ទឹមនឹងនេះ រាជរដ្ឋាភិបាលបានសម្រេចផ្ដល់ និងដំឡើងប្រាក់ឧបត្ថម្ភគោលនយោបាយគាំពារសង្គមចំនួន ២ទៀត ដោយអនុវត្តចាប់ពីខែមករា ឆ្នាំ ២០១៨ ដែលរួមមាន៖

- **ផ្ដល់ប្រាក់ឧបត្ថម្ភមាតុភាពដល់មន្ត្រីរាជការស៊ីវិល និងកងកម្លាំងប្រដាប់អាវុធគ្រប់ប្រភេទជាស្ត្រី** ដោយបង្កើនពី ៦០០.០០០រៀល ទៅចំនួន ៨០០.០០០រៀល សម្រាប់ការសម្រាលបានកូនមួយ និងចំនួន ១.៦០០.០០០រៀល សម្រាប់ការសម្រាលបានកូនភ្លោះពីរ និងចំនួន ២.៤០០.០០០រៀល សម្រាប់ការសម្រាលបានកូនភ្លោះបី

- **ផ្ដល់ប្រាក់ឧបត្ថម្ភបុណ្យសពមន្ត្រីរាជការស៊ីវិល ដែលទទួលមរណភាព** ដោយក្នុងម្នាក់ៗត្រូវបានដំឡើងពីចំនួន ១.២០០.០០០រៀល ទៅ ២.០០០.០០០រៀល ចំពោះមរណភាពដោយជម្ងឺធម្មតា និងដំឡើងពីចំនួន ១.៥០០.០០០រៀល ទៅ ៤.០០០.០០០រៀល ចំពោះមរណភាពក្នុងពេលបំពេញបេសកកម្ម ឬគ្រោះថ្នាក់ការងារ ។

ដោយឡែក ចំណាយមិនមែនបន្ទុកបុគ្គលិកត្រូវបានគ្រោងចំនួន៧.៣០៣.២៤៣លានរៀល,មានសមាមាត្រស្មើនឹង៤៨,០% នៃចំណាយចរន្តថវិកាថ្នាក់ជាតិ ត្រូវជា ៧,៣៧% នៃផ.ស.ស គឺមានកំណើន ១៦,៩% ធៀបនឹងច្បាប់ឆ្នាំ២០១៧, ហើយត្រូវបានវិភាជដោយផ្អែកលើតម្រូវការ និងអាទិភាពចាំបាច់តាមវិស័យនីមួយៗ ។

តាមការព្យាករណ៍កំណើនសេដ្ឋកិច្ចកម្ពុជានៅឆ្នាំ២០១៨ នឹងអាចបន្តសម្រេចបានប្រមាណ ៦,៩% ដូចឆ្នាំ២០១៧ ដែលធ្វើឲ្យ ផ.ស.ស តាមថ្លៃបច្ចុប្បន្នកើនឡើងដល់ ៩៩.១១៦.០៤១លានរៀល ប្រមាណជា ២៤.៥៥២លានដុល្លារអាមេរិក ខណៈដែល ផ.ស.ស សម្រាប់មនុស្សម្នាក់ត្រូវបានរំពឹងថានឹងកើនឡើងដល់ ១.៥៦៨ដុល្លារអាមេរិក ។ **អត្រាអតិផរណាមធ្យមប្រចាំឆ្នាំ** ត្រូវបានប៉ាន់ស្មានថា នឹងមានការកើនឡើងបន្តិចក្នុងអត្រា ៣,៨% ក្នុងឆ្នាំ ២០១៧ និង ៣,៥% ក្នុងឆ្នាំ២០១៨ ដោយសារការងើបឡើងវិញជាបណ្ដើរៗនៃថ្លៃប្រេងលើទីផ្សារអន្តរជាតិ និងថ្លៃកសិផលមួយចំនួន ។ ចំណែកឯអត្រាប្ដូរប្រាក់រៀល គឺនៅតែបន្តស្ថិតនៅក្នុងរង្វង់ ៤.០៣៧រៀល ក្នុងមួយដុល្លារអាមេរិក ក្នុងឆ្នាំ២០១៧ និង២០១៨ ។ ឱនភាពគណនីចរន្តនៃជញ្ជីងទូទាត់ក្រៅប្រទេសត្រូវបានព្យាករថាអាចនឹងកើនឡើងដល់ ៨,៤% នៃផ.ស.ស នៅឆ្នាំ២០១៨ ធៀបនឹង ៧,៩% នៃផ.ស.ស នៅឆ្នាំ២០១៧ ដោយសារការរំពឹងទុកនៃការថមថយនៃឥណទាន ដែលបានមកពីប្រភពហិរញ្ញប្បទានឥតសំណង ក្រោមហេតុផលថាកម្ពុជាបានប្រែក្លាយខ្លួនជាប្រទេសមានប្រាក់ចំណូលមធ្យមកម្រិតទាប ខណៈដែលឱនភាពពាណិជ្ជកម្មបានធ្លាក់ចុះពី ១៥,៤% នៃផ.ស.សក្នុងឆ្នាំ ២០១៧ មកត្រឹម ១៥% នៃផ.ស.ស ក្នុងឆ្នាំ២០១៨ ដែលឆ្លុះបញ្ចាំងនូវពិពិធកម្មផលិតផលនាំចេញ ។ ទុនបម្រុងអន្តរជាតិត្រូវបានប៉ាន់ស្មានថានឹងកើនឡើងដល់ ៩.០៥០លានដុល្លារអាមេរិក នៅឆ្នាំ២០១៧ និងព្យាករថានឹងបន្តកើនឡើងដល់ ១០.៥១៨ លានដុល្លារអាមេរិក នៅក្នុងឆ្នាំ ២០១៨ ដែលធានាបាននូវការនាំចូលប្រមាណ ៦,៥ខែ នៅឆ្នាំ ២០១៨ ។ ផ្អែកលើសូចនាករម៉ាក្រូសេដ្ឋកិច្ចដូចដែលបានកំណត់ខាងលើ យើងអាចនិយាយបានថា កម្ពុជានៅតែអាចបន្តសម្រេចបាននូវកំណើនសេដ្ឋកិច្ចក្នុងរង្វង់ ៧,០% ក្នុងមួយឆ្នាំនៅក្នុងរយៈពេលខ្លី និងមធ្យមខាងមុខ ។

សរុបមកថវិកាឆ្នាំ២០១៨ អាចប្រសិទ្ធនាមបានថា ជាថវិកាយុទ្ធសាស្ត្រនៃការពូនផ្ដុំកម្លាំង និងធនធានជាអតិបរមា ដើម្បីសម្រេចឲ្យខាងតែបាននូវគោលដៅសំខាន់ៗនៃកម្មវិធីនយោបាយរបស់រាជរដ្ឋាភិបាលនីតិកាលទី៥នៃរដ្ឋសភា នៅក្នុងសភាពការណ៍តំបន់ និងពិភពលោក ដែលកាន់តែមានភាពស្មុគស្មាញ ដើម្បីបន្តរក្សាសន្តិភាព ស្ថិរភាព ក៏ដូចជាការទ្រទ្រង់នូវដំណើរការវិវឌ្ឍន៍ឈានឡើងរបស់កម្ពុជាលើវិថី នៃការអភិវឌ្ឍប្រកបដោយគុណភាព និងចីរភាពតទៅមុខឥតឈប់ឈរក្នុងនីតិកាលបន្តបន្ទាប់ទៀត ៕

# ចក្ខុវិស័យ និងផែនការការងារវិស័យសាធារណការ និងដឹកជញ្ជូនសម្រាប់រយៈពេលខាងមុខ



*ឯកឧត្តម **ស៊ុន ចាន់ថុល** ទេសរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងសាធារណការ និងដឹកញ្ជូន អញ្ជើញចូលរួមពិធីសម្ពោធមណ្ឌលត្រួតពិនិត្យលក្ខណៈបច្ចេកទេសយានជំនិះសាខាជ្រោយចង្វារ*

រាជរដ្ឋាភិបាលដឹកនាំដោយ**សម្ដេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន** នាយករដ្ឋមន្ត្រីនៃព្រះរាជាណាចក្រកម្ពុជា បាននិងកំពុងអនុវត្តកម្មវិធីកំណែទម្រង់ស៊ីជម្រៅលើគ្រប់វិស័យ។ក្នុងនោះកំណែទម្រង់វិស័យសាធារណការ និងដឹកជញ្ជូន មិនត្រឹមតែដើរតួនាទីសំរាប់ជំរុញដល់កំណើនសេដ្ឋកិច្ចនិងការបង្កើតការងារ ប៉ុណ្ណោះទេ ប៉ុន្តែវិស័យនេះក៏បានរួមចំណែកយ៉ាងសំខាន់នៅក្នុងការកាត់បន្ថយភាពក្រីក្រផងដែរ ។

ឯកឧត្តមទេសរដ្ឋមន្ត្រី **ស៊ុន ចាន់ថុល** រដ្ឋមន្ត្រីក្រសួងសាធារណការ និងដឹកជញ្ជូនបានអោយដឹងថាសមិទ្ធផលធំៗដ៏រឹងមាំនៃវិស័យសាធារណការ និងដឹកជញ្ជូន ដែលសម្រេចបានក្នុងរយៈពេលកន្លងមកមានដូចជា ការស្តារសាងសង់ ជួសជុលផ្លូវថ្នល់ ស្ពាននិងអភិវឌ្ឍន៍ផ្លូវដែក ស្តារផ្លូវទឹក សាងសង់ និងពង្រឹងសមត្ថភាពកំពង់ផែ និងការពង្រឹងសុវត្ថិភាពចរាចរណ៍មានវឌ្ឍនភាពគួរឲ្យកត់សម្គាល់។ ដោយខ្សែបណ្តាញដឹកជញ្ជូនជាយុទ្ធសាស្ត្រត្រូវបានតភ្ជាប់រវាងតំបន់នានានៅទូទាំងប្រទេសក៏ដូចជា ប្រទេសជិតខាង ដែលជាកត្តាដ៏សំខាន់សម្រាប់ទ្រទ្រង់កំណើនសេដ្ឋកិច្ច បង្កើនប្រសិទ្ធភាពសេដ្ឋកិច្ច ព្រមទាំងពង្រឹងភាពប្រគួតប្រជែង និងការកាត់បន្ថយភាពក្រីក្ររបស់ប្រជាជន ។ ការអនុវត្តកិច្ចព្រមព្រៀងស្តីពីការដឹកជញ្ជូនឆ្លងកាត់ព្រំដែនរវាងប្រទេសជាប់ព្រំដែនជាមួយព្រះរាជាណាចក្រកម្ពុជា មានភាពរលូន និងមានសន្ទុះកើនឡើងជាលំដាប់ នៃចំនួនកូតាយានយន្តធ្វើប្រតិបត្តិការ ឆ្លងកាត់ព្រំដែន ។

ក្រសួងសាធារណការ និងដឹកជញ្ជូនក៏ទទួលបានជោគជ័យក្នុងការអនុវត្តយន្តការនៃការផ្តល់សេវាសាធារណៈ ដោយត្រូវបានពង្រឹង និងពង្រីក ប្រកបដោយតម្លាភាព គុណភាព ប្រសិទ្ធភាព គណនេយ្យភាព មានភាពរហ័ស តម្លៃថោក និងនៅជិតកៀកនឹងប្រជាជន ។ ឯកឧត្តមទេសរដ្ឋមន្ត្រី **ស៊ុន ចាន់ថុល** រដ្ឋមន្ត្រីក្រសួង សាធារណការ និងដឹកជញ្ជូនបានលើកឡើងថា គិតចាប់ពីដើម ឆ្នាំ២០១៧ រហូតមកទល់បច្ចុប្បន្ននេះ ក្រសួងបានជួយដោះស្រាយការលំបាកមួយចំនួន ជូនដល់ប្រជាពលរដ្ឋកម្ពុជារួមមាន៖

ការដាក់ឲ្យដំណើរការមណ្ឌលប្តូរ និងពន្យារបណ្ណបើកបរនៅផ្សារទំនើបអ៊ីអនម៉ល (AEON Mall) ភ្នំពេញ ដោយចំណាយពេលប្រមាណ ១៥នាទី ដើម្បីទទួលបានបណ្ណបើកបរ។ ការបិតផ្លាកសុវត្ថិភាព ស្ទីគ័រចំណាំងផ្លាតពន្លឺពេលយប់បាន ចំនួន៣,៤លាន សន្លឹក។ យុទ្ធនាការចែកមួកសុវត្ថិភាព។ ការរៀបចំរចនាសម្ព័ន្ធអង្គការលេខរបស់ក្រសួងឡើងវិញដើម្បីបំពេញការងារឱ្យកាន់តែមានប្រសិទ្ធភាព។ ការដាក់ឲ្យដំណើរការចុះបញ្ជីយានយន្តតាមប្រព័ន្ធស្វ័យប្រវត្តិកម្ម។ការផ្តល់ប័ណ្ណបើកយានយន្ត និងអប់រំ។ អប់រំកម្មវិធីយល់ដឹងអំពីទ្រឹស្តីនៃការបើកលើទូរសព្ទឈៀកចល័ត និងផ្លាកលេខយានយន្តដែលមាន យូអរ កូត (QR Code) ដើម្បីកាត់បន្ថយការក្លែងបន្លំ។ ឯកឧត្តមទេសរដ្ឋមន្ត្រី **ស៊ុន ចាន់ថុល** រដ្ឋមន្ត្រីក្រសួងសាធារណការ និងដឹកជញ្ជូនបានលើក ឡើងទៀត អំពីគម្រោងផែនការដែលត្រូវអនុវត្តនាពេលខាងមុខដូចជា៖ ការសាងសង់ផ្លូវរថភ្លើងពីភ្នំពេញទៅព្រលានយន្តហោះ ដើម្បីកាត់បន្ថយការកកស្ទះចរាចរណ៍ ដែលគ្រោងដាក់ឲ្យដំណើរក្នុងពេលឆាប់ៗ, ការដឹកជញ្ជូនតាមផ្លូវ-ទឹក, ការរៀបចំក្របខណ្ឌស្ថាប័ន ទទួលបន្ទុកភស្តុភារកម្ម ដើម្បីកាត់បន្ថយថ្លៃដឹកជញ្ជូន, ការធ្វើសមាហរណកម្មទូទាំងប្រទេសតាមរយៈការកសាង និងពង្រីកបណ្តាញផ្លូវតភ្ជាប់, ការកសាងផ្លូវ រថភ្លើង, ការគ្រប់គ្រងការដឹកជញ្ជូនលើសទម្ងន់កម្រិតកំណត់,ការកសាងកំពង់ផែទឹកជ្រៅ។ ជំរុញការអនុវត្តច្បាប់ឲ្យកាន់តែមានសុវត្ថិភាពនិងវិបុលភាពថែមទៀត និងបានលើកទឹកចិត្តឲ្យប្រជាពលរដ្ឋទាំងអស់ ចូលរួមឲ្យបានសស្រាក់សស្រាំក្នុងការអនុវត្តច្បាប់ចរាចរណ៍ផ្លូវគោក ដើម្បីជួយកាត់បន្ថយគ្រោះថ្នាក់ចរាចរណ៍ និងការកកស្ទះចរាចរណ៍នៅក្នុងប្រទេស។

គួរបញ្ជាក់ថា ក្នុងឆ្នាំ ២០១៨ នេះកំណាត់ផ្លូវជាតិលេខ ៥៥ ដែលតភ្ជាប់ពីផ្លូវជាតិលេខ ៥ ឆ្លងកាត់ ស្រុកវាលវែង ខេត្តពោធិ៍សាត់ ទៅកាន់ច្រកព្រំដែនកម្ពុជា-ថៃ គឺច្រកថ្មដា ប្រវែង ១៨២ គីឡូម៉ែត្រ នឹងបញ្ចប់ការសាងសង់ ដែលផ្លូវនេះ នឹងជំរុញសេដ្ឋកិច្ចរបស់កម្ពុជាកើនឡើងបន្ថែមទៀតផងដែរ ។

ក្នុងឱកាសបើកសម្ពោធមណ្ឌលត្រួតពិនិត្យលក្ខណៈបច្ចេកទេសយានជំនិះសាខាជ្រោយចង្វានៅថ្ងៃទី២១ ខែធ្នូ ឆ្នាំ២០១៧ នេះ ឯកឧត្តមទេសរដ្ឋមន្ត្រី **ស៊ុន ចាន់ថុល** រដ្ឋមន្ត្រីក្រសួង សាធារណការ និងដឹកជញ្ជូនបានបញ្ជាក់ថា មុនចូលឆ្នាំថ្មីប្រពៃណីជាតិខ្មែរខាង មុខនេះ យើងនឹងតភ្ជាប់ផ្លូវស្ថានីយ៍រថភ្លើង ពីស្ថានីយភ្នំពេញទៅព្រលានយន្តហោះ ដោយមានក្បាលរថភ្លើងចំនួនបីគ្រឿងដែលមួយគ្រឿងដឹកបានប្រហែល១០០នាក់។ ប្រជាពលរដ្ឋធ្វើដំណើររយៈពេល៣ខែ ដោយឥតគិតថ្លៃថែមទៀតផង។ យើងក៏មានគម្រោងកសាងកំពង់ផែទឹកជ្រៅនៅខេត្តព្រះសីហនុ រហូតដល់ ១៤.៥ម៉ែត្រផងដែរ។ កំពង់ផែទឹកជ្រៅថ្មីនេះ អាចឲ្យកប៉ាល់ធំៗទូទាំងពិភពលោកចូលចតបានដោយត្រៀមបញ្ចប់ការសាងសង់នៅឆ្នាំ២០២២។ ឯកឧត្តមទេសរដ្ឋមន្ត្រីបានបញ្ជាក់ថា ក្រសួងសាធារណការ និងដឹកជញ្ជូនសហការជាមួយក្រុមហ៊ុនឯកជននានាបង្កើតប្រព័ន្ធអនឡាញ ដើម្បីស្នើសុំ

តទៅទំព័រទី ២៨

# អំពីមហាសន្និបាតតំណាងទូទាំងប្រទេសលើកទី ១៩ របស់បក្សកុម្មុយនីស្តចិន



ឯកឧត្តម វ៉ាង វៃត័ង ៖ ប្រធានបណ្ឌិតសភាវិទ្យាសាស្ត្រសង្គមចិន

មហាសន្និបាតតំណាងទូទាំងប្រទេសលើកទី១៩ ត្រូវបានប្រារព្ធធ្វើឡើងនៅរដ្ឋធានីប៉េកាំង កាលពីថ្ងៃទី១៨ ដល់ថ្ងៃទី២៤ ខែតុលា ឆ្នាំ២០១៧។ ពិភពលោកទាំងមូលយល់ឃើញជាទូទៅថា មហាន្និបាតនេះជាមហាសន្និបាតដ៏មានសារៈសំខាន់ណាស់ ដែលធ្វើឡើងក្នុងដំណាក់កាលសំខាន់ ដើម្បីដណ្ដើមយកជោគជ័យនៃការកសាង សង្គមមានធូរធារគ្រប់ជ្រុងជ្រោយ និងសង្គមនិយមប្រកបដោយ លក្ខណៈពិសេសចិនឈានចូលយុគសម័យថ្មី។ ក្នុងមហាសន្និបាតនេះ ឯកឧត្តម **ស៊ី ជីនពីង** អគ្គលេខាបក្សកុម្មុយនីស្តចិនបានថ្លែងលើកឡើងប្រព័ន្ធគំនិត និងផែនការសកម្មភាព ដែលមានលក្ខណៈគ្រប់ជ្រុងជ្រោយយុទ្ធសាស្ត្រនិងសម្លឹងឆ្ពោះទៅមុខ។ គតិសង្គមនិយមប្រកបដោយលក្ខណៈពិសេសចិនក្នុងយុគសម័យថ្មីរបស់ឯកឧត្តម **ស៊ី ជីនពីង** ត្រូវបានចម្លងទៅក្នុងលក្ខន្តិកៈបក្ស។ ក្រៅពីនេះ ក៏ធ្វើការជ្រើសរើសស្ថាប័នដឹកនាំនៃមជ្ឈិមបក្សអាណត្តិថ្មី។ ឯកឧត្តម **ស៊ី ជីនពីង** ត្រូវបានជ្រើសតាំងជាអគ្គលេខាបក្សជាថ្មីម្តងទៀត ។

មហាសន្និបាតលើកនេះ បានបូកសរុបសមិទ្ធផលដ៏អស្ចារ្យ ដែលប្រទេសចិនសម្រេចបានបន្ទាប់ពីមហាសន្និបាតលើកទី១៨ ។ ៥ឆ្នាំ កន្លងទៅនេះ សេដ្ឋកិច្ចពិភពលោកងើបឡើងវិញ ដោយទន់ខ្សោយការប៉ះទង្គិច និងជម្លោះក្នុងតំបន់តែងតែកើតឡើង បញ្ហាពិភពលោកកាន់តែធ្ងន់ធ្ងរ ការអភិវឌ្ឍសេដ្ឋកិច្ចចិនបានឈានចូលស្ថានភាព ប្រក្រតីថ្មី។ ក្រោមការដឹកនាំដ៏រឹងមាំរបស់មជ្ឈិមបក្សដោយមាន ឯកឧត្តម **ស៊ី ជីនពីង** ជាស្នូល សេដ្ឋកិច្ចចិនរក្សាល្បឿនកំណើនខ្ពស់ និងមធ្យម ដែលជាប់លំដាប់ខ្ពស់ក្នុងចំណោមប្រទេសសំខាន់ៗនៅលើពិភពលោក។ ផលិតផលសរុបក្នុងស្រុកកើនឡើងពី៥៤ ទ្រីលានយ៉ាន់ រហូតដល់ ៨០ទ្រីលានយ៉ាន់ ជាប់លំដាប់ទី២ នៅលើពិភពលោក។ កំណែទម្រង់ត្រូវបានជំរុញឲ្យកាន់តែស៊ីជម្រៅ។ ប្រទេសចិនបានចាត់វិធានការផ្អែកការកែទម្រង់ចំនួនជាង ១៥០០ ។ ការស្ថាបនាក្នុងវិស័យដូចជា ប្រជាធិបតេយ្យ និងនីតិរដ្ឋ គំនិត និងវប្បធម៌ ជីវភាពរស់នៅរបស់ប្រជាជនប្រព័ន្ធអេកូឡូស៊ីទទួលការរីកចម្រើនដ៏ធំធេង។ ការប្រយុទ្ធប្រឆាំងអំពើពុករលួយនិងការទូត ដែលមានលក្ខណៈពិសេសចិន ទទួលបានស្នាដៃគួរឲ្យកត់សម្គាល់ក្នុងទូទាំងពិភពលោក។ យើងអាចនិយាយបានថា ៥ឆ្នាំកន្លង ទៅនេះ ចិនសម្រេចបានសមិទ្ធផលស្ទើរតែក្នុងគ្រប់វិស័យ ដែលមិនធ្លាប់មានក្នុងប្រវត្តិសាស្ត្រ។

មហាសន្និបាតបានលើកឡើងថា តាមរយៈកិច្ចខិតខំប្រឹងប្រែងរយៈពេលវែង សង្គមនិយមប្រកបដោយលក្ខណៈពិសេសចិនបានឈានចូលយុគសម័យថ្មី។ នៅក្នុងយុគសម័យថ្មីនេះ ទំនាស់សំខាន់ៗក្នុងសង្គមប្រទេសចិន បានក្លាយទៅជាទំនាស់រវាងតម្រូវការចំពោះជីវភាពល្អប្រសើររបស់ប្រជាជន ដែលកើនឡើងជារៀងរាល់ថ្ងៃ និងការអភិវឌ្ឍដោយអតុល្យភាព និងមិនពេញលេញ ។ មិនយូរប៉ុន្មានប្រទេសចិននឹងកសាងសង្គម មានភាពធូរធារគ្រប់ជ្រុងជ្រោយ ប្រជាជននឹងលើកឡើងនូវតម្រូវការ ដែលមានលក្ខណៈពិពិធកម្មកាន់តែខ្ពស់ចំពោះជីវភាពរស់នៅល្អប្រសើរ។ ទន្ទឹមនឹងនេះ ជាទូទៅកម្រិតផលិតភាពចិនត្រូវបានលើកកម្ពស់គួរឲ្យសម្គាល់ ។ សមត្ថភាព ផលិតកម្មលើច្រើនវិស័យបានជាប់លំដាប់ខ្ពស់ក្នុងពិភពលោក បញ្ហាប្រឈមសំខាន់ជាង គឺការអភិវឌ្ឍដោយអតុល្យភាព និងការមិនពេញលេញ ។ នៅពេលអនាគត ការងារចម្បងរបស់បក្សកុម្មុយនីស្តចិននៅតែជាការអភិវឌ្ឍសេដ្ឋកិច្ច តែត្រូវផ្តោតសំខាន់ទៅលើការអភិវឌ្ឍដោយគ្រប់ជ្រុងជ្រោយ ។

មហាសន្និបាតបានលើកឡើងថា ក្នុងអំឡុងពីមហាសន្និបាត លើក ទី១៩ ដល់មហាសន្និបាតលើកទី២០ ជាដំណាក់កាលសំខាន់សម្រាប់សម្រេចគោលដៅ **“មួយរយឆ្នាំពីរ”**។ យើងនឹងសម្រេចគោលដៅមួយរយ ឆ្នាំទីមួយ គឺកសាងសង្គមមានធូរធារគ្រប់ជ្រុងជ្រោយ ក៏នឹងខិតខំប្រឹងប្រែងចាប់ផ្តើមកិច្ចការថ្មី ដើម្បីកសាងប្រទេសសង្គមនិយមទំនើបកម្មដោយគ្រប់ជ្រុង-ជ្រោយ ដែលជាគោលដៅមួយរយឆ្នាំទីពីរ។ ពីឆ្នាំ២០២០ ទៅដល់ឆ្នាំ២០៣៥ ដោយឈរលើមូលដ្ឋានបញ្ចប់ការកសាងសង្គមមានភាពធូរធារគ្រប់ជ្រុងជ្រោយ ប្រទេសចិននឹងខិតខំកសាងប្រទេស១៥ ឆ្នាំ ដើម្បីសម្រេចទំនើបកម្មជា ទូទៅ។ ពីឆ្នាំ២០៣៥ ដល់ពាក់កណ្តាលសតវត្សរ៍នេះ ដោយឈរលើមូលដ្ឋានសម្រេចទំនើបកម្ម ប្រទេសចិននឹងខិតខំកសាងប្រទេស១៥ឆ្នាំទៀត ដើម្បីកសាងប្រទេសចិន ឲ្យទៅជាប្រទេសសង្គមនិយមទំនើបដែលមានភាពខ្លាំងក្លា និងសម្បូរសប្បាយប្រកបដោយប្រជាធិបតេយ្យ អរិយធម៌ ភាពចុះសម្រុង និងភាពស្រស់ស្អាត។ ជីវភាពរស់នៅរបស់ប្រជាជនចិននឹងកាន់តែមានសុភមង្គល ជនជាតិចិននឹងដើរតួនាទីកាន់តែសំខាន់នៅលើឆាកអន្តរជាតិ ។

មហាសន្និបាតបានបញ្ជាក់ថា ដើម្បីសម្រេចគោលដៅអស្ចារ្យ ត្រូវតែមានបក្សកាន់អំណាចដ៏រឹងមាំ។ ការដឹកនាំរបស់បក្សកុម្មុយនីស្តចិនជាឧត្តមភាពធំបង្អស់ និងលក្ខណៈពិសេសគល់នៃរបបសង្គមនិយមប្រកបដោយលក្ខណៈពិសេសចិន ត្រូវតែប្រកាន់ខ្ជាប់និងកែលម្អការដឹកនាំរបស់បក្សដោយមិនងាករេ ដើម្បីកសាងបក្សឲ្យទៅជាបក្សកាន់អំណាចលទ្ធិម៉ាក្សដែលឈានមុខជានិច្ចទទួលការគាំទ្រពីប្រជាជន ហ៊ានធ្វើបដិវត្តលើខ្លួនឯងទប់ទល់នឹងរាល់ បញ្ហាប្រឈម មិនអត់ឱន ប្រកាន់ខ្ជាប់ធ្វើយុទ្ធនាការតស៊ូប្រឆាំង **“ពួកខ្លា ពួករុយ និងពួកឆ្កែចចក”** ដែលធ្វើឲ្យការតស៊ូប្រយុទ្ធប្រឆាំងអំពើពុករលួយកាន់តែមានលក្ខណៈលើសលប់ និងទទួលការរីកចម្រើនធំឡើងៗ។ បក្សកុម្មុយនិស្តចិននឹងបន្តប្រយុទ្ធប្រឆាំងអំពើពុករលួយដោយគ្មានទីបញ្ចប់ ធ្វើឲ្យមន្ត្រីរដ្ឋការមិនហ៊ាន មិនអាច មិនចង់ប្រព្រឹត្តអំពើពុករលួយ ដើម្បីដណ្តើមយកជោគជ័យនៃការតស៊ូប្រយុទ្ធប្រឆាំងអំពើ

ពុករលួយ ។

អ្នកសារព័ត៌មានបានឲ្យដឹងថា បណ្ឌិត្យសភាវិទ្យាសាស្រ្តសង្គមចិន គឺជាគ្រឹះស្ថានសិក្សាស្រាវជ្រាវចម្រុះកម្រិតខ្ពស់ជាងគេបង្អស់ នៅក្នុងប្រទេសចិនដែលសាវ្រជ្រាវទស្សនវិជ្ជា និងវិទ្យាសាស្រ្តសង្គម។ ឯកឧត្តមប្រធាន **វ៉ាង វៃភ្វាង** ធ្វើការស្រាវជ្រាវពាក់ព័ន្ធទស្សនវិជ្ជាលទ្ធិម៉ាក្ស ទ្រឹស្ដីសំខាន់ៗនិងបញ្ហាជាក់ស្ដែងនៃសង្គម និយមប្រកបដោយលក្ខណៈពិសេសចិនរយៈពេលយូរ។ ក្នុងនាមជាតំណាងបក្ស ដែលចូលរួមមហាសន្និបាតលើកនេះ ឯកឧត្ដម **វ៉ាង វៃភ្វាង** មានការយល់ដឹង និងមតិយ៉ាងជ្រាលជ្រៅចំពោះខ្លឹមសារនៃមហាសន្និបាតលើកទី១៩ នេះ។ ឯកឧត្តមយល់ឃើញ ថា ក្នុងបរិបទមជ្ឈិមបក្សកុម្មុយនីស្តចិន ដែលមានឯកឧត្តម **ស៊ី ជីនភីង** ជាស្នូលដឹកនាំប្រជាជនចិនគ្រប់ជនជាតិទាំងអស់ ឈានចូលយុគសម័យថ្មី ចាប់ផ្ដើមធ្វើដំណើរថ្មី បន្តសរសេរទំព័រថ្មី ។ មហាសន្និបាតលើកទី១៩ នេះ ជាកិច្ចប្រជុំអស្ចារ្យ ដែលមានលក្ខណៈប្រវត្តិសាស្រ្តប្រកបដោយសារសំខាន់បំផុត។ មហាសន្និបាតលើកទី១៩ នេះបានប្រកាសថា សង្គម និយមប្រកបដោយលក្ខណៈពិសេស ចិនបានឈានចូលយុគ-សម័យថ្មី បានពន្យល់គតិសង្គមនិយម ប្រកបដោយលក្ខណៈពិសេសចិនក្នុងសម័យថ្មីរបស់ឯកឧត្តម **ស៊ី ជីនភីង** បានធ្វើឲ្យគំនិតណែនាំរបស់បក្សកុម្មុយនិស្តចិនបន្តវិវឌ្ឍទៅមុខឲ្យទាន់សម័យ បានបើកទំព័រជាប្រវត្តិ-សាស្រ្តថ្មី ដែលជនជាតិចិនបោះជំហានទៅរកវិបុលភាពឡើងវិញ បានបើកទំព័រជាប្រវត្តិសាស្តថ្មី ដែលប្រជាជនចិនបានបោះជំហានទៅរកជីវភាពរស់នៅដ៏ល្អប្រសើរនិងយុគសម័យថ្មី បានបើកទំព័រជាប្រវត្តិសាស្រ្តថ្មី ដែលបក្សកុម្មុយនីស្តចិនហ៊ានធ្វើការតស៊ូ ដើម្បីបោះជំហានទៅរកជោគជ័យដ៏អស្ចារ្យ។ រាល់ផែនការនិងសមិទ្ធផលដែលរៀបចំឡើងនិងទទួលបានក្នុងមហាសន្និបាតនេះ មុខជានឹងដើរតួនាទីណែនាំនិងធានាសំខាន់ក្នុងការដណ្ដើមយកជោគជ័យសម្រាប់កសាងសង្គមមានធូរធារគ្រប់ជ្រុងជ្រោយ ការជំរុញវិស្វកម្មដ៏អស្ចារ្យក្នុងការកសាងបក្ស ដណ្ដើមយកជោគជ័យថ្មីរបស់សង្គមនិយមប្រកបដោយលក្ខណៈពិសេសចិនការសម្រេចសុបិន ចិន ក្នុងការស្ដារវិបុលភាពដ៏មហិមារបស់ប្រជាជាតិចិនឡើងវិញ ។

តមកពីទំព័រទី ២៦

សេវាត្រួតពិនិត្យលក្ខណៈ បច្ចេកទេសយានយន្ត ការចុះបញ្ជីយានយន្តការចេញប័ណ្ណបើកបរ និងបានជំរុញឲ្យមន្ត្រីពាក់ព័ន្ធទាំងអស់ ខិតខំប្រឹងប្រែងប្រើប្រាស់ប្រព័ន្ធអនឡាញ ដើម្បីកាត់បន្ថយចំណាយក្រៅផ្លូវការ។ ក្នុងឆ្នាំ២០១៧ នេះ ប្រជាពលរដ្ឋបានយករថយន្តពិនិត្យលក្ខណៈបច្ចេកទេស (ឆៀក) បានចំនួន ២១៦,០០០គ្រឿង មានការធ្លាក់ចុះជាង ឆ្នាំ២០១៦ ដែលមានចំនួន ២៣៤,០០០គ្រឿង ការធ្លាក់ចុះនេះ ដោយសាររថយន្តនីមួយៗ មិនទាន់ដល់ពេលកំណត់ត្រូវឆៀកតែប៉ុណ្ណោះ។

ចំពោះទិសដៅសកម្មភាព ដែលត្រូវអនុវត្តបន្តក្រសួងត្រូវខិតខំអភិវឌ្ឍន៍ហេដ្ឋារចនាសម្ព័ន្ធដឹកជញ្ជូន ការងារដឹកជញ្ជូនផ្លូវគោក ការងារផ្លូវថ្នល់ និងការបន្តស្តារ និងសាងសង់ហេដ្ឋារចនាសម្ព័ន្ធផ្លូវថ្នល់ឲ្យបានយ៉ាងហោចប្រវែង ៣ ៥០០ គ.ម បន្ថែមសម្រាប់៥ ឆ្នាំខាងមុខ ដើម្បីគាំទ្រគោលនយោបាយនានារបស់ រាជរដ្ឋាភិបាល ជាពិសេសគោលនយោបាយអភិវឌ្ឍន៍វិស័យឧស្សាហកម្មនៅកម្ពុជា និងបំរើឲ្យការធ្វើសមាហរណកម្មជាតិ និងអន្តរជាតិ។បន្តស្តារនិងសាងសង់ផ្លូវជាតិកម្រិត១ពីប្រភេទផ្លូវក្រាលកៅស៊ូ២ជាន់ ( DBST ) ទៅបេតុងកៅស៊ូ (AC) ។ បន្តពង្រីកផ្លូវជាតិកម្រិត ១ ភ្ជាប់ទៅតំបន់អភិវឌ្ឍន៍សំខាន់ៗ និងនៅជុំវិញទីក្រុងសំខាន់ៗពី ២ គន្លងទៅ៤គន្លងដើម្បីកាត់បន្ថយពេលវេលាធ្វើដំណើរនិងកាត់បន្ថយគ្រោះថ្នាក់

ពាក់ព័ន្ធនឹងទំនាក់ទំនងរវាងប្រទេសចិន និងបណ្ដាប្រទេសទូទាំងពិភពលោក ឯកឧត្តម **វ៉ាង វៃភ្វាង** គូសបញ្ជាក់ថា បក្សកុម្មុយនីស្តចិនជាបក្សនយោបាយមួយ ដែលពាំនាំសុភមង្គលជូនប្រជាជនក៏ជាបក្សនយោបាយមួយដែលតស៊ូ ដើម្បីបុព្វហេតុវឌ្ឍនភាពរបស់មនុស្សជាតិ។ បក្សកុម្មុយនិស្តចិនតែងតែចាត់ទុកការរួមវិភាគទានថ្មីកាន់តែធំ ដើម្បីមនុស្សជាតិជាបេសកកម្មរបស់ខ្លួន។ អត្រារួមវិភាគទានចិនសម្រាប់កំណើនសេដ្ឋកិច្ចពិភពលោកលើសពី៣០ ភាគរយ ជាប់លំដាប់លេខមួយនៅលើពិភពលោក។ ប្រទេសចិន ខិតខំក្នុងការថែរក្សាសន្តិភាពពិភពលោក ជំរុញការអភិវឌ្ឍរួមគ្នា ប្រកាន់ខ្ជាប់នូវអភិវឌ្ឍកិច្ចសហប្រតិបត្តិការមេត្រីភាពជាមួយបណ្ដាប្រទេសនានា ដោយឈរលើមូលដ្ឋាននៃគោល-ការណ៍សន្តិសហវិជ្ជមាន ជំរុញកសាងទំនាក់ទំងអន្តរជាតិបែបថ្មី ដែលគោរពគ្នាទៅវិញទៅមក មានយុត្តិធម៌ និងផ្ដល់ផលប្រយោជន៍ទៅវិញទៅមក។ របាយការណ៍មហាសន្និបាត លើកទី១៩ បានអំពាវនាវគ្រប់ប្រទេសនានាសហការគ្នា ដើម្បីបង្កើតសហគមន៍រួម វាសនាតែមួយនៃមនុស្សជាតិ និងកសាងពិភពលោកដែលមានសន្តិភាពយូរអង្វែរ សន្តិសុខទូទៅ វិបុលភាពរួមគ្នា ការបើកទូលាយបរិយាប័ន និងភាពស្រស់ស្អាត។ ប្រទេសចិននឹងបន្តដើរតួនាទីជាប្រទេសធំ ទទួលខុសត្រូវ ចូលរួមក្នុងការកែទម្រង់និងកសាងប្រព័ន្ធគ្រប់គ្រងពិភពលោកយ៉ាងសកម្ម ផ្ដល់គតិបណ្ឌិតនិងកម្លាំងរបស់ខ្លួនដោយឥតឈប់ឈរ។

ពាក់ព័ន្ធនឹងទំនាក់ទំនងរវាងប្រទេសចិននិងកម្ពុជា ឯកឧត្តម **វ៉ាង វៃភ្វាង** យល់ឃើញថា ការអភិវឌ្ឍនៃប្រទេសចិនមិនអាចកាត់ផ្ដាច់ពិភពលោក មិនអាចកាត់ផ្ដាច់ពីទ្វីបអាស៊ី ក៏មិនអាចកាត់ផ្ដាច់ពីប្រទេសកម្ពុជាបានទេ ។ ក្នុងនាមជាអ្នកជិតខាងល្អ មិត្តភ័ក្ដល្អ បងប្អូនល្អ ដៃគូល្អប្រទេសចិនសង្ឃឹមយ៉ាងស្មោះថាប្រទេស កម្ពុជាអាចសម្រេចបានស្ថិរភាពនិងវិបុលភាពរយៈពេលវែង ក្នុងការអភិវឌ្ឍសេដ្ឋកិច្ច និងសង្គម។ ប្រទេសចិន ស្វាគមន៍កម្ពុជាជិះ រថភ្លើងល្បឿនលឿននៃការអភិវឌ្ឍសេដ្ឋកិច្ចរបស់ខ្លួន ដើម្បីធ្វើឲ្យប្រទេសយើងទាំងពីរមានវិបុលភាពនិងការរីកចម្រើនរួមគ្នា ៕

ចរាចរណ៍ ។ បន្តស្តារ និងសាងសង់ផ្លូវជាតិ ផ្លូវខេត្ត ភ្ជាប់ទៅតំបន់អភិវឌ្ឍន៍ឧស្សាហកម្ម កសិកម្ម កសិឧស្សាហកម្ម និងទេសចរណ៍ថ្មីៗ ដែលបានបង្កើតឡើង និងតាមតំបន់ព្រំដែន ។ បន្តបង្កើនអត្រាក្រាលកៅស៊ូសម្រាប់ផ្លូវជាតិកំរិត២ ឲ្យបាន ១០០% និងផ្លូវខេត្តឲ្យបានយ៉ាងតិច ៤០% ។ រៀបចំឲ្យមាន ការសិក្សា និងអនុវត្តគម្រោង ស្ដីពីការបាក់ច្រាំង និងចំនុចសំខាន់ៗ។បន្តការស្ថាបនាស្ថានីយប្រព្រឹត្តិកម្មទឹកកខ្វក់ នៅតាមបណ្ដាខេត្តសំខាន់ៗ ។ បន្តរៀបចំឲ្យមាននិងប្រើប្រាស់សេវាដឹកជញ្ជូនសាធារណៈនៅតាមទីក្រុងសំខាន់ៗ ។ បង្កើនស្លាកសញ្ញាសុវត្ថិភាពចរាចរណ៍លើផ្លូវជាតិ ផ្លូវខេត្ត និងតំបន់ទីប្រជុំជន និងរៀបចំ ដាក់ឲ្យមានកាមេរ៉ា សម្រាប់តាមដាន ការបើកបរលើសល្បឿន កំណត់នៅតាមផ្លូវជាតិ កម្រិត១ ដើម្បីសុវត្ថិភាព និងកាត់បន្ថយ គ្រោះថ្នាក់ចរាចរណ៍ ។ ជំរុញការសាងសង់ផ្លូវល្បឿនលឿន ដែលជាគម្រោងអាទិភាព ផ្អែកលើផែនការមេនៃការអភិវឌ្ឍផ្លូវល្បឿនលឿននៅកម្ពុជា ដូចជាខ្សែផ្លូវភ្នំពេញ-ក្រុងព្រះសីហនុ និងភ្នំពេញ- បាវិតជាដើម ។បន្តពង្រឹងគុណភាពលើការថែទាំ ជួសជុល និងការងារសាងសង់ និងធានាឲ្យបាននូវលំហូរថវិកាជាតិ លើការ ថែទាំប្រចាំ និងថែទាំខួបណ្ដាញផ្លូវថ្នល់ និងបន្តការងារគ្រប់គ្រងដីចំណីផ្លូវឲ្យមានប្រសិទ្ធភាព ៕



# ទើបចាប់បដិសន្ធិជាង៦ ឆ្នាំ ឃុំតេជោអភិវឌ្ឍន៍ មានការរីកចម្រើនយ៉ាងខ្លាំង



*មណ្ឌលសុខភាពក្នុងឃុំតេជោ អភិវឌ្ឍន៍*



*វិទ្យាល័យ **ម៉ិុន រ៉ានី-ហ៊ុន សែន** កោះស្លា ឃុំតេជោ អភិវឌ្ឍន៍*

មានចម្ងាយជិត ១០០គីឡូម៉ែត្រស្ថិតនៅភាគឧត្តរនៃទីរួមខេត្តកំពត, តេជោអភិវឌ្ឍន៍ជាឃុំមួយទើបកកើតឡើងជាងប្រាំមួយឆ្នាំប៉ុណ្ណោះ តែគ្រប់វិស័យក្នុងដែននៃរដ្ឋបាលដែលពឹងផ្អែកជាសំខាន់លើវិស័យកសិកម្មនេះ មានការប្រែប្រួលរីកចម្រើនយ៉ាងឆាប់រហ័ស បើប្រៀបធៀបទៅនឹងបណ្ដាឃុំសង្កាត់ទាំងអស់ក្នុងខេត្តកំពត។ ជាទឡ្ហីករណ៍ដែលត្រូវបានវាយតម្លៃថា មូលដ្ឋានដែលដឹកនាំដោយមន្ត្រីមកពីគណបក្សប្រជាជនកម្ពុជាមួយមានការរីកចម្រើននេះ គឺដោយសារក្នុងចំណោមប្រជាពលរដ្ឋជាង ១.៩៥០គ្រួសារមានយានយន្ត និងគ្រឿងចក្រផ្នែកកសិកម្មសម្រាប់ប្រើប្រាស់ប្រមាណជាងជិត ១.៥០០ គ្រឿង ឯណោះ។

**ទឹកដីតេជោអភិវឌ្ឍន៍**

លោក **សាន គ្រីយ៉ា** ប្រធានក្រុមប្រឹក្សាឃុំតេជោអភិវឌ្ឍន៍ បានរៀបរាប់ប្រាប់ទស្សនាវដ្ដីប្រជាជនថា ឃុំនេះបានបង្កើតឡើងកាលពីថ្ងៃទី៣១ ខែឧសភាឆ្នាំ២០១១ ដែលកាត់ចំណែកផ្ទៃដីមួយផ្នែកចេញពីឃុំត្រពាំងភ្លាំង ស្រុកឈូក ។ ឃុំមានភូមិចំនួនប្រាំមួយជាចំណុះ គឺភូមិតេជោអភិវឌ្ឍន៍ ភូមិតេជោអន្លង់ក្មេងលេង ភូមិតេជោក្បាលដំរី ភូមិតេជោអង្កាញ់ ភូមិតេជោពង្រក និងភូមិតេជោជ្រៃបាក់។

ឃុំតេជោអភិវឌ្ឍន៍ មានព្រំប្រទល់ខាងជើងនិងខាងកើតជាប់ខេត្តកំពង់ស្ពឺ។ ខាងត្បូងទល់ឃុំត្រពាំងភ្លាំង ខាងលិចទល់ខេត្តព្រះសីហនុ។ វិសាលភាពនៃឃុំទាំងមូលមានផ្ទៃដីទំហំ២៦.៣៥២ហិកតា ក្នុងនោះផ្ទៃដីកសិកម្ម ៤.៥០០ ហិកតានិងដីលំនៅស្ថាន ២.០៥២ហិកតា ។ រហូតមកដល់បច្ចុប្បន្ន ប្រជាពលរដ្ឋក្នុងឃុំមានចំនួន ១.៩៥៨ គ្រួសារ ស្មើនឹង៧.៣៦៦នាក់ ។ ប្រជាជននៃឃុំនេះមាន៩៨% ប្រកបមុខរបរកសិកម្ម។

**តេជោអភិវឌ្ឍន៍មានអ្វីខ្លះ ?**

លោកមេឃុំបានរៀបរាប់ឱ្យដឹងពីសមិទ្ធផលដែលបានកើតឡើង សម្រាប់មូលដ្ឋានទើបនឹងមានអាយុកាលជាងប្រាំមួយឆ្នាំនេះថា ដោយមួយផ្នែកនៃភូមសាស្ត្រ ឃុំតេជោអភិវឌ្ឍន៍គ្របដណ្ដប់មជ្ឈមណ្ឌលអភិវឌ្ឍន៍ យោធិនពិការ ៣១៧ កោះស្លាផងនោះ សមិទ្ធិបានកើតឡើងជាបន្តបន្ទាប់និងឆាប់រហ័ស។ ក្នុងនោះរួមមាន ផ្លូវកៅស៊ូប្រវែង ១៨គីឡូម៉ែត្រតភ្ជាប់ពីផ្លូវជាតិលេខ៤ អគារសាលាឃុំមួយ ប៉ុស្តិ៍នគរបាលរដ្ឋបាលមួយ ស្នាក់ការសន្តិសុខកងរាជអាវុធហត្ថមួយ ផ្សារមួយកន្លែងមានតូបលក់ទំនិញគ្រប់មុខចំនួន២២៧ វិទ្យាល័យ និងសាលាបឋមសិក្សាប្រាំកន្លែង វត្តចំនួនបួន មន្ទីរពេទ្យបង្អែក និងមណ្ឌលសុខភាពពីរកន្លែង ស្រះទឹកធំៗបាំមួយកន្លែង អណ្ដូងស្នប់៦៨ និងអណ្ដូងលូចំនួន២៦៦។

លោក **សាន គ្រីយ៉ា** បានបញ្ជាក់ទៀតថា មកដល់ពេលនេះ ភូមិចំនួនបីមានអគ្គិសនីរដ្ឋប្រើប្រាស់ ក្នុងនោះនៅភូមិតេជោអភិវឌ្ឍន៍ភ្លើងអគ្គិសនីមានគ្រប់អគាររដ្ឋ និងលំនៅស្ថានប្រជាជន។ រីឯភូមិតេជោអន្លង់ក្មេងលេង និងភូមិតេជោក្បាលដំរីមានដោយផ្នែកៗ។ ចំណែកទឹកស្អាតវិញ អាជ្ញាធរបានចាប់ដៃគូជាមួយក្រុមហ៊ុនឯកជន ដែលពេលនេះកំពុងសាងសង់មណ្ឌលផលិតសម្រេចបានប្រមាណ ៥០% តាម រយៈការទាញយកទឹក ដែលមានទីតាំងក្នុងភូមិសាស្ត្រស្រាប់។ ជាជំហានដំបូងទឹកស្អាតនឹងផ្គត់ផ្គង់លើភូមិតេជោអភិវឌ្ឍន៍ ភូមិតេជោអន្លង់ក្មេងលេងនិងភូមិតេជោក្បាលដំរី។

លោកមេឃុំបានប្រាប់ទៀតថា៖ ជាមោទនភាពសម្រាប់ឃុំតេជោអភិវឌ្ឍន៍ដែលមាន ក្រុមហ៊ុនឯកជនបីបានកើតឡើងក្នុងមូលដ្ឋានដោយផ្ដល់ការងារ ដល់ប្រជាពលរដ្ឋក្នុងការរកប្រាក់ចំណូលសម្រាប់គ្រួសារនោះ គឺក្រុមហ៊ុនកសិកម្មដាំដូងប្រេងវីជីភី, ក្រុមហ៊ុនដាំស្វាយចន្ទីចាន់សុធា និងមណ្ឌលកម្សាន្តទឹកធ្លាក់បីជាន់។ ទោះជាបែបនេះក្ដីលោកប្រធាន ក្រុមប្រឹក្សាឃុំតេជោអភិវឌ្ឍន៍បានផ្ញើជូនចំពោះរាជរដ្ឋាភិបាល និងផ្នែកពាក់ព័ន្ធនានានូវសំណូមពរមួយចំនួនរួមមាន ជួយសាងសង់រោងចក្រ ដើម្បីផ្ដល់ការងារជូនពលរដ្ឋក្នុងមូលដ្ឋាន ដែលជាផ្នែកសំខាន់ឈានទៅកាត់បន្ថយការធ្វើចំណាកស្រុក។ បង្កើនការផ្ដល់សេវាអគ្គិសនីដល់ភូមិទាំងប្រាំមួយ ដើម្បីបានប្រើប្រាស់គ្រប់ៗគ្រួសារ។ ជួយសង់ស្ពានឆ្លងកាត់ស្ទឹងពីរកន្លែងស្ថិតនៅក្នុងភូមិតេជោក្បាលដំរី និងភូមិតេជោពង្រក ដោយមួយខ្សែៗមានប្រវែង២៣



*ផ្លូវចាក់កៅស៊ូឆ្លងកាត់ក្នុងភូមិសាស្ត្រឃុំតេជោ អភិវឌ្ឍន៍*

ម៉ែត្រ។ សូមជួយសង់សាលាបឋមសិក្សាមួយកន្លែងស្ថិតក្នុងភូមិពង្រកដោយភូមិនេះមានចម្ងាយរហូតដល់ ២៣គីឡូម៉ែត្រពីទីកន្លែងដែលមានសាលារៀនសព្វថ្ងៃ។

លោក **ម៉ៅ ម៉ារ៉ាឌី** នាយប៉ុស្តិ៍នគរបាលរដ្ឋបាលឃុំតេជោអភិវឌ្ឍន៍បានប្រាប់ថា ក្រោមដំបូលសន្តិភាពរបស់រាជរដ្ឋាភិបាលកម្ពុជា ដឹកនាំដោយ **សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន** ប្រធានគណបក្សប្រជាជនកម្ពុជា បានធ្វើឱ្យប្រជាពលរដ្ឋឃុំតេជោអភិវឌ្ឍន៍មានជីវភាពធូរធារនិងរីកចម្រើនជាលំដាប់ ។ សព្វថ្ងៃក្នុងចំណោមប្រជាពលរដ្ឋ ១.៩៥៨ គ្រួសារនៃមូលដ្ឋាននេះគឺមានរថយន្តតូចធំ ចំនួន ១០៧គ្រឿង ម៉ូតូ ១.១៤៨គ្រឿង គោយន្ត ៤៨គ្រឿង ត្រាក់ទ័រ ៣៥គ្រឿង និងអេស្កាវ៉ាទ័រមួយគ្រឿង។

ពាក់ព័ន្ធបញ្ហាសន្តិសុខមូលដ្ឋាន លោកនាយប៉ុស្តិ៍បានបញ្ជាក់ថា ទោះបីមិនបានដល់កម្រិតឥតខ្ចោះក្តី តែការការពារសន្តិសុខសុវត្ថិភាពជូនប្រជាពលរដ្ឋក្នុងឃុំតេជោ អភិវឌ្ឍន៍មានលក្ខណៈល្អ តាមរយៈកិច្ចសហការរវាងកម្លាំងនគរបាលមូលដ្ឋានជាមួយប្រជាការពារ កងរាជអាវុធហត្ថ និងកងពលតូចលេខ ១១ ។ ព្រោះតែសភាពការណ៍ និងលក្ខណៈភូមិសាស្ត្រអំណោយផលល្អ ពេលនេះ ក្នុងឃុំឈានទៅមានហាងខារ៉ាអូខេសម្រាប់បម្រើដល់ការកម្សាន្ត ផ្ទះសំណាក់ និងសាលាឯកជនផ្នែកភាសាបរទេសថែមទៀតផង។

លោក **ខៀវ ឫទ្ធិភ័ណ្ឌ** អភិបាលស្រុកឈូកបានមានប្រសាសន៍ថា ក្រោយពីបានបង្កើតឡើង ការដឹកនាំឃុំតេជោអភិវឌ្ឍន៍មានការប្រែប្រួលទាំងហេដ្ឋារចនាសម្ព័ន្ធ ក៏ដូចជាជីវភាពរបស់ប្រជាពលរដ្ឋបានធូរធារស្មើរគ្រប់គ្រួសារ ។ ជាមួយនឹង ការជំរុញខ្លាំងក្លាផ្នែកវិស័យ កសិកម្ម បច្ចុប្បន្ន តំបន់តេជោ អភិវឌ្ឍន៍ មានទេសភាពពណ៌បៃតង ទាំងប្រាំងវស្សា ។ ប្រជាពលរដ្ឋ ចេះប្រើប្រាស់នូវអ្វី ដែលជាសក្តានុពល ក្នុងមូលដ្ឋាន របស់ខ្លួន ពោលគឺ ខុសពីមុន ដែលមានភាពសោះកក្រោះ បង្កឲ្យមានការ ធ្វើចំណាកស្រុកជាហូរហែ ។ លោកអភិបាលស្រុក ក៏បានបញ្ជាក់អំពីអ្វីដែលអាជ្ញាធរត្រូវខិតខំបន្តទៀត ដូចជា បញ្ហាដំណោះស្រាយទំនាស់ដីធ្លី ការកែលម្អ ជួសជុល និងស្ថាបនាផ្លូវជនបទដាច់ស្រយាលដែលមិនទាន់បានល្អប្រសើរនៅឡើយនោះ។

លោក **ស៊ុន ពេជ្រ** អាយុ ៥៨ឆ្នាំ រស់នៅភូមិតេជោអភិវឌ្ឍន៍ ឃុំតេជោអភិវឌ្ឍន៍បានរៀបរាប់ថាលោកបានមករស់នៅទីនេះតាំងពីឆ្នាំ២០០៨ តាមរយៈការចែកដីកសិកម្ម និងលំនៅស្ថានក្រោមគោលនយោបាយយោធិនពិការ។ កាលនោះ ស្ថានភាពស្ងាត់ជ្រងំ ហើយបើចង់ទិញម្ហូបអាហារ ឬសម្ភារៈផ្សេងៗត្រូវធ្វើដំណើរទៅផ្សារត្រែងត្រយឹង ខេត្តកំពង់ស្ពឺ។ ប៉ុន្តែបន្ទាប់ពីបង្កើតរដ្ឋបាលឃុំតេជោអភិវឌ្ឍន៍ ទើបចាប់ផ្តើមមានការរីកចម្រើនគ្រប់ហេដ្ឋារចនាសម្ព័ន្ធ ពិសេសផ្សារបានកើតមានក្នុងមូលដ្ឋានតែម្តង។

អតីតមន្ត្រីយោធារូបនេះបានបន្តថា ជាមួយនឹងវត្តមានផ្សារក្បែរលំនៅស្ថាននោះ ក្រៅពីការងារដាំដុះដំណាំផ្សេងៗ និងមានដើមទុនមួយចំនួន ក្រុមគ្រួសារលោកក៏ចាប់ផ្តើមលក់ទំនិញរហូតបច្ចុប្បន្នទទួលបាននូវជីវភាពធូរធារដូចគេឯងដែរ។ លោក **ស៊ុន ពេជ្រ** បញ្ជាក់ថារាល់ថ្ងៃក្នុងបន្ទុកគ្រួសារមានគ្នាប្រាំនាក់ លោកមានរថយន្តស្អាតល្មមមួយគ្រឿងគ្រាន់ នឹងដឹកអីវ៉ាន់ និងម៉ូតូពីរគ្រឿងសម្រាប់កូនចៅធ្វើដំណើរ។ ថ្មីៗនេះ លោកទើបនឹងជួសជុលនិងធ្វើផ្ទះអស់ជាងមួយម៉ឺនដុល្លារ បន្ថែមលើរបបដែលទទួលបាន ។ ពីមុនបើត្រូវការទៅណាមកណាលុយមានច្រើនបំផុតត្រឹមពីរម៉ឺនរៀលប៉ុណ្ណោះ តែបច្ចុប្បន្នពេលឡើងផ្សារធំៗ ដើម្បីទិញអីវ៉ាន់មកលក់បន្ត យ៉ាងហោចក៏មាន២០លាន ទៅ៣០លានរៀល ដាក់តាមខ្លួនដែរ។ មោទនភាពទាំងនេះ លោកនិងក្រុមគ្រួសារមិនបំភ្លេចគុណពិសេសនៅតែបន្តគាំទ្ររាជរដ្ឋាភិបាល ដែលដឹកនាំដោយ**សម្តេចតេជោ ហ៊ុន សែន** ប្រធានគណបក្សប្រជាជនកម្ពុជា ដោយឥតប្រែប្រួលឡើយ។

មានគណបក្សប្រជាជនកម្ពុជា ដឹកនាំនឹងមានការរីកចម្រើនរហូត ប្រជាពលរដ្ឋដែលទទួលបាននូវសុខសុវត្ថិភាព សន្តិភាពនិងការរីកចម្រើនពីការដឹកនាំរបស់រាជរដ្ឋាភិបាលកម្ពុជា ដែលមានគណបក្សប្រជាជនកម្ពុជាជាស្នូលដ៏រឹងមាំ ក៏ដូចជា អាជ្ញាធរដែនដីគ្រប់លំដាប់ថ្នាក់ ដែលមានតែងទទួលបាននូវការគាំទ្រកើនឡើងជាលំដាប់ ហានបង្ហាញនូវជំនឿជាក់ថា មានគណបក្សប្រជាជនកម្ពុជា មានសម្តេចតេជោជាប្រមុខព្រមទាំងថ្នាក់ដឹកនាំគណបក្សប្រជាជនកម្ពុជា គ្រប់លំដាប់ថ្នាក់ ដែលតែងគិតគូនិងចុះជួយគ្រប់បែបយ៉ាងជាប្រចាំ ឃុំតេជោអភិវឌ្ឍន៍ នឹងទទួលបាននូវវឌ្ឍនភាពឈានឡើងថែមទៀត ៕



## សំណើច

១-សំណើចយើងសើចក្នុងសង្ឃឹម
សើចលាយញញឹមភក្រ្តប្រិមប្រិយ
សំណើចសំណាងជីវិតថ្មី
នៅលើទឹកដីអច្ឆរិយៈ ។
២-សន្តិភាពអភិវឌ្ឍគត់មត់ល្អ
សំណើចខ្ចារខ្ចរ័ដ៏ប្រត្យក្ស
ប្រាំពីរមករាចារជ្រៅជាក់
ក្នុងបេះដូងអ្នក - ខ្មែររាល់គ្នា ។
៣-អតីតកាលដ៏ងងឹត
បច្ចុប្បន្នភ្លឺពិតលើកម្ពុជា
អនាគតត្រចះច្បាស់មាគ៌ា
ព្រោះបក្សប្រជាជនដឹកនាំ ។

## សំណោក

១-សំណោកសោយសោកពីអតីត
អំពូខ្មៅរួមរឹតទ្រូងពើតគ្រាំ
ភ្នំផ្អឹងស្នឹងឈាមជន់ជោគជាំ
ហូរក្លាយជាជ្រាំក្រាលកម្ពុជា ។
២-សំណើចខំសើចទាំងឈឺចាប់
មិនសើចគឺស្លាប់ទាំងវេទនា
សើចតាមអង្គការដាក់បញ្ជា
សើចយំលាយគ្នា សើចមុនស្លាប់ ។

## សំណាង

១-សំណាងតែមួយក្នុងរយគ្រោះ
សំណាងបានរស់ផុតឈឺចាប់
អតីតកាលរំឭកប្រាប់
សូមកុំប្រញាប់បំភ្លេចភ្លាម ។
២-ជិតសែសិបឆ្នាំសមិទ្ធផល
បានផ្តល់ផ្លែផ្កាស្គួយកិត្តិនាម
ដែលត្បាញចេញមកពីញើសឈាម
សាងឡើងក្នុងនាមជាតិកម្ពុជា ។
៣-ការពារឲ្យបានឯករាជ្យជាតិ
អធិបតេយ្យជាតិមហិមា
សន្តិភាពអភិវឌ្ឍយឺនយូរយារ
សុខដុមរមនាអង្វែងអើយ ៕

ដោយលោក. ខៀវ ណាវី

### ទំពែកពីរនាក់




តា **ភក់** និងតា **ភឹម** ក្បាលទំពែកគ្មានសល់សក់មួយសរសៃដូចគ្នា ។ ពេលដើរជួបគ្នាដោយចៃដន្យ តា **ភឹម** និងយាយ៖

- អេហ៍...ល្បង...ខ្ញុំមើលទៅក្បាលល្បងឯងឃើញដូចជាទំពែកច្រើនជាងខ្ញុំ ។

- និយាយផ្តាស ក្បាលខ្ញុំ និងក្បាលប្អូនកឹមឯងរលីងគ្មានសក់មួយសរសៃដូចគ្នា ។ បានសេចក្តីថា ទំពែកស្មើគ្នា ហេតុម៉េចក៏ថាក្បាលខ្ញុំទំពែកច្រើនជាង ?

- អត់សល់សក់មួយសរសៃដូចគ្នាមែនហើយ ប៉ុន្តែក្បាលល្បងកាក់ ឯងធំជាងក្បាលខ្ញុំ ។ ដូច្នេះ បើមិនទំពែកច្រើនជាង តើជាស្អីទៅវិញ ? ។

### កុំឲ្យសងរួច

ក្រុមគ្រួសារលោក **សារ៉ែម** អង្គុយជុំគ្នាពីមុខទូរទស្សន៍តាមដានការប្រកួតបាល់ទាត់រវាងក្រុម **ក** និងក្រុម **ខ** ដែលសុទ្ធសឹងជាក្រុមខ្លាំងដូចគ្នា ។ ប្រយុទ្ធគ្នាយ៉ាងស្វិតស្វាញជិតចប់តង់ទីមួយស្រាប់តែក្រុម **ក** ស៊ុតចូលបានមួយគ្រាប់ ធ្វើឲ្យអ្នកទស្សនាស្រែកហ៊ោរគ្រេវ ។ ភ្លាមនោះកុមារ **សំអុន** ជាកូនប្រុសពៅស្ទុះទៅបិទទូរទស្សន៍ធ្វើឲ្យអ្នកទស្សនាក្តៅក្រហាយគ្រប់គ្នា ។

កុមារ **សំអន** ជាបងគំហកសួរ:

- ម៉េចអូនឯងធ្វើអ៊ីចឹង ?

កុមារសំអុនសើចស្ងួតឆ្លើយ:

- បិទកុំឲ្យក្រុម **ខ** សងរួច ។ ខ្ញុំខ្លាចក្រុម **ខ** ទាត់ចូលវិញ ។

### អ្នកច្រឡំហើយ

រាត្រីពាក់កណ្តាលអធ្រាតទៅហើយ បុគ្គលិកសណ្ឋាគារម្នាក់រត់ទៅគោះទ្វារបន្ទប់មួយ ដែលមានអតិថិជនម្នាក់កំពុងស្នាក់នៅក្នុងនោះ ។ ពួកគេគោះហើយគោះទៀត ទាល់តែអ្នកស្នាក់នៅខាងក្នុងភ្ញាក់ហើយស្រែកសួរ:

- អ្នកណារកអីថ្មើរណេះ ?

- ក្រោកភ្លាមឡើងលោក សណ្ឋាគារត្រូវភ្លើងឆេះហើយ ។

- អេហ៍ អ្នកឯងច្រឡំហើយ ខ្ញុំមិនមែនបុគ្គលិកពន្លត់អគ្គីភ័យទេ ។

### ជៅក្នុងខោខ្ញុំ

នៅចុងម៉ោងសិក្សា អ្នកគ្រូសួរសិស្ស **វ៉ូច**

- មើលប្អូន **វ៉ូច** កិត្តិយសគឺជាអ្វី ?

- បាទ....ជម្រាបអ្នកគ្រូកិត្តិយសគឺរបស់នៅក្នុងខោខ្លីប៉ាខ្ញុំ។

ឮ **វ៉ូច** ឆ្លើយអ្នកគ្រូភ្ញាក់វិះដាច់ផ្ងា៖

- អេហ៍..... ម៉េចក៏ប្អូនអះអាងដូច្នេះ ?

- បាទ.... ខ្ញុំនិយាយការពិតតើ ជាក់ស្តែងម្សិលមិញនៅផ្ទះខ្ញុំមានភ្ញៀវជិះរថយន្តមកលេង ខណៈឪពុកខ្ញុំកំពុងស្លៀកខោខ្លី ។ គាត់ហៀបនឹងចេញទទួលភ្ញៀវទាំងខោខ្លី តែម្តាយខ្ញុំស្រែកឃាត់ថា:

<<អេហ៍...ម៉េចបងមិនស្លៀកខោវែងវិញ ធ្វើដូច្នេះបងមិនបាត់បង់កិត្តិយសអស់ហើយទេឬ ?>>៕

បោះពុម្ពដោយ រោងពុម្ព **អរិយធម៌** ផ្ទះលេខ ៩២, ផ្លូវលេខ ៥៩៤, សង្កាត់បឹងកក់ II ខណ្ឌទួលគោក-ភ្នំពេញ
H/P : 012 990 935 / Tel : 023 885 188 / Fax : 023 885 189 E-mail : ariyathoar@yahoo.com

# អ្នកឧបត្ថម្ភ ទស្សនាវដ្ដី ប្រជាជន លេខ ១៩៩

| | | | | | |
|---|---|---|---|---|---|
| ១- | លោកជំទាវ | ម៉ែន | សំអន | សមាជិកគណៈអចិន្ត្រៃយ៍គណៈកម្មាធិការកណ្ដាល ប្រធានគណៈកម្មាធិការគណបក្សក្រសួងទំនាក់ទំនងជាមួយរដ្ឋសភា ព្រឹទ្ធសភា និងអធិការកិច្ច | ៤០០.០០០៛ |
| ២- | ឯ.ឧ | កែ | គឹមយ៉ាន | សមាជិកគណៈអចិន្ត្រៃយ៍គណៈកម្មាធិការកណ្ដាល ប្រធានក្រុមការងារចុះខេត្តបន្ទាយមានជ័យ | ១០០ ដុល្លារ |
| ៣- | ឯ.ឧ | អ៊ុក | រ៉ាប៊ុន | សមាជិកគណៈអចិន្ត្រៃយ៍គណៈកម្មាធិការកណ្ដាល ប្រធានគណៈកម្មាធិការគណបក្សក្រសួងអភិវឌ្ឍន៍ជនបទ | ១០០ ដុល្លារ |
| ៤- | ឯ.ឧ | ជា | ចាន់តូ | ប្រធានគណៈកម្មាធិការនៃគណបក្សធនាគារជាតិ | ៤០០.០០០៛ |
| ៥- | ឯ.ឧ | អូន | ព័ន្ធមុនីរ័ត្ន | ប្រធានគណៈកម្មាធិការគណបក្សក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ | ២០០ ដុល្លារ |
| ៦- | ឯ.ឧ | វេង | សាខុន | ប្រធានគណៈកម្មាធិការគណបក្សក្រសួងកសិកម្មរុក្ខាប្រមាញ់ និងនេសាទ | ១៥០ ដុល្លារ |
| ៧- | ឯ.ឧ | ប៉ាន | សូរស័ក្តិ | ប្រធានគណៈកម្មាធិការគណបក្សក្រសួងពាណិជ្ជកម្ម | ១៥០ ដុល្លារ |
| ៨- | ឯ.ឧ | ហ៊ុន | ណេង | ប្រធានគណៈកម្មការទី ៤ នៃរដ្ឋសភា | ១០០ ដុល្លារ |
| ៩- | ឯ.ឧ | ថោង | ខុន | ប្រធានគណៈកម្មាធិការគណបក្សក្រសួងទេសចរណ៍ | ១០០ ដុល្លារ |
| ១០- | ឯ.ឧ | អ៊ិត | សំហេង | ប្រធានគណៈកម្មាធិការគណបក្សក្រសួងការងារ និងបណ្ដុះបណ្ដាលវិជ្ជាជីវៈ | ១០០ ដុល្លារ |
| ១១- | ឯ.ឧ | គង់ | វិបុល | ប្រតិភូរាជរដ្ឋាភិបាលទទួលបន្ទុកអគ្គនាយកដ្ឋាន នៃអគ្គនាយកដ្ឋានពន្ធដារ នៃក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ | ១០០ ដុល្លារ |
| ១២- | ឯ.ឧ | លន់ | លឹមថៃ | ប្រធានគណៈកម្មាធិការគណបក្សខេត្តកំពង់ចាម | ១០០ ដុល្លារ |
| ១៣- | ឯ.ឧ | អូស្មាន | ហាសស្សាន់ | ប្រធានគណៈចលនាសាសនិកឥស្លាមនៃគណបក្សប្រជាជនកម្ពុជា | ១០០ ដុល្លារ |
| ១៤- | ឯ.ឧ | សរ | ចាំរុង | ប្រធានគណៈកម្មាធិការគណបក្សខេត្តក្រចេះ | ១០០ ដុល្លារ |
| ១៥- | ឯ.ឧ | ប៉ា | សុជាតិវង្ស | ប្រធានគណៈកម្មាធិការគណបក្សរាជធានីភ្នំពេញ | ១០០ ដុល្លារ |
| ១៦- | ឯ.ឧ | ម៉ែន | វិបុល | ប្រធានគណៈកម្មាធិការគណបក្សខេត្តស្វាយរៀង | ១០០ ដុល្លារ |
| ១៧- | ឯ.ឧ | ម៉ម | ប៊ុននាង | អនុប្រធានគណៈកម្មការទី ១០នៃព្រឹទ្ធសភា | ១០០ ដុល្លារ |
| ១៨- | ឯ.ឧ | យូ | តិរម្យ | អនុប្រធានក្រុមការងាររបស់គណៈកម្មាធិការកណ្ដាល ចុះជួយរាជធានីភ្នំពេញ | ១០០ ដុល្លារ |
| ១៩- | **គណៈកម្មការ ក៧១** | | | | ៤០០.០០០ ៛ |
| ២០- | **គណៈកម្មាធិការគណបក្សខេត្តបាត់ដំបង** | | | | ១០០ ដុល្លារ |
| ២១- | **គណៈកម្មាធិការគណបក្សខេត្តសៀមរាប** | | | | ១០០ ដុល្លារ |
| ២២- | **គណៈកម្មាធិការគណបក្សខេត្តព្រះសីហនុ** | | | | ១០០ ដុល្លារ |
| ២៣- | **គណៈកម្មាធិការគណបក្សក្រសួងកិច្ចការនារី** | | | | ៥០ ដុល្លារ |
| ២៤- | **គណៈកម្មាធិការគណបក្សខេត្តបន្ទាយមានជ័យ** | | | | ៥០ ដុល្លារ |
| ២៥- | **គណៈកម្មាធិការគណបក្សខេត្តកំពត** | | | | ៥០ ដុល្លារ |
| ២៦- | **គណៈកម្មាធិការគណបក្សក្រសួងវប្បធម៌ និងវិចិត្រសិល្បៈ** | | | | ២០០.០០០ ៛ |
| ២៧- | ឯ.ឧ | លឹម | គានហោ | ប្រធានគណៈកម្មាធិការគណបក្សក្រសួងធនធានទឹក និងឧតុនិយម | ២០០.០០០ ៛ |
| ២៨- | ឯ.ឧ | ម៉ម | ប៊ុនហេង | ប្រធានគណៈកម្មាធិការគណបក្សក្រសួងសុខាភិបាល | ៥០ ដុល្លារ |
| ២៩- | ឯ.ឧ | ថា | យ៉ាវ | អនុប្រធានគណៈកម្មាធិការគណបក្សធនាគារជាតិនៃកម្ពុជា | ២១៣.៤៧០៛ |
| ៣០- | ឯ.ឧ | ជូ | យិនស៊ឹម | រដ្ឋលេខាធិការក្រសួងសុខាភិបាល | ៥០ ដុល្លារ |
| ៣១- | ឯ.ឧ | ប៉ាវ | ហមផាន | រដ្ឋលេខាធិការក្រសួងមហាផ្ទៃ | ៥០ ដុល្លារ |
| ៣២- | ឯ.ឧ | ម៉ៅ | ប៊ុនណារិន | សមាជិកគណៈកម្មាធិការកណ្ដាលគណបក្សប្រជាជនកម្ពុជា | ២០០.០០០៛ |
| ៣៣- | ឯ.ឧ | សូ | ជុងហួរ | សមាជិកក្រុមប្រឹក្សាខេត្តព្រះសីហនុ | ៥០ ដុល្លារ |
| ៣៤- | ឯ.ឧ | ចាយ | បូរិន | អ្នកតំណាងរាស្ត្រមណ្ឌលកំពង់ចាម | ៥០ ដុល្លារ |
| ៣៥- | ឯ.ឧ | សួស | យ៉ារ៉ា | អ្នកតំណាងរាស្ត្រមណ្ឌលព្រះវិហារ | ៥០ ដុល្លារ |
| ៣៦- | ឯ.ឧ | នរៈ | រតនៈវឌ្ឍនោ | រដ្ឋលេខាធិការក្រសួងធម្មការ និងសាសនា | ២០០.០០០ ៛ |
| ៣៧- | ឯ.ឧ | ឃួន | រ៉ានីន | រដ្ឋលេខាធិការក្រសួងសង្គមកិច្ច អតីតយុទ្ធជន និងយុវនីតិសម្បទា | ៥០ ដុល្លារ |
| ៣៨- | ឯ.ឧ. | ស្តើង | សុខុម | អនុរដ្ឋលេខាធិការក្រសួងទេសចរណ៍ | ២០០.០០០៛ |
| ៣៩- | ឯ.ឧ | ឆាយ | ឫទ្ធិសែន | អគ្គនាយកនៃអគ្គនាយកដ្ឋានរៀបចំដែនដីនគរូបនីយកម្ម និងសំណង់ | ២០០.០០០៛ |
| ៤០- | ឯ.ឧ. | ប៊ុន | លឹមហេង | អនុរដ្ឋលេខាធិការទីស្ដីការគណៈរដ្ឋមន្ត្រី | ២០០.០០០៛ |
| ៤១- | ឯ.ឧ | សេង | ធៀង | អនុរដ្ឋលេខាធិការទីស្ដីការគណៈរដ្ឋមន្ត្រី | ២០០.០០០៛ |
| ៤២- | ឯ.ឧ | សុខ | ខេមរិន | អនុប្រធានក្រុមការងារចុះស្រុកកញ្ជ្រៀច និងប្រធានក្រុមការងារចុះឃុំកញ្ជ្រៀច | ៥០ ដុល្លារ |
| ៤៣- | ឯ.ឧ | ហេង | សួរ | អគ្គនាយកនាយករដ្ឋបាល និងហិរញ្ញវត្ថុនៃក្រសួងការងារ និងបណ្ដុះបណ្ដាលវិជ្ជាជីវៈ | ៥០ ដុល្លារ |
| ៤៤- | ឯ.ឧ | ម៉ែន | ស៊ីផាន់ | សមាជិកព្រឹទ្ធសភា | ១០០.០០០៛ |
| ៤៥- | ឯ.ឧ | ណៅ | ធួក | រដ្ឋលេខាធិការក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ | ១០០.០០០៛ |
| ៤៦- | ឯ.ឧ | ប៉ាន | ប៊ុនធឿន | រដ្ឋលេខាធិការក្រសួងផែនការ | ១០០.០០០៛ |
| ៤៧- | លោកជំទាវ | ស៊ឹង | ស៊ីយុត | | ១០០.០០០៛ |
| ៤៨- | ឯ.ឧ | គឹម | ធា | ប្រធានក្រុមប្រឹក្សាខេត្តស្វាយរៀង | ១០០.០០០៛ |
| ៤៩- | ឯ.ឧបណ្ឌិត | មាស | ប៉ូ | អនុរដ្ឋលេខាធិការក្រសួងប្រៃសណីយ៍ និងទូរគមនាគមន៍ | ១០០.០០០៛ |
| ៥០- | លោកជំទាវ | និត្យ | ច័ន្ទតារីន | អនុរដ្ឋលេខាធិការក្រសួងរៀបចំដែនដី នគរូបនីយកម្ម និងសំណង់ | ១០០.០០០៛ |
| ៥១- | ឯ.ឧ | ជួន | ថេរ៉ាវ៉ាត | ទីប្រឹក្សាសម្ដេចអគ្គមហាពញាចក្រី **ហេង សំរិន** | ១០០.០០០៛ |
| ៥២- | លោក | គឹម | ប៊ុណ្ណា | សមាជិកអចិន្ត្រៃយ៍នៃគណៈកម្មាធិការគណបក្សខេត្តសៀមរាបប្រធានសាខាគណបក្សមន្ទីរសាធារណការ និងដឹកជញ្ជូន | ១០០.០០០៛ |
| ៥៣- | ឯ.ឧ. ឧកញ៉ា | សន | កុសល | អនុប្រធានគណបក្សស្រុកកំពង់សិលា | ២០ ដុល្លារ |
| ៥៤- | ឯ.ឧ | ស៊ឹម | ស៊ីថា | អគ្គនាយករដ្ឋាករទឹកស្វយ័តក្រុងភ្នំពេញ | ៨០.០០០៛ |
| ៥៥- | ឯ.ឧ | អ៊ុន | ឆាលី | សមាជិកក្រុមប្រឹក្សាខេត្តកោះកុង | ៥០.០០០៛ |
| ៥៦- | ឯ.ឧ | ពត | ចាន់នី | សមាជិកក្រុមការងារចុះជួយខេត្តកំពង់ចាម | ៥០.០០០៛ |

# អ្នកឧបត្ថម្ភ ទស្សនាវដ្តី ប្រជាជន លេខ ១៩៩

| | | | | |
|---|---|---|---|---|
| ៥៧- | ឯ.ឧ | **ហេង វណ្ណា** | សមាជិកក្រុមការងារគណៈកម្មាធិការកណ្តាលចុះជួយខេត្តព្រះសីហនុ | ៥០.០០០៛ |
| ៥៨- | ឯ.ឧ | **ស៊ាង ចាន់** | សមាជិកក្រុមការងារគណៈកម្មាធិការកណ្តាលចុះជួយខេត្តព្រះសីហនុ | ៥០.០០០៛ |
| ៥៩- | លោកជំទាវ | **ស៊ើ ចំនួថា** | | ៥០.០០០៛ |
| ៦០- | លោក | **ជា វុទ្ធី** | សមាជិកក្រុមការងារគណៈកម្មាធិការកណ្តាលចុះជួយខេត្តព្រះសីហនុ | ៥០.០០០៛ |
| ៦១- | លោក | **ទេព វិសិដ្ឋ** | អនុប្រធានគណៈកម្មាធិការត្រួតពិនិត្យ នៃគណៈកម្មាធិការគណបក្សខេត្តព្រះសីហនុ | ៥០.០០០៛ |
| ៦២- | លោក | **អ៊ុំ រាត្រី** | អភិបាលរងខេត្តបន្ទាយមានជ័យ | ៥០.០០០៛ |
| ៦៣- | លោក | **ឆេង សុភក្រ្ត** | សមាជិកក្រុមការងារគណៈកម្មាធិការកណ្តាលចុះជួយខេត្តព្រះសីហនុ | ៥០.០០០៛ |
| ៦៤- | លោក | **ហូ ដារីណា** | ប្រធានការិយាល័យរដ្ឋបាល នៃធនាគារជាតិ | ៥០.០០០៛ |
| ៦៥- | ឯ.ឧ | **ថៅ វេដ្ឋា** | រដ្ឋលេខាធិការក្រសួងធនធានទឹក និងឧតុនិយម | ៤០.០០០ ៛ |
| ៦៦- | **គណៈកម្មាធិការគណបក្សប្រជាជនកម្ពុជាប្រចាំគណៈកម្មាធិការសម្របសម្រួលខ្មែរកម្ពុជាក្រោម** | | | ៤០.០០០៛ |
| ៦៧- | លោក | **លី សារី** | អភិបាលរង ខេត្តបន្ទាយមានជ័យ | ៤០.០០០៛ |
| ៦៨- | លោក | **គីម សុវណ្ណ** | ប្រធានមន្ទីរសាធារណការ ខេត្តបន្ទាយមានជ័យ | ៤០.០០០៛ |
| ៦៩- | ឯ.ឧ | **ស៊ិន វុទ្ធី** | សមាជិកអចិន្ត្រៃយ៍គណៈកម្មាធិការគណបក្សក្រសួងធនធានទឹក និងឧតុនិយម | ៣០.០០០៛ |
| ៧០- | ឯ.ឧ | **សាំង សាវ៉ាត** | សមាជិកក្រុមប្រឹក្សាខេត្តបន្ទាយមានជ័យ | ៣០.០០០៛ |
| ៧១- | លោក | **ម៉ៅ សុខលីម** | អនុប្រធានមជ្ឈមណ្ឌលជាតិស្រាវជ្រាវវេជ្ជសាស្រ្តបូរាណក្រសួងសុខាភិបាល សមាជិកក្រុមការងារចុះខណ្ឌសែនសុខ ភ្នំពេញ | ៣០.០០០៛ |
| ៧២- | លោក | **ចាន់ ស៊ីណាត** | សមាជិកគណៈកម្មាធិការគណបក្សក្រសួងធនធានទឹក និងឧតុនិយម | ៣០.០០០៛ |
| ៧៣- | លោក | **ឃុ ពៅ** | អភិបាលស្រុកស្វាយចេក | ៣០.០០០៛ |
| ៧៤- | កញ្ញា | **កែវ សុជាតា** | អនុប្រធានលេខាធិការដ្ឋានអមគណៈកម្មការទី ៤ នៃព្រឹទ្ធសភា | ៣០.០០០៛ |
| ៧៥- | លោក | **ហង់ ប៊ូ** | ប្រធានក្រុមការងារចុះ ឃុំវវៀង ស្រុកសំរោង ខេត្តតាកែវ | ២០.០០០៛ |
| ៧៦- | លោក | **ឈា ប៊ុនរិទ្ធ** | សមាជិកក្រុមការងារចុះខេត្តកណ្តាល | ២០.០០០៛ |
| ៧៧- | លោក | **ម៉ៅ ហាក់** | សមាជិកក្រុមការងារចុះខេត្តកណ្តាល | ២០.០០០៛ |
| ៧៨- | លោក | **លឹម វីរក្ស** | សមាជិកគណៈកម្មាធិការគណបក្សក្រសួងធនធានទឹក និងឧតុនិយម | ២០.០០០៛ |
| ៧៩- | លោក | **លឹម ថេង** | សមាជិកក្រុមការងារចុះខេត្តកណ្តាល | ២០.០០០៛ |
| ៨០- | លោក | **ឃ្លោក សំអាង** | សមាជិកក្រុមការងារចុះខេត្តកំពង់ចាម | ២០.០០០៛ |
| ៨១- | លោក | **ម៉ី វុឌ្ឍា** | មន្ត្រីមន្ទីរគណបក្ស ខេត្តព្រៃវែង | ២០.០០០៛ |
| ៨២- | លោក | **អ៊ុត សំអាន** | អគ្គាធិការរងនៃអធិការដ្ឋានក្រសួងរៀបចំដែនដី នគរូបនីយកម្ម និងសំណង់ | ២០.០០០៛ |
| ៨៣- | លោក | **គួច ចាន់និត្យ** | អាជីវករ ខេត្តបន្ទាយមានជ័យ | ២០.០០០៛ |
| ៨៤- | ឯ.ឧ | **សេង សុមុនី** | សមាជិកគណៈអចិន្ត្រៃយ៍គណៈកម្មាធិការគណបក្សក្រសួងធម្មការ និងសាសនា | ១០.០០០៛ |
| ៨៥- | ឯ.ឧ | **ប៉ុញ សច្ចះ** | អគ្គនាយកកិច្ចការបច្ចេកទេសនៃក្រសួងធនធានទឹក និងឧតុនិយម | ១០.០០០៛ |
| ៨៦- | លោក | **ជួន វណ្ណរិទ្ធ** | សមាជិកក្រុមការងារចុះខេត្តកណ្តាល | ១០.០០០៛ |
| ៨៧- | លោក | **ខួន ពេជ្រ** | ប្រធាននាយកដ្ឋានទឹកស្អាត ក្រសួងធនធានទឹក និងឧតុនិយម | ១០.០០០៛ |
| ៨៨- | លោក | **ម៉ម ប្រួស** | អនុប្រធាននាយកដ្ឋានរដ្ឋបាល និងធនធានមនុស្សនៃក្រសួងធានធានទឹក និងឧតុនិយម | ១០.០០០៛ |
| ៨៩- | លោក | **សៅ សម្ផស្ស** | អនុប្រធាននាយកដ្ឋានហិរញ្ញវត្ថុនៃក្រសួងនៃក្រសួងធានធានទឹក និងឧតុនិយម | ១០.០០០៛ |
| ៩០- | លោក | **ប៉ាវ មុយថុង** | អនុប្រធានគណៈកម្មាធិការសាខាបក្សមជ្ឈមណ្ឌលផ្តល់ឈាមនៃមន្ទីរពេទ្យព្រះអង្គឌួង | ១០.០០០៛ |
| ៩១- | លោក | **ឈុន ប៊ុនឈឿន** | សមាជិកក្រុមការងារចុះខេត្តកណ្តាល | ១០.០០០៛ |
| ៩២- | លោក | **ថេង ប៊ុនតេង** | សមាជិកក្រុមការងារចុះខេត្តកណ្តាល | ១០.០០០៛ |
| ៩៣- | លោក | **ស្វាយ សុគន្ធី** | សមាជិកក្រុមការងារចុះខេត្តកណ្តាល | ១០.០០០៛ |
| ៩៤- | លោក | **សុខ ចំណាន** | សមាជិកក្រុមការងារចុះខេត្តកណ្តាល | ១០.០០០៛ |
| ៩៥- | លោក | **សៅ សម្ភារ** | ប្រធានការិយាល័យបណ្តុះបណ្តាលនៃនាយកដ្ឋានរដ្ឋបាល និងធនធានមនុស្ស នៃក្រសួងធានធានទឹក និងឧតុនិយម | ១០.០០០៛ |
| ៩៦- | លោក | **ទិត ចរិយា** | ប្រធានការិយាល័យគណនេយ្យនាយកដ្ឋានហិរញ្ញវត្ថុ នៃក្រសួងធានធានទឹក និងឧតុនិយម | ១០.០០០៛ |
| ៩៧- | លោក | **សែម សំណាង** | ប្រធានការិយាល័យគ្រប់គ្រងប្រព័ន្ធធារាសាស្រ្តនាយកដ្ឋានធារាសាស្ត្រ កសិកម្ម នៃក្រសួងធានធានទឹក និងឧតុនិយម | ១០.០០០៛ |
| ៩៨- | លោក | **សុខ តារា** | សមាជិកក្រុមការងារចុះខេត្តកណ្តាល | ១០.០០០៛ |
| ៩៩- | លោក | **សូ ផល្លី** | សមាជិកក្រុមការងារចុះខេត្តកណ្តាល | ១០.០០០៛ |
| ១០០- | លោក | **ហួត ធាន** | សមាជិកក្រុមការងារចុះខេត្តកណ្តាល | ១០.០០០៛ |
| ១០១- | លោក | **ទឹម វុដ្ឋារី** | សមាជិកក្រុមការងារចុះខេត្តកណ្តាល | ១០.០០០៛ |
| ១០២- | លោក | **ណុប រឿមណី** | សមាជិកក្រុមការងារចុះខេត្តកណ្តាល | ១០.០០០៛ |
| ១០៣- | លោក | **សារុន សម្បត្តិ** | សមាជិកក្រុមការងារចុះខេត្តកណ្តាល | ១០.០០០៛ |
| ១០៤- | លោក | **សរ វិចិត្រ** | សមាជិកក្រុមការងារចុះខេត្តកណ្តាល | ១០.០០០៛ |
| ១០៥- | លោក | **នូច សុផល្លា** | សមាជិកក្រុមការងារចុះខេត្តកណ្តាល | ១០.០០០៛ |
| ១០៦- | លោក | **ជុំ ឧត្តរ៉ា** | សមាជិកក្រុមការងារចុះខេត្តកណ្តាល | ១០.០០០៛ |
| ១០៧- | លោក | **ឈ្លាង ប៊ុយ** | សមាជិកក្រុមការងារចុះខេត្តកណ្តាល | ១០.០០០៛ |
| ១០៨- | លោក | **ជីវ ស៊ុនហេង** | សមាជិកក្រុមការងារចុះខេត្ត កណ្តាល | ១០.០០០៛ |
| ១០៩- | លោក | **យស់ ធុល** | សមាជិកក្រុមការងារចុះស្រុកពោធិរៀង ខេត្តព្រៃវែង | ១០.០០០៛ |
| ១១០- | លោក | **ឡុង ចន្ធា** | សមាជិកក្រុមការងារចុះស្រុកពោធិរៀង ខេត្តព្រៃវែង | ១០.០០០៛ |
| ១១១- | លោក | **ឡាច គីរ៉ាត់** | សមាជិកក្រុមការងារចុះស្រុកបាភ្នំ ខេត្តព្រៃវែង | ១០.០០០៛ |
| ១១២- | លោក | **ឈាង សុវណ្ណារ៉ា** | មន្ត្រីមន្ទីរគណបក្ស ខេត្តព្រៃវែង | ១០.០០០៛ |



# ទិដ្ឋភាពប្រជាជនចូលរួម
# សប្បាយរីករាយនៅក្នុង



# ពិធីបុណ្យសមុទ្រលើកទី៦
# នៅខេត្តកែប

ពីថ្ងៃទី២២ ដល់ថ្ងៃទី២៤ ខែធ្នូ ឆ្នាំ២០១៧





ចែកជូនដោយឥតគិតថ្លៃ